# មាតិកា

## ១-ផ្នែកគ្រប់គ្រង


១.១-សមាសភាពនៃគណៈគ្រប់គ្រង :..........ទំព័រ ក

១.២-អារម្ភកថា :..........-- ខ


## ២-ផ្នែកអត្ថបទ


២.១- លក្ខណៈពិសេសនៃអក្សរសិល្ប៍និងវចនសព្ទវិទ្យានៃភាសាខ្មែរតាមការវិភាគសិលាចារឹកព្រៃស្វាយ នៅសុខោទ័យ នាសតវត្សទី១៤ (ឆ្នាំ១៣៦១គ.ស.) ដោយសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម :..........ទំព័រ ១

២.២- ព្យាង្គតម្រួត ឬ ព្យាង្គរាយ? ដោយសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ :..........-- ២៩

២.៣- Development of Minority Languages in Cambodia by Prof. Dr. IV Chan :...-- ៤៩

២.៤- ជុំវិញបញ្ហាអក្ខរាវិរុទ្ធខ្មែរ ដោយសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ :..........-- ៥៥

២.៥- គុណនាមក្នុងភាសាខ្មែរ ដោយលោក ប៊ី សុខគង់ :..........--៦៣

២.៦- ការសិក្សាស្រាវជ្រាវវចនសព្ទមួយចំនួននៅក្រុងប៉ៃលិន ដោយផ្នែកខេមរនីយកម្ម វចនានុក្រម និង បកប្រែ រួមសហការជាមួយផ្នែករដ្ឋបាលនៃវិទ្យាស្ថានភាសាជាតិ និង មន្ត្រីរាជបណ្ឌិតសភាកម្ពុជា :..........--៧៣

២.៧- ទំនៀមទម្លាប់ធ្វើចម្ការរបស់ជនជាតិទំពួននៅខេត្តរតនគិរី ដោយផ្នែកអក្សរសាស្ត្រ និង អក្សរសិល្ប៍ :..........---៨៣

២.៨- BRAO DIALECTS: LEXICAL AND PHONOLOGICAL VARIATIONS by Charles Keller, Jacqueline Jordi, Kenneth Gregerson, In G.Baird :..........--៨៧

## គណៈគ្រប់គ្រង

-ប្រធានកិត្តិយស : សាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង
-ចាងហ្វាងការផ្សាយ : សាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន
-ចាងហ្វាងរងការផ្សាយ : សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ

## គណៈកម្មការអំណាន

-ប្រធាន : សាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់
-អនុប្រធាន : សាស្ត្រាចារ្យបណ្ឌិត ហ្សង់មីសែល ហ្វីលីពី
-សមាជិក : -សាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន
-សាស្ត្រាចារ្យបណ្ឌិត សោម សុមនី
-សាស្ត្រាចារ្យបណ្ឌិត ហ្សាក់ រ៉ុងហ្ស៊ីយ៉េរ
-សមាជិករបាយការណ៍ : សាស្ត្រាចារ្យ សន ពៅ

## ទំនាក់ទំនងទូទៅ

-សាស្ត្រាចារ្យ ជួរ គារី
-សាស្ត្រាចារ្យ លាង សុភាព
-សាស្ត្រាចារ្យ ផង់ ភិរុណ

## ក្រុមការងារ

មន្ត្រីវិទ្យាស្ថានភាសាជាតិ

**Comité de Direction**

-Président d'honneur : Dr. Sorn Samnang
-Directeur de publication : Dr. IV Chan
-Directeur Adjoint : Dr. Chan Somnoble

**Comité de Lecture**

-Président : Prof. Prum Moal
-Vice Président : Dr. Jean Michel Filippi
-Membres : -Dr. Sum Chhumbun
-Dr. Som Somuny
-Dr. Jacques Rongier
-Membre rapporteur : Mr. San Peou

**Relations publiques**

-Chour Keary
-Leang Sopheap
-Phang Phirun

**Groupe de Travail**

Personnel de l'Institut de la Langue Nationale



ចេញផ្សាយដោយ : វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
អាសយដ្ឋាន : ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល ២
ផ្លូវសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Publié par : Institut de la Langue Nationale de l'A.R.C.
Adresse : Université Royale de Phnom Penh, Campus II
Boulevard de la Fédération de Russie Phnom Penh Cambodge
E-mail : nckl_secretariat@yahoo.com
Téléphone : 023 89 04 55, 023 89 01 80

# អារម្ភកថា

ទស្សនាវដ្ដីលេខពិសេសនេះ មានចុះអត្ថបទចុងក្រោយរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម និងស្នាដៃរបស់អ្នកស្រាវជ្រាវមួយចំនួន ជាពិសេស អតីតសិស្សនិងសហការីរបស់លោក ដែលបានរួមចំណែកអភិវឌ្ឍភាសាជាតិនិងអក្សរសាស្ត្រជាតិ ។

នៅក្នុងទិវារំលឹកខួបមួយឆ្នាំនៃសពឯកឧត្តម ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី១៥ ខែកក្កដា ឆ្នាំ២០០៨ នេះ យើងខ្ញុំសូមឧទ្ទិសស្នាដៃទាំងនេះ ជូនដល់វិញ្ញាណក្ខន្ធឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ដែលបានខិតខំពុះពារបំពេញភារកិច្ចជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតវិទ្យាស្ថានភាសាជាតិ ដើម្បីរៀបចំការអនុវត្តឯកភាវូនីយកម្មនៃការប្រើប្រាស់ភាសាជាតិ ។

**ប្រធានវិទ្យាស្ថានភាសាជាតិ**

**អ៊ុំ ចន**

# សន្និសីទស្ដីពី ការស្រាវជ្រាវ អភិរក្ស និង អភិវឌ្ឍភាសាខ្មែរ លើវិស័យវចនសព្ទវិទ្យា និងវចនានុក្រមវិទ្យា នៅរាជបណ្ឌិតសភាកម្ពុជា រៀបចំដោយៈ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦

## បទអន្តរាគមរបស់សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា

## ស្ដីអំពី

## លក្ខណៈពិសេសនៃអក្សរសិល្ប៍និងវចនសព្ទវិទ្យានៃភាសាខ្មែរតាមការវិភាគសិលាចារឹក ព្រៃស្វាយនៅសុខោទ័យ នាសតវត្សទី១៤ (ឆ្នាំ១៣៦១ គ.ស.)

លោកសាស្ត្រាចារ្យ ហ្សក សឺដេស អ្នកស្រាវជ្រាវបឋមមួយរូបនៃសិលាចារឹកប្រទេសកម្ពុជាបានសរសេរថា សិលាចារឹកវត្តព្រៃស្វាយនៅសុខោទ័យ បានរកឃើញនៅឆ្នាំ១៨៣៤ ហើយបានទទួលការសិក្សាបោះពុម្ពផ្សាយជាពិសេសដោយលោកហ្សកសឺដេស នៅឆ្នាំ១៩១៧ ដោយលោកស្រី សាវរស ពៅ នៅឆ្នាំ១៩៧៨ និង ដោយបុរាណវិទូនិងភាសាវិទូដទៃទៀត។

លក្ខណៈអក្សរសិល្ប៍និងសំនួនវោហារពាក្យពិសេសនៃភាសាខ្មែរនាសតវត្សទី១៤ដែលជាសម័យមហានគរបានលេចឡើងដោយសារការសិក្សាអត្ថបទសិលាចារឹកវត្តព្រៃស្វាយ នៅលើការប្រើប្រាស់បុរាណអក្ខរក្រម លើវិធីបំបែកមូលបទមាន បុព្វបទ និងអន្តរបទ លើទំនាក់ទំនងខាងវចនសព្ទនិងវចនាសម្ព័ន្ធនៃភាសាខ្មែរសម័យសតវត្សទី១៤ ដែលមានអត្ថាធិប្បាយជាលំដាប់លំដោយដូចតទៅនេះ៖

១-សិលាចារឹកព្រៃស្វាយបានប្រើប្រាស់គំរូបុរាណនៃអក្ខរក្រមខ្មែរប្រកបដោយតួព្យញ្ជនៈនិងស្រៈដែលមានរូបរាងជាអក្សរបួនជ្រុងដែលមានរង្វង់មូលនៅផ្នែកខាងលើនិងខាងក្រោម។ អក្សរបែបនេះ គឺកើតមកពីវិធីសំយោគរវាងតួអក្សរមូលសម័យព្រះបាទយសោវរ្ម័នទី១សតវត្សទី១០និងអក្សរបួនជ្រុងទ្រវែងនៅសម័យព្រះបាទជ័យវរ្ម័នទី៧នៅសតវត្សទី១២ ហើយគឺជាអក្សរដែលជាអក្សរមូល អក្សរឈរ និង អក្សរជ្រុងសម័យបច្ចុប្បន្ន។ គឺជាអក្សរបុរាណដែលប្រកប

ដោយភាពសង្ហារនិងសោភណ្ឌភាពសមស្របទៅតាមសិលាស្តម្ភ ដែលជាមូលដ្ឋាននៃសំណេរសម័យនោះ ដើម្បីទុកជាវត្ថុនៃការធ្វើសក្ការៈបូជាព្រះពុទ្ធសាសនា។

នៅក្នុងការសិក្សាស្រាវជ្រាវការវិវត្តន៍អក្ខរក្រមខ្មែរតាំងពីសម័យកាលដំបូងនាសតវត្សទី៣មកគឺតាមគំរូនៃអក្សរព្រាហ្មី ការសិក្សាប្រៀបធៀបតួអក្សរតាមសិលាចារឹក និង សម័យកាលនិមួយៗអាចជាជំនួយដល់ការយល់ដឹងអំពីសម័យកាលនៃសិលាចារឹកមួយចំនួនធំ ដែលបានបាត់បង់កាលបរិច្ឆេទរបស់ខ្លួនហើយមិនតែប៉ុណ្ណោះវាក៏អាចទៅជាចំណេះដឹងមួយដែលគេអាចឱ្យឈ្មោះជាបុរាណអក្ខរវិទ្យាខ្មែរដែរ (Paléographie Khmère) ។ សិលាចារឹកវត្តព្រៃស្វាយមានតួអក្សរដ៏ប្រសើរ មានអក្ខរាវិរុទ្ធនិងសំណេរដ៏ត្រឹមត្រូវ ដែលគេអាចចាត់ជាអក្សរ និង អក្ខរាវិរុទ្ធ វង្វាស់សម្រាប់ទស្សន៍ទាយការវិវត្តន៍និង កាលបរិច្ឆេទនៃអត្ថបទសំណេរជាភាសាខ្មែរទាំងនោះ មានទាំងអត្ថបទសារសេរជាសាស្ត្រាស្លឹករឹតទៀតផង។

២-នៅក្នុងវិស័យវចនសព្ទវិទ្យា ប្រភពនៃការបង្កើតពាក្យទាំងអស់ បានត្រូវប្រើប្រាស់ដើម្បីបង្កើតសមាសពាក្យ ពាក្យកម្លាយ ពាក្យរណ្តំបរិវារសព្ទ និង ពាក្យប្រកបដោយរចនាបទខ្ពង់ខ្ពស់ មានសំនួនវោហារពាក្យ ពាក្យបច្ចេកសព្ទខាងពុទ្ធសាសនា មានទាំងរាជស័ព្ទដែលជាពាក្យចាំបាច់សម្រាប់បង្កើតឧត្តមភាពនៅក្នុងរចនាបទនៃអត្ថបទ ដែលសរសេរសរសើរដល់ព្រះមហាក្សត្រ។ វាក្យសព្ទទាំងឡាយដែលមានប្រើប្រាស់នៅក្នុងអត្ថបទសិលាចារឹកតាមការសិក្សារបស់យើង យើងយល់ថា គឺជាពាក្យដែលមានវត្តមានមកនេះនៅសម័យអង្គរ ហើយនៅតែមានបន្តរស់រវើកក្នុងភាសាខ្មែរបច្ចុប្បន្នទៀតផង ហើយមិនតែប៉ុណ្ណោះពាក្យទាំងឡាយនោះមានទម្រង់ជាកន្សោមពាក្យឬជាពាក្យសមាសធម្មតា ភាគច្រើនបានប្រែក្លាយជាសំនួនវោហារពាក្យ (les expressions idiomatiques)ដែលលំអអត្ថបទសិលាចារឹកវត្តព្រៃស្វាយ ឱ្យក្លាយជាអត្ថបទអក្សរសិល្ប៍មួយប្រភេទដក់ជាប់ដោយព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររៀបរាប់អំពីបុញ្ញកិច្ចនិងព្រះសមត្ថភាពដ៏ឧត្តុងឧត្តមរបស់ព្រះករុណាព្រះបាទសូរ្យពង្សរាមាមហាធម្មិករាជាធិរាជនិងអំពីពិធីរៀបចំទទួលព្រះមហាសមីសង្ឃរាជ ដែលនិមន្តមកពីលង្កាទ្វីប ព្រមទាំងបាតុភូតធម្មជាតិដ៏មហាអស្ចារ្យដែលបានកើតមានឡើងជាបន្តបន្ទាប់ ទាំងអស់នោះបានធ្វើឱ្យអត្ថន័យអក្សរសាស្ត្រនៃអត្ថបទសិលាចារឹកមាន កម្រិតខ្ពស់ជាអតិបរិមា។

ជាពិសេសសំនួនវោហារសព្ទ និង ពាក្យរណ្តំបរិវារសព្ទ ដែលមានវត្តមានរហូតដល់

ដេញប្រហារសត្រូវជោង ដងនោះទើបស្តេចលើលា ឱ្យទានជីវិត ព្រាហ្មណ៍ តាបសី្ស ព្រះបិតកព្រៃ សម្តេចបពិត្រ ព្រះវិស្ណុកម្មគិតនិម្មាណ ខ្មែរយខ្ពល់កន្ទេល គណនាអនេកប្បការ ឆ្លង សង្សារទុក្ខ នាំសត្វឆ្លងព្រៃភព យល់ផលបុណ្យ...។ល។

សំនួនវោហារពាក្យខាងលើរមែងដក់នូវនិយមន័យទាក់ទងទៅនិងសាសនានិងជីវភាពរស់នៅរបស់អ្នកស្រុក ដែលត្រូវបានអ្នកប្រើប្រាស់ភាសារក្សាទុករហូតដល់សព្វថ្ងៃ។ពាក្យទាំងនោះអាចចាត់ទុកបានថា ជាពាក្យអក្សរសិល្ប៍។

អត្ថបទសិលាចារឹកព្រៃស្វាយនៅសុខោទ័យត្រូវបានតាក់តែងឡើងឱ្យមានដំណើររឿងប្រៀបបានទៅនឹងអត្ថបទអក្សរសិល្ប៍មួយ ដែលមានចោទបញ្ហា ហើយត្រូវបានទទួលការដោះស្រាយនៅខាងចុង ហើយដែលធ្វើឱ្យអ្នកអានមានសេចក្តីចង់ដឹង មានចិត្តរំភើប មានការកោតសរសើរនិងភក្តីភាពដល់សាសនា និង ព្រះមហាក្សត្រ។ ជាទូទៅអត្ថបទបានត្រូវនិពន្ធឡើងដើម្បីបង្ហាញថា ព្រះមហាក្សត្រមានបារមី ព្រះអង្គជាអ្នកមានបុណ្យលើដែនដីប្រៀបដូចជាអត្ថបទ សិលាចារឹកស្តុកកក់ធំ ដែលមានការពណ៌នាយ៉ាងក្បោះក្បាយអំពីលទ្ធិទេវរាជា។

ម្យ៉ាងវិញទៀតគេអាចធ្វើការសិក្សាប្រៀបធៀបសិលាចារឹកវត្តព្រៃស្វាយនៅសុខោទ័យនេះ ទៅនឹងសិលាចារឹកព្រះធាតុទ្វារនៅកំពង់ស្វាយ។ សិលាចារឹកទាំងពីរត្រូវបានចារឡើងនៅសតវត្សទី១៤ ដែលមានការពណ៌នាអំពីការនិមន្តមកដល់ និង ការទទួលដ៏គគ្រឹកគគ្រេងពីសំណាក់ព្រះមហាក្សត្រចំពោះសង្ឃរាជ និង ព្រះមហាថេរានុថេរនៃលង្កាទ្វីប ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនាថេរវាទនៅឧបទ្វីបឥណ្ឌូចិន។

សំនួនវោហារសព្ទទាំងឡាយដែលបានលំអអត្ថបទសិលាចារឹកព្រៃស្វាយឬសុខោទ័យជាភាសាខ្មែរហើយបានធ្វើឱ្យអត្ថបទនេះមានលក្ខណៈជាអត្ថបទអក្សរសិល្ប៍។

ម្យ៉ាងវិញទៀត គេអាចនិយាយបានថា សិលាចារឹកណាដែលគ្មានសំនួនវោហារពាក្យគ្មានពាក្យលំអំបរិវារសព្ទឬក៏គ្មានរូបារម្មណ៍នោះ គេមិនអាចចាត់ថ្នាក់ជាអត្ថបទនោះជាអត្ថបទអក្សរសិល្ប៍ពិតប្រាកដឡើយ។

គួរកត់សម្គាល់ផងដែរថា សំនួនវោហារសព្ទច្រើនកើតចេញមកពីនិមិត្តរូបនិយកម្មនៃពាក្យសមាសនៃកន្សោមពាក្យ។ ពាក្យទោល ឬ ពាក្យមួយម៉ាត់មិនអាចចាត់ទុកជាជាសំនួនវោហារសព្ទបានឡើង។ ពាក្យ«បញ្ជើភ្នែក» បើសម្គាល់រុក្ខជាតិម្យ៉ាងដែលដុះលើដើមត្នោតគឺជាពាក្យ

សមាស ក៏ប៉ុន្តែបើសម្គាល់ «មនុស្សដែលមិនធ្វើការ ហើយរស់ដោយសារអ្នកដទៃ នោះគឺជាសំនួនវោហារសព្ទ (expression idiomatique)»។

ដូច្នេះពាក្យនេះអាចបំពេញតួនាទីជានាមសព្ទផងនិងជាគុណសព្ទផង។ សំនួនវោហារសព្ទក្នុងអត្ថបទសិលាចារឹកសុខោទ័យបានរស់រានមានជីវិតនៅក្នុងភាសាខ្មែររហូតដល់សម័យបច្ចុប្បន្ន គឺអស់រយៈពេលប្រាំពីររយឆ្នាំហើយ ក៏ប៉ុន្តែពាក្យនីមួយៗអាចមានការផ្លាស់ប្តូរខាងសូរសព្ទនិងខាងនិយមន័យខ្លះៗប៉ុណ្ណោះ។ ជាទូទៅវចនសព្ទមានជាពិសេសសំនួនវោហារសព្ទបានរក្សាយ៉ាងខ្ជាប់ខ្ជួននូវទម្រង់ដើមរបស់ខ្លួន។

តទៅនេះគឺជាទម្រង់នៃសំនួនវោហារសព្ទចំនួនជិតមួយរយពាក្យ ដែលត្រូវបានស្រង់ចេញ ពីសិលាចារឹកសុខោទ័យ ព្រមទាំងមានការពន្យល់ ការកត់ត្រាពាក្យជាអក្សរតាំង និងបំណកប្រែនិយមន័យរបស់ពាក្យខ្មែរនាសម័យអង្គរ និង សម័យបច្ចុប្បន្នទៀតផង។

## សំណេរចម្លងតាមអត្ថបទដើម (V)

(១) បញ្ចៀនព្រះខ័ន្ធព្រះអភិធម្មតោយលោកាចារ្យគួត្បាច់

(២) នេប្រតោយប្រាប្ហណោតបល្ងិសំតេចបពិត្រញ្ញាប្បែចេតសា

(៣) ស្រាតមជ្ឈិម្ពន្ធ្យាយឆោឌធំនេប្រទ្យោពិសាស្ត្រតិ..តារាជំ...

(៤) តិបង៌មាលគ្នូយ៉្យព្រាលចន្ទព្រាលស្ដេចអាចត្យូនន្ទសេស

(៥) ប្រះប្រជ្ញាតឌ៏លាវិកវិជល្ហុំណោន្ដតិត្វរមោគរ..ក្រោយនុគ

(៦) គរាជតអកិតស្ដេចផ្ទុកខិនក្រាលត្វរបិលេចួសអាចច្បូនជម៌

(៧) ៥ណាជិតមាលអិនជារនគ្ល្យត្រូនូលជត្លេរបគុះតោយនុក្រម្មកិច្ចី

(៨) សំតេចបពិត្រអាចតករអាចលបអាចលេគនាំ..តិ..

(៩) តោយនុកិច្ចិកក្តិប្រះកម្ម៌សបមាត្រាប្រាកគក្រូយសករត្តិប្បូត

(១០) លេះហនុបណ៌នាបិសាន្ទច៌លេយស្ដុចតជតំរជស្ទ្វេយរាជខិភាឯត

(១១) ក្រិសជូឆាលយសុខោគយនៅឆ្នាំរារល្វះ១៦៨កោកន្ទូលំតេច

(១២) បពិត្រប្រេរាជបណ្ឌិតផៅអញ្ចោញ្ញមហាកាមិលផ្សូរាជតមានកិល

(១៣) ញ៉្យនចបប្រះបិដកត្រូយតលិដនៅលត្ដាថ្វិបតមានកិលាបារិយ្យ៉

(១៤) ឫក្ស៊្យណាគ្រុបធោជប្រេជរាំបិនតរបន្ទមោគល្វះតមត្ដីន្ទរគេប

(១៥) ប្រេតិស្ស៊្យលំតបុលជប្រះកុដិខិហារកល្ងជប្រើស្វាយតមានតោ

(១៦) យអិលបក្វិមស្យេ៉ ឧយនេះប្រាបរាបចកក្លេ្យបទ្វេឧគយ

(១៧) ប្រលេសបជិត្សូប្រះខិម្ហកម្មជិតវិម្ហ៌នកាលឆានុឆាលំតេច

(១៨) ប្រះមហាចេរនុភិត្លូសង្ឃ៉ាឆេ ជមោកប្រះជាធកម្រតេជអញ្ជប្រេ

(១៩) ល់តបស្លាលាឧត្យូនទ្ធបបុស្ប៊្យកល្យូប្ញត្ល្យសជ..ប្ញុឆាត្រា

(២០) បមាត្យ៌ប្រេរមាត្យមន្ត្រីរាជកុលយោងទៅពល្លលប្អូនាស

(២១) ក្លាររំបស្រុកទៅតមោកល្អះធ្យូងទោងតាលស្រុកបាជបន្ទ្រ

(២២) បាជបារថ្វីបល្អះសុខេឝយនេះមួយថ្វីតខេបប្រេបោលក្រា

(២៣) ភឝំរះប្រះរាជមាត្យ៌រំបិក្វារឝីប្តូថ្វីទៅល្អះក្វារបឝិមតលត

(២៤) ជ្រៃស្វាយឆាលជតុងិខំហារស្ថានស្បូជតស្លូនុខិតានតខិជិត្រ

(២៥) ថ្ងំលេជរក្ខុំយាភិត្យម្ឫតបណ្តាយបន្ទូជជខឝិការយ៉្យលខន្លី

(២៦) យត្រាបំតបរន្តរាលក្រាលនុជស្រួបញារ្តផ្ទំលេជតពុ

(២៧) ឝហាបាឝបុះភជរសៀលបរន្លេថ្វេប្រះប្ឫជាក្រិយោជប្រេន

(២៨) បេតប្តំរាថ្កឹតណោរាចាបឝេស្ល្យលេយឝេះនុប្ប៌្យមេលប្រះ

(២៩) រាជមាត្យ៌នោះប្រណិយ្យរស្វត្ន៌ហានជ្ជស្វត្ន៌រារាជឆាមា

(៣០) ហាសាមិសឆ្យរាជចូលប្រះជំមាឝស្ល្យត្រៃមាសកាលបុញ្ញប្រះ

(៣១) ជំធាថ្វេមហាភានឆ្លេជប្រះសំរិតតិរុំតប្រណ្ឌូជរវត្តប្រះបុ

(៣២) ទ្ធកម្រតេជរញប្រតិម្ឫវុកកណ្តាលស្រុកសុខោឝយនេះ

(៣៣) តោយប្អូថ្វីស្ថានប្រះមហាធាតុនោះស្តបជម្ភូសបល្ឆ្ចៀររំបិមួយ

(៣៤) កេតល្អះប្ឫលាំមិតពិរាជទ្រព្យតជាប្រះភានមាសឆ្យជ១០ប្រា

(៣៥) កឆ្យជ១០ខ្វុឝលារ១០ស្លាលារ៣ជិបរក្លៀ៥បាតបចុះខ្លួយខ្លួលកន្លេ

(៣៦) ១រ្វុខនោះជក្តរិក្រិយាភានបរិបរយោជតណឹតិសោតរ្យាត

(៣៧) ភលានាររនេកប្រកា·កាលបុញ្ញប្រះបមរីល្អះរស្តមិរោ

(៣៨) បបុន្តបរបុនថ្វីស្ឫប្ឫក្ស្យឆាល្ហាបច្ឆ្លៃនោះប្រះបាឝកម្រតេ

(៣៩) ជរញ្ញាក្រិក្ខុយ៌្យបក្តរាមមហាជម្ហូរាធាជិរាជក្ស្យមាភានរិល

(៤០) ធាតាបសបេសអេប្លេកព្រះសុចណ៌ប្រតិមាតិប្រតិស្ឋាលេ

(៤១) រាធមន្ទីរឆាស្តចនមស្ការឫធាសបច្ចេល្ហេយទេបអញ្ជោ

(៤២) ញាមហាសាមិសឆ្សរាធចេរាន្ទចេរភិក្សុសឆ្សចោឌថ្លេ

(៤៣) ឌលេហោមប្រាសាទរាធមន្ទីរទេបឫសធាសាមនេរ

(៤៤) កាលឆាន្សប្ឫសស្សំកិលឆោះព្រះបាទកម្រតេងអត៌ក្រ៏

(៤៥) ក្ឋយ៍ប្រចក្ករាមមហាចក្រ៏វរិធាធិរាធស្តចឈរច្ឆេន

(៤៦) លេកអញ្ចាថិនមស្ការព្រះសុចណ៌ប្រតិមាន្ទព្រះបិងកក្រេ

(៤៧) យតិប្រតបទុកលេព្រះរាធមន្ទីរន្ទមហាសមិសឆ្សរាធ

(៤៨) អជិស្ឋានពោះហានេះន្ទចល់បុន្ស្យតិអតឫសតសាសនព្រះ

(៤៩) ឬន្ធកម្រតេងអត្យខនេះអត៌ប្បំត្ឋម្ភាចក្របក្តីសំបត្តិ

(៥០) ក៏ន្ទ្រសំបត្តិព្រហ្មសំបត្តិអតត្ឋម្ភាស្បំលេឌអត់អំបានធា

(៥១) ព្រះឬន្ធបិឆាំសត្វចោឌឆ្លោឌ ត្រៃភពនេះគុះអជិម្ឋានពោះ

(៥២) ឆោះល្ហេយ ទេបយោក ត្រៃសរណាគម·ត្បលាឆោះឆ្លេក

(៥៣) ពាំនេះកក្រេកសបធិប អជិម្ឋានឫសល្ហេយទេបក្រ

(៥៤) ឌព្រះបរតបុះអំឋិសុចណ៌ ប្រាសាទបាទបារនៅល្ងះតព្រះ

(៥៥) ត្រៃស្វាយ·ឆាស្តចប្រតិម្ឋាព្រះបាទបុះតងលិតលប្រ

(៥៦) ចធិនេះប្រកម្សតខឌសបធិសសោតតល្ហ៏ឆោះ

### សំណេរបម្លែងតាមអក្សរបន្ទាត់ (IV)

(១) ............ ទុកគោរនេះឆ្វេងលេចផ្លូលទៅតាល

(២) ........ មោះតាងារអនិលលេយ · មានស្តុបច្ទ្រ

(៣) ..... កាលនោះបិមានមហាកុយ្ស៊ប្បូននោះតឹ

(៤) ...... ប្រតិស្ឋាកំលាបរិកនេះលេងតងនគណ

(៥) ..... ប្រែប្រូផិបុទ្ធបាបថ្វិតច្ទ្របុទ្ធ

(៦) ...... មានប្រុមានសបអ្នកលេយ · ឆាឆៃកកៅ

(៧) .. រូបនេះផល្អឱ្យគមានអំបេបុទ្ធប្រម៉្លូតោ

(៨) នមុនស្នំតេលយេនយលរួននេះ ... រយេនស្តបអ្ន

(៩) កបោលកំល្អូនបម្លុំតុះនេះផល្អូបិយលធលបុទ្ធ

(១០) .. តប្បូតគ្ទរបិនគណនោងប្បូយាម ... ក

(១១) ... សបអ្នករិបាបបោងឆ្វំតប្លូច្ទ្រលេយ . ម

(១២) បាចេរត្រៃបិដកតមោគអំខឹលទ្ធាទ្ធឹបសិងនៅ

(១៣) .. សិគោលគោយធក្សែណប្រែស្វាយទុកប្រះតា

(១៤) ចាសរសេរប្រះយសកិរត្តិនោងឆាស្តុបច្ទ្រប្រះន្ធ

(១៥) សស្រួបបារកំលាទុកកំល្អូនបន្លំសិមាឆាប្រៃស្វា

(១៦) យតោយឌីសបន្លិមសុខោគយនេះ

## Transliteration ជាអក្សរខ្មែរទំនើប

### ទី I

(១) ១២៦៩ គក កុរ ព្រះ បាទ កម្រតេង អញ ឞូទៃយ-

(២) រាជ ត ជា ព្រះចៅ ត ព្រះ បាទ កម្រតេង អញ គ្រីរាម-

(៣) រាជ នាំ សេនា ពល ព្យុហ ជោង អំពិ គ្រីសជនាលែយ មៅ-

(៤) ក ប្រត ផ្គត ផ្គង ហ្វង ពល ចរត ក្រៅ...ព្រះវិសែយ// នៅ

(៥) បញ្ជាមី កេត ជេស្ឋ គុក្រពារ នុ កាល ស្តច បន្ទូល ត សេ-

(៦) នា ពល ជោង..ចូល ចោម ចប កប ទ្វារ តិង ប្រហារ ស-

(៧) ត្រុ ជោង..ហោង//ៗ តោង នោះ ទេប ស្តច លិ-

(៨) លា ចូល ស្វេយ ព្រះ រាជទយ ឥឝ្វរយាធិបត្យ ត ស្រុក

(៩) សុខោទយ នេះ ស្នោង ព្រះ ជនក ព្រះ ជី វិង វូត//...ក្សុ-

(១០) ត្រ ជោង មាន ត ចតុិទិគ ស្បុង មាន.......

(១១) នាំ ... មកុត ... ខនជយគ្រីយ ស្វេតឆត្រ ...//

(១២) អភិបេក អោយ មាន ព្រះ បាទ កម្រតេង អញ គ្រីគូយ្យិ

(១៣) ពង្សរាមមហាធម្មិរាជាធិរាជ ស្វេយ...//

(១៤) ..................................

(១៥) ពុំ ចង យោក ស្បុង ថ្វេ សៅខ្យ.....កូន.......

(១៦)......................ជ-អូន ពិណា........

(១៧).......................នេះ............

(១៨)........................ស្បុង..........

(១៩)........ ........................

(២០)......................សំតេច បរិត្រ.....

(២១).......អោយ ទានុ ជីវិត្ត នោះ វិង ស្បុង ប្រេន...

(២២)......ហោង..............ប្រានិ...........

(២៣)................................នាំ

(២៤)........ជោង ឆ្លោង ...សង្ក្រាទុខ...........

(២៥)..................................

(២៦).........នាំ ហ្វង.............ប្រោស.....

(២៧)..................................

(២៨)..................ស្តច................

(២៩-៣២)............................

(៣៣)....[ព្រះបាទ] កម្រតេង អញ គ្រីត្ធយ៉ាព្យង្ស រាម [ម]-

(៣៤) ហាធម្មិរាជាធិរាជ.........................

(៣៥)..................................

(៣៦)................ស្វេយ....................

(៣៧-៣៩)..................................

(៤០).........,ជោង.............................

(៤១)................ទេប ស្តច..................

(៤២)...............គ្រមណា ព្រាហ្មហ តបស្វិ យតិ......

(៤៣)...................................

(៤៤)............ព្រះ ចេតិយ....................

(៤៥)...................................

(៤៦)................ព្រះ ពុទ្ធ......................

(៤៧)...................................[ព្រះ]

(៤៨) បាទ កម្រតេង អញ គ្រីត្ធយ៉ាព្យង្ស រាមមហាធម្មិរាជា[ធិរាជ]

(៤៩)..............នេះ ត នុ អន្តរជាន្ត...............

(៥០)...,រូប ព្រះ ឥស្វរ.....ព្រះ អង្គ បិ បរិប៉ូណា ហោង//

(៥១).....គក ឆ្ល .ទនតប កេត អាអោជ គុក្រពារ បុរ្វអាជ បូក នា..

(៥២).គ្រីសូរ្យោន្ទតិ កាល ស្តច ប្រតិស្ថា ព្រះ មហេស្វររូប វិស្ណុ រូប

(៥៣).ស.នុ ទេវាលយមហាក្សេត្រ ព្រៃស្វាយ នេះ........

(៥៤)..... តបស្វិ ព្រាហ្មណ ជោង បូជា និត្យ....ធម្ម៌......
(៥៥) អន្តរជាន ត លេយ // ។ ព្រះ បាទ កម្រតេង អញ ត្រី-
(៥៦) ភូឃ្យិពង្ស រាមមហាធម្មិរាជាធិរាជ ទ្រង ព្រះ បិដកត្រយ អាច យ្យិណា[ច]-

ទី II

(១) បយ្យិណ ព្រះ វិណយ ព្រះ អភិធម្ម៌ គោយ លោកាចាយ្យិកប្ចុត្យា ទ [អំ]-
(២) នេប្រ គោយ ព្រាហ្មណ តបស្វិ // សំតេច បរិត្រ ញាប្ត ពេទ សា-
(៣) ស្ត្រាគម ធម្មិន្យាយ ជោង ទំនេប្រ ជ្យោតិសាស្ត្រ តិ...// តារា ទំ...
(៤) តិ ពារ មាស គូយ្យិគ្រាស ចន្ទ្រគ្រាស ស្តេច អាច ត្យ [ង] នុ សេស
(៥) ព្រះ ប្រជ្ញា ត ខណារិក//រិ ជាល្គុណាន្ត តិ ត្វរ មោក អ..ក្រោយ នុ គ-
(៦) ករាជ ត អធិក ស្តេច ផ្ទិក វិង គ្រាល ត្វរ បិ ពៃ ផ្ទស//អា[ច] ត[ហ្វ]ង ពារ
(៧) ខណាធិកមាស ទិនពារ នក្សត្រ នុ សង្ក្រេប ត្វះ គោយ នុ កម្មិ [តិទ្ធិ]
(៨) សំតេច បរិត្រ អាច តក អាច លប អាច លេក នាំ...តិ..
(៩) គោយ នុ តិទ្ធិគក្តិ//ព្រះ កម្មិ សប មាត្រា ប្រាកត ត្រីយសកិរត្តិព្យត្រ
(១០) លេះហ នុ ពណិនា បិ សាទ្ធបិលេយ// ស្តច គង តំរង
ស្វេយ រាជវិភត្ត
(១១) ត្រីសជ្ជនាលយ សុខោទយ នៅ ឆ្នាំ ២២ ល្វះ ១២៨៣ គក ឆ្លូ សំតេច
(១២) បរិត្រ ប្រេ រាជបណ្ឌិត ទៅ អញ្ជេញ មហាគាមិស័ង្ឃរាជ ត មាន តិល
(១៣) យ្យិណា ចប ព្រះ បិដកត្រយ ត សិង្ហៅ លង្កាទ្វិប ត មាន តិលាចាយ្យិ
(១៤) ៗ ក្សិណាគ្រត ជោង ព្រេង//អំពិ នគរ ពន្ទ មោក ល្វះ ត មាគ្តិាន្តរ ទេប
(១៥) ប្រេ សិល្បិ លំតប សង ព្រះ កុដិ វិហារ កំល្វង ព្រៃ ស្វាយ ត មាន គោ-
(១៦) យ ទិប បគ្និម សុខោទយ នេះ//ប្រាប រាប ចក ក្បៀចសន្ទេ ថ្ងៃ ឧទយ
(១៧) ប្រពៃ សប ទិប ៗ ព្រះ វិស្ណុកម្មិ តិត និម្មិាន//កាល នា.នុ នា សំតេច
(១៨) ព្រះ មហាថេរ នុ ភិក្សុសង្ឃ ជោង មោក ព្រះ បាទ កម្រតេង អញ ប្រេ
(១៩) លំតប ស្លា ឈាជ ឡូន ធូប បុស្ប កល្បព្រក្ស សង..ថ្ងៃ បូជា ត្រា-
(២០) ប មិាគ្គ ប្រេ អមាត្យ មន្ត្រី រាជកុលជោង ទៅ ទលទូល បូជា ស-

(២១) ក្ការ អំពិ ស្រុក ឆោត មោក ល្វះ ជ្យង ទោង គល ស្រុក បាង ចន្ទ្រ

(២២) បាង ពារ ვ្ថ់ ល្វះ សុខោទយ នេះ ម្វយ ვ្ត//ទេប ប្រេ បោស ក្រា-

(២៣) គ ជំរះ ព្រះ រាជមា៌ត្គ អំពិ ទ្វារ តិ ឬ្វិ ទៅ ល្វះ បត្ចិម គល គ

(២៤) ព្រះ ស្វាយ សង កុដិ វិហារស្ថាន//ស្យង តស្ស នុ វិតាន គ វិចិត្រ

(២៥) ព្វំ លេង វត្ថិយាទិត្យ ម្វត បន្លាយ បនល្វង ជវនិកា រំយ្វល ვ្-

(២៦) យ ត្រា បំគប អន្តរាល ក្រាល នុ ពស្ត្រ បញ្ចរង្គ ព្វំ លេង គ ពុ-

(២៧) ធបាទ ចុះ គ ធរណិ សប អន្លេ ថ្ងេ ព្រះ បូជា ក្រិយា ជោង ប្រេន

(២៨) ពេគ ព្វំ អាថ្កី គណនា ថា បិ ឥស្ស លេយ//ទោះ នុ ប៉្យប មេល ព្រះ

(២៩) រាជមាត្គិ នោះ ប្រពៃ យ្វរ សត្វគ្គិ ៗ ហាន ផ្លូ ស្វត្គិ//ទេបអារាធនា ម-

(៣០) ហាសាមិ សង្ឃរាជ ចូល ព្រះ ពមិា ឥស្ស ព្រៃ មាសកាល ចុញ ព្រះ

(៣១) ពមិា ថ្វេ មហាទាន ឆ្លោង ព្រះ សំរិត តិ គិត ប្រល្វង អង្គ ព្រះ ពុ-

(៣២) ទ្ធ កម្រតេង អញ ប្រតិម្ថា ទុក កន្តាល ស្រុក សុខោទយ នេះ

(៣៣) តោយ ប្វរិស្ថាន ព្រះ មហាធាតុ នោះ//ស្តប ធម្ម សប ថ្ងៃ អំពិ ម្វយ

(៣៤) កេត ល្វះ បូណ៌មិ គ គិ រាជទ្រព្យ គ ជា ព្រះ ទាន មាស ជ្យង១០ ប្រា-

(៣៥) ក ជ្យង១០ ខ្វទ លារ១០ ស្លា លារ២ ចិពរ គ្រែ៤ បាត ពពុះ ខ្នេយ

ខ្នួលកន្ទេ-

(៣៦) ល វ្វ នោះ ជគ្គ ក្រិយា ទាន បរិពរ ជោង គ ទៃ តិសោត អ្យត

(៣៧) គណនា អនេកប្រការ//។ កាល ចុញ ព្រះ ពមិា ល្វះ អស្តមិ ពា-

(៣៨) ច ពុទ្ធពរ បុនរិស្វប្វក្សនា ល្វាច ថ្ងៃ នោះ ព្រះ បាទ កម្រតេ-

(៣៩) ច ពុទ្ធពរ បុនរិស្វប្វក្សនា ល្វាច ថ្ងៃ នោះ ព្រះ បាទ កម្រតេ-

(៣៩) ង អញ ត្រិត្វយ៉្យពង្ស រាមមហាធម្មរាជាធិរាជក្សមាទាន គិល

(៤០) ជា តាបសពុស អេ ញ្ណក ព្រះ សុពណ៌ប្រតិមា តិ ប្រតិស្ថា លេ

(៤១) រាជមន្ទិរ នា ស្តច នមស្ការ បូជា សប ថ្ងៃ//ល្ហេយ ទេប អញ្ជេ-

(៤២) ញ មហាសាមិ សង្ឃរាជ ថេរានុថេរ ភិក្សុសង្ឃ ជោង ថ្លេ

(៤៣) ង លេ ហេមប្រាសាទ រាជមន្ទិរ ទេប ប្វស ជា សាមនេរ//

(៤៤) កាល នា នុ បួស ស្ងំ គិល នេះ ព្រះ បាទ កម្រតេង អញ ត្រី-

(៤៥) ភូវនាទិត្យវង្ស រាមមហាធម្មិរាជាធិរាជ ស្តច ឈរ ថ្លេង

(៤៦) លេក អញ្ជលិ នមស្ការ ព្រះ សុពណ៌ប្រតិមា នុ ព្រះ បិដកត្រ-

(៤៧) យ តិ ប្រតប៉ុ ទុក លេ ព្រះ រាជមន្ទិរ នុ មហាសាមិ សង្ឃរាជ//

(៤៨) អធិស្ឋាន រោះហ នេះ នុ ផល បុន្យ តិ អញ បួស ត សាសន ព្រះ

(៤៩) ពុទ្ធ កម្រតេង អញ វ្រ នេះ អញ ពុំ ត្ឫស្ណា ចក្រពត្តិសំបត្តិ

(៥០) ឥន្ទ្រសំបត្តិ ព្រហ្មសំបត្តិ អញ ត្ឫស្ណា ស្ងំ លេង អញ អំបាន ជា

(៥១) ព្រះ ពុទ្ធ បិ នាំ សត្វ ជោង ឆ្លោង ត្រៃភព នេះ គុះ//អធិដ្ឋាន រោះ

(៥២) នោះ ល្ហេយ ទេប យោក ត្រៃសរណាគម។ ក្សណ នោះ ផ្ទែ ក-

(៥៣) រោំ នេះ កក្រេក សប ទិឞ//អធិដ្ឋាន ល្ហេយ ទេប ទ្រ-

(៥៤) ង ព្រះ ចរត ចុះ អំពិ សុពណ៌ប្រាសាទ បាទចារ ទៅ ល្វះ ត ព្រះ

(៥៥) ព្រៃ ស្វាយ ។ នា ស្តច ប្រទិដ្ឋា ព្រះ បាទ ចុះ ត ធរណិ តល ប្រ-

(៥៦) ថពិ នេះ ប្រកម្បត រិង សប ទិស សោត//ត ណ្ឌោច នោះ

## ទី III

(១) ...ចលច...ថ្ងៃ......ច ពុញ......................

(២) ...រ លេយ.................កាល...............

(៣) .យ គា ...ក្ស ...............យ...............

(៤) ... នោះ ទេប ស្តច...........................

(៥) .........មាន នាគរាជ........................

(៦) ........................................

(៧) ...................យ....................

(៨) ...................រោ....................

(៩) ...................គរិ....................

(១០) ...................រិ ជនគណ.................

(១១) ....................មហាគូយ៉្យ.................

(១២) ..................នោះ បិ មាន................

(១៣-៤៥) ..............................

(៤៦) ...........................មា ត ជា វប្ឫទ្ធិ

(៤៧) .............ព្រះ ជនក អោយ នាម ព្រះ...........

(៤៨) .........យ......រាជ............អភិបេក......

(៤៩) រាជសំបត្តិ . វល នុ .........................

(៥០) .......ទៅ .រក ស្រុក មួយ ជ្មោះ គ្រី  .ទា ..

(៥១-៥៦) ...........................

## ទី IV

(១) ...................ទុក ទេវ ជេង ថ្លេង លេ ថ្នល ទៅ តល

(២) .................មោះ ត ជា អន្និល លេយ ។ មន ស្តច ថ្ងៃ

(៣) .................កាល នោះ បិ មាន មហាគូយ៉្យ ស្រុវ នោះ តិ

(៤) .................ប្រ [តិស្ថា] គិលាចារិក នេះ លេង ត ជនគណ

(៥) .......................ប្រេ ប្រពៃ បុន្យ បាប រូត ថ្ងៃ បុន្យ

(៦) ..............មាន ប្រមាទ សប អ្នក លេយ//។ នា ថ្ងៃ កំពៅ

(៧) ...........ស្រុវ នេះ ឥល្វ ខ្មិ រុ ត មាន អំពេ បុន្យ ធម្មិ ជោ-

(៨) ង មុន ពុំ តេល យេង យល ស្រុវ នេះ ... រ យេង ស្តប អ្ន-

(៩) ក ពោល កំល្ហុង ធមិ គុះ នេះ ឥល្វ បិ លយ ជល បុន្យ

(១០) ...ត ព្យូត// គួរ បិ ជនគណ ជោង ព្យាយាម... គ

(១១) ....សប អ្នក រិ បាប ជោង ពុំ គប បិ ថ្ងៃ លេយ//។ [ម]-

(១២) [ហា]ថេរ ត្រៃបិដក ត មោក អំរិ លង្កាទ្វិប សិង នៅ

(១៣) .. សិទោល តោយ ទក្សិណ ព្រៃ ស្វាយ ទុក ព្រះ គា-

(១៤) [ថា ស]រសេរ ព្រះ យសកិរត្តិ ជោង នា ស្តច ថ្ងៃ ព្រះ ផ្ទ-

(១៥) [ស] //ស្រេច ចារ គិលា ទុក កំល្វង ពន្ធសិមា នា ព្រៃ ស្វា-

(១៦) [យ តោ]យ [ទិ]ស បត្ចិម សុខោទយ នេះ

# អត្ថបទបកប្រែសិលាចារឹកព្រៃស្វាយ សុខោទ័យ
# ដោយសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម

## I

(១) នៅឆ្នាំ១២៦៩ នៃមហាសករាជ ត្រូវនឹងឆ្នាំកុរ ព្រះបាទស្រីឫទៃយរាជ
(២) ជាព្រះចៅព្រះបាទស្រីរាមរាជ (ព្រះបាទរាមាកំហែង)
(៣) បាននាំពលសេនាព្យុហយាត្រាជងទាំងឡាយចេញអំពីទីក្រុងស្រីសជ្ជនល័យ
(៤) មកព្យេបចំផ្គត់ផ្គង់ឱ្យល្អប្រសើរ ធ្វើដំណើរទៅក្រៅ...ព្រះតំបន់។ នៅថ្ងៃ
(៥) ប្រាំកើតខែជេស្ឋ ថ្ងៃសុក្រព្រះមហាក្សត្រស្ដេចមានព្រះបន្ទូលដល់
(៦) ពលសេនាជងទាំងឡាយ...ឱ្យចូលចោមចាប់កាប់ទ្វារ ដេញប្រហារ
សត្រូវទាំងឡាយ...
(៧) ជងនោះ ទើបព្រះករុណាស្ដេច
(៨) លើលាចូលសោយព្រះរាជសម្បត្តិ ដំឧត្តុងឧត្តម នៅរាជធានី
(៩) សុខោទ័យ នេះស្នងព្រះជនក និង ព្រះជីតាតព្យេងទៅ។ បណ្ដាមហាក្សត្រ
(១១) នាំ...ព្រះមកុដ...ព្រះខ័ន ជ័យស្រីស្វេតឆត្រមកថ្វាយព្រះអង្គ
(១២) ព្រះអង្គទទួលអភិសេក ហើយមានព្រះបរមនាមជាព្រះបាទកម្រតេងអញស្រី
(១៣) សូរ្យពង្ស រាមមហាធម្មិរាជាធិរាជ ទ្រង់សោយរាជ សម្បត្តិ...
(១៤-៤៧).................................
(៤៨) ព្រះបាទ កម្រតេង អញ ស្រីសូរ្យពង្ស រាមមហាធម្មិរាជាធិរាជ
(៤៩) ......នេះជំនូវអន្តរធាន......
(៥០) ...រូបព្រះឥសូរ...ព្រះអង្គដំបរិបូរណ៍ហោង។
(៥១) ..មហាសករាជ គឺឆ្នាំឆ្លូវ ដណ្ដប់កើត ខែអាសាឍ ថ្ងៃសុក្រ .. បូវាសាឍ
នក្ខត្តឫក្សនៅពេលអរុណោទ័យ
(៥២) នៅកាលដែលព្រះករុណាស្ដេចប្រតិស្ឋាន បដិមា រូបមហេស្វរ រូបវិស្ណុ...
(៥៣)...និងទេវស្ថាននៃវត្តព្រៃស្វាយនេះ....
(៥៤)...ពួកតាបសឥសីនិងព្រាហ្មណាចារ្យទាំងឡាយ ធ្វើពិធីបូជា ជានិច្ច...

(៥៥) កុំឱ្យ អន្តរធានឡើយ។

(៥៦) ព្រះករុណាព្រះ កម្រតេង អញ ស្រីសូរ្យពង្ស រាមមហាធម្មិរាជាធិរាជ ទ្រង់ធ្វើការសិក្សាព្រះត្រៃបិដក ដែលព្រះអង្គបានរៀនចប់។

II

(១) ព្រះអង្គបានរៀនព្រះវិន័យ ព្រះអភិធម្ម តាមពាក្យទូន្មានរបស់សាស្ត្រាចារ្យទាំងឡាយ

(២) ជាពិសេសគឺព្រាហ្មណាចារ្យ តាបសឥសីទាំងឡាយ។ ព្រះករុណាសម្តេចបពិត្របានសិក្សាគម្ពីរវេទតាម សាស្ត្រគម វិទ្យាសាស្ត្រ តាមនិយាមនៃតក្កវិជ្ជា ជាពិសេស សិក្សាតាមហោរាសាស្ត្រ...

(៣-៥) តារាទាំងឡាយ...ខែឆ្នាំសូរ្យគ្រាស ចន្ទគ្រាស ស្តេចអាចយល់ដឹងចំណេះវិជ្ជាទាំងនេះនិងមុខវិជ្ជានៅសេសសល់។ ប្រាជ្ញារបស់ព្រះអង្គទូលំទូលាយណាស់។

(៥-៦) ថ្ងៃខែជល្អុណ ដែលគួរមកដល់...ក្រោយនិងពេលនៃសករាជដែលលើសព្រះអង្គអាចបន្ថយឱ្យមកតិច គួរបីប្រពៃណាស់។

(៦-៩) ព្រះអង្គអាចយល់ដឹងអំពីឆ្នាំខ្វះ (ថ្ងៃខែ) និងឆ្នាំលើសនានា អំពីទិវា និងនក្ខត្តឫក្សព្រះអង្គអាចធ្វើសេចក្តី សង្ខេបដោយព្រះសមត្ថភាព។ ព្រះបរមបពិត្រសម្តេច អាចលប់ អាចលើក អាច នាំ. គឺ...

(៩-១០) ដោយភាពសក្តិសិទ្ធ។ សកម្មភាពរបស់ព្រះអង្គនៅសព្វមាត្រាក្នុងគ្រប់វិស័យមានភាពពិតប្រាកដដែល បញ្ជាក់នូវកិត្តិយសរបស់ព្រះអង្គ ពីព្រោះកាលណាធ្វើការពណ៌នាអំពីអ្វីមួយព្រះអង្គរមែងធ្វើតាមក្បួនច្បាប់។

(១០-១៥) ព្រះអង្គគង់តម្រងរាជសម្បត្តិនៅទីក្រុង ស្រីសជ្ជនាល័យ សុខោទ័យអស់រយៈពេល២២ឆ្នាំហើយនៅឆ្នាំ១២៨៣ នៃមហាសករាជ ត្រូវនឹងឆ្នាំឆ្លូវព្រះករុណាសម្តេចបពិត្រទ្រង់ប្រើរាជបណ្ឌិតឱ្យទៅអញ្ជើញមហាសមីសង្ឃរាជដែលមានសីលរៀនចប់ព្រះត្រៃបិតក ហើយដែលសិងនៅប្រទេសលង្កាទ្វីប។ ព្រះសង្ឃរាជមានសីលធម៌ ប្រៀបបាននិងព្រះខីណាស្រពពីព្រេងនាយ។

(១៤-១៦) នៅពេលព្រះសង្ឃរាជចាកចេញពី ព្រះនគរ (មកចម្ងាយ) ពាក់កណ្ដាលផ្លូវ ទើបព្រះករុណាសម្ដេចបពិត្រទ្រង់ប្រើពួកសិល្បករ សាងសង់ និងរចនាព្រះកុដិ ព្រះវិហារនៅក្នុងព្រៃស្វាយ ដែលស្ថិតនៅខាងលិចទីក្រុងសុខោទ័យនេះ។

(១៦-១៧) គេទាំងឡាយពង្រាបដីចាក់ខ្សាច់ឱ្យស្មើ និងធ្វើឱ្យប្រពៃនៅសព្វទិសទី ប្រៀបដូចព្រះវិស្ណុកម្ម បានគិត និម្មាន។

(១៧-២២) កាលណាសម្ដេចព្រះមហាថេរព្រមទាំងភិក្ខុសង្ឃផងទាំងឡាយបាននិមន្តមកដល់ព្រះករុណាសម្ដេចបពិត្រប្រើឱ្យរៀបលំដាប់គ្រឿងស្លា លាជ ទៀន ធូប បុស្ប និងដើមកល្បព្រឹក្ស សាង សង់...ធ្វើពិធីបូជាគ្រៀបគ្រាតាមដងមាគ៌ា (ព្រះអង្គ) ប្រើអាមាត្រមហាមន្ត្រីរាជវង្សានុវង្សផងទាំងឡាយទៅទទួលស្វាគមន៍ ហើយធ្វើសក្ការបូជា (ព្រះមហាសង្ឃរាជ) អំពីស្រុកឆោតមកលុះ (ភូមិ) ជ្បង់ទោងដល់ស្រុកបាំងចន្ទ្រនិងបាំងបារ រហូតដល់ទីក្រុងសុខោទ័យ (នោះតែម្តង)។

(២២-២៤) តមកព្រះអង្គប្រើបោសច្រាស់ជម្រះស្មៅតាមដងព្រះមាគ៌ាអំពីទ្វារខាងកើតលុះទ្វារទិសបច្ចិមរហូតដល់ព្រៃស្វាយ ដែលមានសង់កុដិ និងវិហារស្ថាន។

(២៤-២៧) គេបានដាក់នូវពិតានដ៏វិចិត្រតាមដងមាគ៌ាដោយពុំលែងឱ្យរស្មីព្រះអាទិត្យចែងចាំងបន្តិចបន្តួចឡើយ។ គេបានចងព្យួរបន្លាយស្បៃរនាំង ក្រណាត់រំយោលភ្ញី ផ្កាស្គុះស្គាយ ព្រះអង្គបានបង្គាប់ឱ្យក្រាលព្រំប្រកបដោយពណ៌បញ្ចរង្សី ដើម្បីកុំឱ្យព្រះបាទព្រះសង្ឃរាជឈានចុះដល់ព្រះធរណី។ នៅគ្រប់អន្លើ គេធ្វើពិធីបូជាក្រយាផងច្រើនពេក ហើយគេពុំអាចគណនាថាអស់ឡើយ។

(២៧-២៨) ទោះបីគេប្រៀបមើលព្រះមាគ៌ាប្រពៃនោះដ៏ស្អកស្កឹង ប្រៀបបានទៅនឹងផ្លូវទៅស្ថានសួគ៌។

(២៩-៣១) តមកទើបគេអារាធនានិមន្តព្រះមហាសមិសង្ឃរាជចូលព្រះវស្សាអស់មួយត្រីមាស ហើយកាលចេញព្រះវស្សាព្រះមហាក្សត្រធ្វើមហាទានដើម្បីឆ្លងព្រះ

សំរិទ្ធមួយអង្គ ដែលត្រូវបានសិតតាមទំហំអង្គព្រះពុទ្ធជាអម្ចាស់ស្ថាបនាទុក នៅកណ្ដាលស្រុកសុខោទ័យនេះ នៅទិសបូព៌ានៃព្រះមហាសរីរិកធាតុ នោះ។

(៣២-៣៦) ព្រះអង្គទ្រង់ស្ដាប់ធម៌ថ្ងៃមួយកើតលុះដល់ថ្ងៃពេញបូណ៌មី ព្រះអង្គទ្រង់ បរិចាកព្រះរាជទ្រព្យធ្វើជាព្រះរាជទានមាន មាស១០ជិង ប្រាក់១០ជិង ខូទ ១០លាន ស្លា២លាន ចីពរ៤សំណុំ (មានទាំង) បាត្រ ពពុះ សម្រាប់បិណ្ឌបាត្រ ខ្នើយខ្នល់កន្ទេលដូចបានពណ៌នាបញ្ជាក់មកហើយ រីឯគ្រឿងក្រយាទាន បរិពារផងដទៃទៀតសោតមានឥតគណនាជាអនេកប្បការ។

(៣៧-៤០) កាលចេញព្រះវស្សានៅល្ងាចថ្ងៃពុធ ទី៨ពោធ នក្ខត្តឫក្សមុនវិសុ ព្រះករុណាព្រះបាទកម្រតេងអញស្រីសូរ្យពង្សរាមមហាធម្មិរាជាធិរាជទ្រង់សមាទានសិល ដោយស្លៀកស្បង់ជាតាបសនៅចំពោះមុខបដិមា ព្រះពុទ្ធធ្វើពីមាស ដែលដំកល់នៅក្នុងព្រះរាជមន្ទីរបរមរាជវាំងហើយតមកព្រះអង្គទ្រង់នមស្ការ-បូជាឰងរាល់ថ្ងៃ។

(៤០-៤២) តមកព្រះអង្គទ្រង់និមន្តមហាសមីសង្ឃរាជថេរានុថេរភិក្ខុសង្ឃផងទាំងឡាយ ឱ្យឡើងលើប្រាង្គមាសនៃព្រះបរមរាជវាំង ទើបព្រះអង្គទ្រង់បួសជាសាមណេរ។

(៤៤-៤៦) កាលនានៅពេលបួសសុំសីលនោះ ព្រះករុណាព្រះបាទកំម្រតេងស្រីសូរ្យពង្សរាមមហាធម្មិរាជាធិរាជ ស្ដេចទ្រង់ក្រោកឈរឡើងលើកអញ្ជលី នមស្ការព្រះសុវណ្ណបដិមា និងព្រះត្រៃបិតក ដែកដំកល់ទុកក្នុងព្រះបរមរាជវាំង និងដល់ព្រះមហាសមីសង្ឃរាជ។ បន្ទាប់មកព្រះអង្គទ្រង់ធ្វើសេចក្ដីអធិស្ឋានដូចតទៅ វីផលបុណ្យដែលបានបំពេញផ្ទួសចំពោះព្រះពុទ្ធជាអម្ចាស់ នោះអញពុំប្រាថ្នាចក្រសម្បត្តិឡើយ ឥន្ទ្រសម្បត្តិឡើយ គឺអញប្រាថ្នាឱ្យបានឡើងទៅជាព្រះសាម្មាសម្ពុទ្ធដើម្បីនាំសត្វនិករផងទាំងឡាយឆ្លងត្រៃភពនេះ។

(៤៦-៥១) បន្ទាប់ពីបានធ្វើសេចក្ដីអធិស្ឋាន ទើបព្រះអង្គទ្រង់យាងចូលជ្រកក្រោមត្រៃសរណាគម។ ក្សិណនោះព្រះធរណីកក្រើកសព្វទិសា។

(៥១-៥៨) ក្រោយពិពេលប្រារព្ធពិធីអធិស្ឋាន ព្រះផ្នួសរួចហើយទើបព្រះអង្គទ្រង់យាងចុះអំពីប្រាសាទមាសទ្រង់ចរយាត្រាដល់វត្តព្រៃស្វាយ។ នៅពេលដែលព្រះអង្គទ្រង់ជាន់លើប្រថពី ព្រះធរណី ក៏កក្រើកសារជាថ្មីនៅគ្រប់ទិសទី..។

## IV

(១)...ដើរដោយជើងឡើងលើថ្នល់ទៅដល់

(២-៣) ...មោះដ៏ជាមន្ទិលឡើយ។ នៅពេលដែលព្រះមហាក្សត្រទ្រង់ធ្វើ.....
កាលនោះមានបាតុភូតដ៏មហាអស្ចារ្យមួយកើតឡើង...

(៤-៦) ...ប្រតិស្ឋានសិលាចារឹកនេះឡើងជនានុជន...ប្រើធ្វើអំពីប្រពៃបុណ្យបាប ធ្វើបុណ្យ ...(កុំបីមានប្រមាទអ្នកទាំងឡាយ។

(៦-១០) នៅលើផែនដីនេះ....ឥឡូវនេះ (គួរ) ខ្មីឃ្មាតមានអំពើបុណ្យមានកុសលធម៌ផង។ ពេលមុនយើងពុំដែលយល់ដូចនេះឡើយ...យើងស្ដាប់អ្នកពោលក្នុងកំឡុងធម៌ ឥឡូវនេះយើងនិយាយនិងយល់នៅផលបុណ្យដ៏ពិត។

(១០-១១) គួរគប្បីជនានុជនផងទាំងឡាយព្យាយាម...អ្នកទាំងឡាយវីអំពើបាបពុំគប្បីធ្វើឡើយ។

(១២-១៦) ព្រះមហាថេរព្រះត្រៃបិតកនិមន្តមកអំពីលង្កាទ្វីបសិងនៅ...សិទោរនៅទិសទក្សិននៃវត្តព្រៃស្វាយបានទទួលបន្ទុកសរសេរព្រះគាថាឧទ្ទិសដល់ព្រះកិត្តិយសផងទាំងឡាយរបស់ព្រះករុណាព្រះមហាក្សត្រនាពេលដែលព្រះអង្គបានធ្វើព្រះផ្នួសហើយស្រេចទើបមានចារឹកលើសិលា ដែលគេដំកល់ទុកក្នុងពុទ្ធសីមាក្នុងវត្តព្រៃស្វាយ។

| ស្រៈខ្មែរ " អ " | | ស្រៈពេញតួ | | ស្រៈនិស្ស័យ |
|---|---|---|---|---|
| អ | | a | | |
| អា | | ā | | ◌ា ◌ា |
| អិ | ឥ | i | ឥ | ◌ិ ◌ិ |
| អី | ឦ | ī | ឦ | ◌ី |
| អុ | ឧ | u | | ◌ុ ◌ុ |
| អូ | ឩ | ū | ឩ | ◌ូ |
| អេ | ឯ | e | | េ◌ |
| អៃ | ឰ | ai | | ៃ◌ |
| អោ | ឱ | o | ឱ | ោ◌ ោ◌ |
| អៅ | ឳ | au | | ៅ◌ |
| ឫ | | ṛ | ឬ | |
| អំ | | ṃ | | ◌ំ |
| អះ | | ḥ | | ◌ះ |

| អក្សរខ្មែរដំណើម | ការបកប្រែ | អក្សរខ្មែរ សុខោទ័យ | |
|---|---|---|---|
| ក | ka | ก | □ |
| ខ | kha | ข | □ |
| គ | ga | ค | □ |
| ឃ | gha | ฆ | □ |
| ង | ṇa | ง | □ |
| ច | ca | จ | – |
| ឆ | cha | ฉ | □ |
| ជ | ja | ช | □ |
| ឈ | jha | ฌ | □ |
| ញ | ña | ญ | □ |
| ដ | ṭa | ฎ | |
| ឋ | ṭha | | |
| ឌ | ḍa | | |
| ឍ | ḍha | | |
| ណ | ṇa | ณ | □ |
| ត | ta | ต | □ |
| ថ | tha | ถ | □ |
| ទ | da | ท | □ |
| ធ | dha | ธ | □ |
| ន | na | น | □ |
| ប | pa | บ | □ |
| ផ | pha | ผ | |
| ព | ba | พ | |
| ភ | bha | ภ | □ |
| ម | ma | ม | □ |
| យ | ya | ย | □ |
| រ | ra | ร | □ |
| ល | la | ล | □ |
| វ | va | ว | □ |
| ស | sa | ส | □ |
| ឝ | śa | ศ | □ |
| ឞ | ṣa | ษ | □ |
| ហ | ha | ห | □ |

រៀបចំដោយ : បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម

| សំនួនជាហារសព្ទភាសាខ្មែរនាសតវត្សទី១៤ ដកស្រង់ចេញពីសិលាចារឹកសុខោទ័យ | Translitération | សំនួនជាហារសព្ទភាសាខ្មែរនាសតវត្សទី២០ |
| --- | --- | --- |
| ១-ព្រះបាទ កម្រតេង អញ (I:២) | braḥ pād kamrateṅ añ | ព្រះបាទ; (ជាពាក្យសំគាល់ឋានន្តរនាមរបស់ព្រះមហាក្សត្រ)។ |
| ២-សេនា ពល ព្យូហ (I:៣) | senā bal byūh | សេនាពល ព្យុហៈយាត្រា។ |
| ៣-តោង នោះ ទេប (I:៧) | ton noḥ dep | ដងនោះទើប;នៅពេលនោះទើប។ |
| ៤-ស្វោយ ព្រះរាជ៍...ស្នោង (I:៨, ៩) | svoy braḥ rāja...snoṅ | សោយរាជ្យស្នង។ |
| ៥-ខន ជយស្រីយ (I:១១) | khan jayaçrīy | ព្រះខ័នជយស្រីយ; (ឈ្មោះព្រះខ័នរាជ ; ឈ្មោះ ប្រាសាទ ព្រះខ័ន។ |
| ៦-អោយ ទាន ជីវិត្ត (I:២១) | oy dān jivitr | ឱ្យទានជីវិត;លើកលែងទោសដល់អ្នកទោសដែលត្រូវប្រហារជីវិត។ |
| ៧-ឆ្លោង..សង្សារទុខ (I:២៨) | chliṅ .. sansāradukh | ឆ្លងសង្សារទុក្ខ, ឆ្លងវដ្តសង្សារ។ (គឺការកើត ចាស់ ឈឺស្លាប់)។ |
| ៨-ព្រះ វិនយ (II:១) . | braḥ vinay | ព្រះវិន័យ (ឈ្មោះគម្ពីរក្នុងពុទ្ធសាសនាស្តីអំពី បទបញ្ញត្តិនៃការប្រព្រឹត្តរបស់គណៈសង្ឃ។ |
| ៩-សំតេច បវិត្រ (II:២) | saṃtec pavitr | សម្តេចដ៏បពិត្រ;ព្រះករុណា ព្រះមហាក្សត្យ។ |
| ១០-ធម្ម៌ ន្យាយ (II:៣) | dharmma nyāy | ច្បាប់និង តក្កវិជ្ជា; (ធម្ម៌ > ធម៌ > ន្យាយ > និយាយ) «និយាយស្តី»។ |
| ១១-សូយ៌្យគ្រាស ចន្ទ្រគ្រាស (II:៤) | çūryyagrās candragrās | សូយ៌្យគ្រាស ចន្ទ្រគ្រាស; ចន្ទ្រគ្រាស «រាហូ ចាប់ចន្ទ្រ»។ |
| ១២-ពៃ ថ្នាស (II:៦) | bai thnas | ប្រពៃណាស់។ (ថ្នាស>ណាស់)។ |
| ១៣-តោយ នុ គិទ្ធិគាក្តិ (II:៩) | toy nu çiddhiçākti | ដោយ សក្តិសិទ្ធិ។ |
| ១៤-១២៨៣ គក ឆ្លូ (II:១១) | 1283 çaka chlū | ១២៨៣ នៃមហាសករាជ ឆ្នាំឆ្លូវ។ |
| ១៥-មហាគមិ សង្ឃរាជ (II:១២) | mahāçami saṅgharāj | ព្រះមហាសង្ឃរាជ។ |

| | | |
|---|---|---|
| ១៦-ព្រះ បិដកត្រៃ (II:១៣) | braḥ piṭak trai | ព្រះត្រៃបិដក។ |
| ១៧-លង្កាទ្វិប (II:១៣) | laṅkādvip | លង្កាទ្វីប; ប្រទេសលង្កា។ |
| ១៨-សុខោទ័យ (II:១៦) | sukhoday | ក្រុងសុខោទ័យ (សុខ+ឧទយ)។ |
| ១៩-ប្រាបរាបចាក់ខ្សាច់ (II:១៦) | prāp rāp cak khsac | ពង្រាបដី (ហើយ) ចាក់ខ្សាច់។ |
| ២០-ព្រះវិស្ណុកម្មិ គិត និម្មាន (II:១៧) | vraḥ viṣṇukarmm git nimmās | ព្រះពិស្ណុកម្ម បានគិតនិម្មាន (ស្ថាបនកម្ម)។ |
| ២១-សំតេច ព្រះមហាថេរ (II:១៨) | saṃtec braḥ mahāther | សម្តេចព្រះមហាថេរ សម្តេចព្រះសង្ឃរាជ។ |
| ២២-បូជា សក្ការ (II:១៩) | pūjā sakkār | ធ្វើពិធីសក្ការៈបូជា។ |
| ២៣-ទៅ ទល្ទួល (II:២០) | dau daldval | ទៅទទួល (ទលទូល «ទូលលើក្បាល»)។ |
| ២៤-កល្ប ឫក្ស (II:១៩) | kalpavṛkṣa | (ដើមព្រះ) កល្បព្រឹក្ស; (ឈ្មោះដើមពោធិដែលនៅទីនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់។ |
| ២៥-មួយរ្វិត (II:២២) | mvay rvvat | រួចមកទៀត; រួចមក។ |
| ២៦-លំតប ស្លា លាជ ទ្យន ធូប (II:១៩) | laṃtap slā lāj dyan dhūp | រៀបចំបូជា ស្លា លាជ ទៀន ធូប។ |
| ២៧-ពោស ក្រាគ ជំរះ (II:២៣) | pos kraç jaṃraḥ | បោស ប្រាស់ ជំរះ (ស្មៅ)។ |
| ២៨-កុដិ វិហារស្ថាន (II:២៤) | kuṭr vihārathān | កុដិ ព្រះវិហារ។ |
| ២៩-តស្ស នុ វិតាន (II:២៤) | tass nu vitān | ដាស ពិតាន (ព្រះវិហារ)។ គ្របដណ្តប់ពិតានដោយក្រណាត់សំពត់។ |
| ៣០-ពំលេង រស្មិយាទិត្យ (II:២៥) | bvaṃ leṅ raçmiyaditya | ពុំលែងរស្មីយាទិត្យ; ពុំឱ្យរស្មីព្រះអាទិត្យលា។ |
| ៣១-រំយួល វ្និយ (II:២៥) | raṃyval vniy | រំយោល ភ្ញីផ្កា។ |
| ៣២-ពស្ត្រ បញ្ចរង្គ (II:២៦) | bastr bañcaraṅg | ព្រះពស្ត្របញ្ចរង្គ; សំពត់ប្រាំពណ៌។ |
| ៣៣-ពុទ្ធបាទ (II:២៧) | buddhpād | ព្រះបាទរបស់ព្រះសម្មាសម្ពុទ្ធ; ព្រះបាទរបស់ព្រះសង្ឃ។ |
| ៣៤-គណនា ថា បិ ឥស្ស លេយ (II:២៨) | gaṇṇā thā pi iss ley | គណនាថា អ្វីមិនអស់ឡើយ។ |

| | | |
|---|---|---|
| ៣៥-ទោះ នុ ប្រ៊ិប មេល (II:២៨) | doḥ nu pryp mel | ទោះបី ប្រៀបធៀបមើល។ |
| ៣៦-ផ្លូ ស្វគ្គិ (II:២៩) | phlū svargg | ផ្លូវ (ទៅ) ស្ថានសួគ៌ា។ |
| ៣៧-ចូល ព្រះពម៌ា (II:៣០) | cval braḥ barṣā | ចូលព្រះវស្សា; ចូលវស្សា។ |
| ៣៨-ចុញ ព្រះពម៌ា (II:៣០) | cuñ braḥ barṣā | ចេញព្រះវស្សា; ចេញវស្សា។ |
| ៣៩-ថ្វេ មហាទាន (II:៣១) | thve mahādān | ធ្វើមហាទាន។ |
| ៤០-ឆ្លោង ព្រះសំរិត (II:៣១) | chloṅ braḥ saṃrit | ឆ្លង ព្រះសំរឹត; ធ្វើបុណ្យឆ្លងព្រះសំរឹត។ |
| ៤១-ព្រះពុទ្ធ កម្រតេង អញ (II:៣២) | praḥ buddh kamrateṅ añ | ព្រះសម្មាសម្ពុទ្ធជាអំម្ចាស់។ |
| ៤២-ព្រះ មហាធាតុ (II:៣៣) | braḥ mahādhātu | ព្រះសរីរិកធាតុព្រះសម្មាសម្ពុទ្ធ។ |
| ៤៣-បន្លាយ បន្លួង (II:២៥) | panlañy panlvaṅ | បន្លាយ ភ្លឺផ្ការយើងរយោង។ |
| ៤៤-ក្មេយក្នលកន្ទេល (II:៣៥) | kney knal kandel | ខ្នើយខ្នល់កន្ទេល។ |
| ៤៥- ក្រិយា ទាន (II:៣៦) | kriyā dān | ក្រយាទាន; (របស់របរជាដង្វាយដល់ព្រះសង្ឃ)។ |
| ៤៦-គណនា អនេកប្រការ (II:៣៧) | gaṇanā anekaprakār | ច្រើនឥតគណនា; ច្រើនជាអនេកកប្បការ។ |
| ៣៧-មួយ កេត ល្វះ បូណ៌មិ (II:៣៨) | mvay ket lvaḥ pūrṇmi | (ថ្ងៃ) មួយកើត លុះដល់ថ្ងៃពេញបូណ៌មី (ថ្ងៃ១៥ កើត)។ |
| ៣៨-ក្សមាទាន ឝិល (II:៣៩) | ksamādān çil | សមាទានសិល។ |
| ៣៩-ឯ ព្នេក (II:៤១) | e bnek | (នៅ) ចំពោះភ្នែក; នៅចំពីមុខ; (ព្នេក<ព្នក<ពេក<«ពែក»+-ន-(ផ្ទត់ជែក)។ |
| ៥០-នមស្ការ បូជា (II:៤១) | namaskār pūjā | ធ្វើនមស្ការ បូជា។ |
| ៥១-បួស ជា សាមនេរ (II:៤៣) | pvas jā sāmaner | បួសជាសាមណេរ។ |
| ៥២-ស្វំ ឝិល (II:៤៤) | svaṃ çil | សុំសិល; សូត្រធម៌សុំសិល។ |
| ៥៣-លេក អញ្ជលី នមស្ការ (II:៤៦) | lek añjalī namaskār | លើកអញ្ជលីនមស្ការបូជា។ |
| ៥៤-កាល នា នុ បួស (II:៤៤) | kāl nā nu pvas | កាលណាបានបួសហើយ; (កាលនា>កាលណា; នាកាល)។ |
| ៥៥-ផល បុន្យ (II:៤៨) | phal puny | ផលបុណ្យ; កុសលផលបុណ្យ។ |
| ៥៦-ថេរានុថេរ ភិក្សុសង្ឃ (II:៤២) | therānuthera bhiksaṅgh. | ព្រះថេរានុថេរៈនិងភិក្ខុសង្ឃផងទាំង |

| | | |
|---|---|---|
| | | ឡាយ។ |
| ៥៧-ចក្រពត្តិ សំបត្តិ (II:៨៩) | cakrabatti saṃpatti | សម្បត្តិនៃស្តេចចក្រពត្រ។ |
| ៥៨-ឥន្ទ្រ សំបត្តិ (II:៩០) | Indra saṃpatti | សម្បត្តិនៃព្រះឥន្ទ្រាធិរាជ។ |
| ៥៩-ព្រហ្ម សំបត្តិ (II:៩០) | brahmasaṃpatti | សម្បត្តិនៃព្រះព្រហ្ម។ |
| ៦០-អំបានជា ព្រះពុទ្ធ (II:៩១) | aṃpān jā braḥ buddha | ឱ្យបានទៅជា ព្រះពុទ្ធ។ |
| ៦១-នាំសត្វ ផោង ឆ្លោងត្រៃភព នេះ (II:៩១) | nāṃ satv phoṅ chloṅ traibhab neḥ | នាំសត្វលោកជងឆ្លងត្រៃភពនេះ; (គឺឆ្លងការកើត ចាស់ ឈឺ ស្លាប់ក្នុងវដ្តសង្សារនេះ)។ |
| ៦២-ល្ហើយ ទេប (II:៩២) | lhey dep | ហើយទើប; តមក។ |
| ៦៣-យោក ត្រៃសរណាគម (II:៩២) | yok traisaraṇāgam | យកត្រៃសរណាគម; ជ្រកក្រោមព្រះសរណាត្រៃ (ជ្រកក្រោមជម្រកទាំងបីគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ)។ |
| ៦៤-ក្សណ នោះ ផ្ដៃករាំនេះ កក្រើក សប ទិឞ (II:៩២) | kṣaṇ noḥ phdai karoṃ neḥ kakrek sap diṣ | ក្សិណនោះ ព្រះធរណីកក្រើកសព្វទិសទី; (ជានិមិត្តរូបារម្មណ៍បញ្ជាក់នូវអច្ឆរិយភាពណាមួយ)។ |
| ៦៥-ព្រះបាទចុះ តធរណី (II:៩៥) | braḥ pād cuḥ ta dharaṇi | ព្រះបាទចុះដល់ព្រះធរណី; ជើងចុះដល់ដី។ |
| ៦៦-មាន នាគរាជ (II:៥) | mān nāgarāj | មាននាគរាជ; មានពស់នាគរាជ។ |
| ៦៧-រាជ សំបត្តិ (III:៨៩) | rāja saṃpatti | រាជសម្បត្តិ; សម្បត្តិទ្រព្យរបស់ព្រះមហាក្សត្រ។ |
| ៦៨-..តេរ ជេង ត្លេង លេថ្នល (IV:១) | .. ter jeṅ tleṅ le thnal | ដើរជើង (ទទេរ) ; ឡើងលើថ្នល់។ |
| ៦៩-..មោះ តជាអន្ទិលលេយ (IV:២) | …moḥ ta jā andil ley | មានមោះជាទីមន្ទិល; មានសៅហ្មងជា; ទីមន្ទិលមិនស្អាតស្អំ។ |
| ៧០-កាល នោះ (IV:៣) | kāl noḥ | កាលនោះ; នៅពេលនោះ។ |
| ៧១-មានមហាគ្គាយ៌្យ (IV:៣) | mān mahāççāryy | មានមហាអស្ចារ្យ (មួយកើតឡើង)។ |
| ៧២-ប្រតិស្ថា តិលាចារីក (IV:៤) | pratisthā çilācārik | ប្រតិស្ឋាន សិលាចារឹក; សរសេរសិលាចារឹក។ |
| ៧៣-បុន្យ បាប (IV:៥) | puny pāp | បុណ្យ បាប។ |

| | | |
|---|---|---|
| ៧៤-ធ្វេបុន្យ (IV:៥) | thve puny | ធ្វើបុណ្យ។ |
| ៧៥-មាន ប្រមាទ សបអ្នក (IV:៦) | mān pramād sap ᵃnak | មានការប្រមាទដល់អ្នកដទៃ។ |
| ៧៦-...រូវ នេះឥលូ (IV:៧) | ruv neḥ ilū | ដូច ឥឡូវនេះ។ |
| ៧៧-អំបេ បុន្យ ធម្ម (IV:៧) | aṃbe puny dharmma | អំពើបុណ្យ (មានកុសល) ធម៌។ |
| ៧៨-មុន ពុំ តេល យេងយល (IV:៨) | mun bvuṃ tel yeṅ yal | (ពេល) មុន យើងពុំដែលយល់។ |
| ៧៩-ពោល កំលូង ធម្ម (IV:៩) | bol kaṃluṅ dharma | ពោលក្នុងកំឡុងធម៌; (គឺទេសនាទូន្មានឱ្យប្រព្រឹត្តតាមគន្លងធម៌)។ |
| ៨០-ផល បុន្យតព្យត (IV:៩) | phal puny ta byat | ផលបុណ្យដ៏ពិតប្រាកដ ផលបុណ្យបានមកដោយធម៌។ |
| ៨១-គួរ បិ (IV:១០) | gvar pi | គួរបើ; គប្បី។ |
| ៨២-ពុំ គប បិ ធ្វេ លេយ (IV:១១) | bvaṃ gappi thve ley | ពុំគប្បីធ្វើឡើយ។ |
| ៨៣-រិ បាប ផោង (IV:១១) | ri pāp phoṅ | រី (អំពើ) បាបផងទាំងឡាយ។ |
| ៨៤-តោយ ទក្សិណ (IV:១៣) | toy dakṣiṇ | ដោយទក្សិណ; នៅទិសទក្សិណ។ |
| ៨៥-ទុក ព្រះគាថា (IV:១៣) | duk braḥ gāthā | ទុកព្រះគាថា; សរសេរអត្ថបទជាភាសាសំស្ក្រឹត ឬ បាលី។ |
| ៨៦-សសើរ ព្រះយសកិរត្តិ (IV:១៤) | sarser braḥ yasakirtti | សរសេរអំពី ព្រះកិត្តិយសរបស់ព្រះមហាក្សត្រ; សរសេរប្រវត្តិរបព្រះមហាក្សត្រ។ |
| ៨៧-មហាថេរ ត្រៃបិដក (IV:១២) | mạhāther traipiṭak | ព្រះមហាថេរ ព្រះត្រៃបិដក; ព្រះមហាសង្ឃរាជ។ |
| ៨៨-សិង នៅ (IV:១២) | siṅ nau | សិងនៅ; គង់នៅ; រស់នៅ។ |
| ៨៩-ធ្វេព្រះផ្នួស (IV:១៤) | thve braḥ phnvas | ធ្វើព្រះផ្នួស; ចូលបួសជាព្រះសង្ឃ; (ពាក្យរាជសព្ទ)។ |
| ៩០-ចារ តិលា (IV:១៥) | cār çila | ចារសិលាចារឹក; សរសេរសិលាចារឹក។ |
| ៩១-កំលូង ពទ្ធសិមា (IV:១៦) | kaṃlūṅ barddha simā | កំឡុងព័ទ្ធសិមា; (នៅក្នុងវត្តព្រៃស្វាយហ៊ុំព័ទ្ធដោយសិមា និងរបងការពារ។ |
| ៩២-តោយ ទិស បត្ចិម (IV:១៦) | toy dis paçcim | ដោយទិសបស្ចិម; នៅទិសខាងលិច។ |

(II)





# ព្យាង្គតម្រួតឬព្យាង្គរាយ ?

ដោយបណ្ឌិត ព្រំ ម៉ល់
សាស្ត្រាចារ្យភាសាវិទ្យា

អ្វីដែលបានជំរុញខ្ញុំឱ្យសរសេរអត្ថបទនេះ គឺ : ១-ចង់សម្រុះសម្រួលនិន្នាការដែលបានបែកជាពីរហើយ ដែលបានបណ្ដាលឱ្យអក្ខរាវិរុទ្ធភាសាខ្មែរខ្វះឯកភាពចំពោះពាក្យមួយចំនួន ; ២-ចង់លើកទឹកចិត្តដល់អ្នកស្រាវជ្រាវពីភាសាខ្មែរឱ្យខំរកឱកាសជជែកវែកញែកនិងបំភ្លឺគ្នាទៅវិញទៅមក ឱ្យបានទូលំទូលាយ ដើម្បីចៀសវាងការភាន់ច្រឡំខ្លះដែលមិនអាចចៀសរួច បើម្នាក់ៗសម្ងំគិតតែម្នាក់ឯង ។

## ១- ការសម្រុះសម្រួល

បើយើងយកតែការប្រកាសក្បួនរបស់វចនានុក្រមធ្វើឡើងក្រោមការទទួលខុសត្រូវរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ដែលគេតែងហៅថា *វចនានុក្រម សម្ដេច ជួន ណាត* មកពិនិត្យនោះ យើងឃើញថាក្បួននោះមានចំណុចខ្សោយដោយឥតប្រកែកបាន : ផ្ទុយពីក្បួន គេសង្កេតឃើញមានពាក្យដើមជាព្យាង្គរាយដែលមានពាក្យកម្លាយកើតចេញជាព្យាង្គតម្រួត , ឧ. *គាប > ឃ្នាប* , *ចាំ > ឆ្មាំ* , *ចូល > បញ្ចូល* , ...។ រីឯពាក្យដើមជាព្យាង្គតម្រួត បែរជាមានពាក្យកម្លាយកើតចេញជាព្យាង្គរាយទៅវិញ , ឧ. *ភ្លឺ > បំភ្លឺ* , *ផ្ទុះ > បំផ្ទុះ* , ...។ ប៉ុន្តែ គប្បីយើងកុំយកតែការប្រកាសក្បួនសុទ្ធសាធមកចាប់កំហុស (ដីរដើងបួនគង់មានភ្លាត់ , អ្នកប្រាជ្ញ...) និង គប្បីពិនិត្យមើលតើ ក្នុងវចនានុក្រមនេះ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានសរសេរ *ឃ្នាប (< គាប)* , *ឆ្មាំ (< ចាំ)* , *បញ្ចូល (< ចូល)* , ... ជាព្យាង្គតម្រួត និង *បំភ្លឺ (< ភ្លឺ)* , *បំផ្ទុះ (< ផ្ទុះ)*, ... ជាព្យាង្គរាយ ឬទេ ?

យើងមិនអាចបដិសេធបានទេថា ក្នុងវចនានុក្រមនេះ ព្រះអង្គបានសរសេរ *ឃ្នាប (< គាប)* , *ឆ្មាំ (< ចាំ)* , *បញ្ចូល (<ចូល)* និង *បំភ្លឺ (<ភ្លឺ)* ,*បំផ្ទុះ (<ផ្ទុះ)* ដូចដែលយើងយល់ថាត្រឹមត្រូវនោះដែរ : ដូច្នេះ នៅពេលដែលលោកប្រកាសក្បួន លោកគិតទៅតែពាក្យកម្លាយកើតចេញពីពាក្យដើមដែលជាព្យាង្គតម្រួតតាមរយៈអន្តោបទ (ផ្នត់ដែក) /-អ'ខ-/ និង /-អ៊'ខ-/[១] នោះទេ ដូចមានក្នុងសម្រង់ភ្ជាប់នៅខាងចុងអត្ថបទនេះស្រាប់ (ឧបការីខ្ញុំស្រង់បានតែ៣០៣ពាក្យប៉ុណ្ណោះ) ។[២]

បើយើងពិនិត្យមើលសម្រង់ក្នុងតារាង យើងឃើញថា បើយើងចង់សរសេរពាក្យកម្លាយជាព្យាង្គរាយ យើងអាចធ្វើទៅបានតែចំពោះពាក្យមួយចំនួន[៣] : ចំពោះពាក្យឯទៀត យើងពិបាកសរសេរជាព្យាង្គរាយ

---

[១] ខ្ញុំសរសេរអន្តោបទ /-អ'ខ-/ និង /-អ៊'ខ-/ ជារូបសព្ទ (morphèmes) ដែលក្នុងនោះព្យញ្ជនៈ /ខ/ អាចប្ដូររូបក្នុងកាឡារូបសព្ទ (allomorphes) ជា [ង] , [ញ] , [ណ] , [ន] , [ម] ទៅតាមបរិបទ ។

[២] ដោយក្នុងសម្រង់នេះពាក្យ *ដំឡើង* បានចោទជាបញ្ហា ខ្ញុំបានយកតារាងបង្ហាញកំណកំណើតនៃពាក្យកិរិយាហេតុមកតភ្ជាប់ ដើម្បីឱ្យអ្នកអានមានមូលដ្ឋានសម្រាប់ពិចារណា ។

[៣] ខ្ញុំចង់ទាញអារម្មណ៍អ្នកភាសាវិទ្យា/ភាសាវិទូខ្មែរលើលក្ខណៈវិទ្យាសាស្ត្រនៃការកត់ត្រាសូរ/សទ្ទតា : តាមលក្ខណៈនេះ ការយក

ឱ្យគេទទួលយកណាស់ , ឧ. *កញ្ចប់ , *កង់រ៉ាក់/កង់វ៉ាក់ , ...។ ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ សម្តេច **ជួន ណាត** បានសរសេរពាក្យជំពូកនេះជាព្យាង្គតម្រួតទៅហើយ ហើយ បើអ្នកខ្លះនៅតែសរសេរពាក្យជំពូកនេះជាព្យាង្គរាយនោះ កង្វះឯកភាពក្នុងអក្ខរាវិរុទ្ធនៅតែជាបញ្ហាចោទដដែល ។ ដើម្បីឱ្យមានឯកភាព គណៈកម្មាធិការជាតិភាសាខ្មែរបានអនុម័ត កាលពីថ្ងៃពុធ ២០-០២-០៨ យកអក្ខរាវិរុទ្ធនៃវចនានុក្រមនេះជាមូលដ្ឋានហើយ : សូម ឥស្សរជនដែលបានធ្វើសម្បទាន មេត្តាទទួលអំណរគុណដ៏ជ្រាលជ្រៅពីគណៈកម្មាធិការយើង ។ គណៈកម្មាធិការនេះមានភារកិច្ចធ្វើឱ្យឯកភាពក្នុងអក្ខរាវិរុទ្ធនេះជ្រួតជ្រាបក្នុងប្រទេសទាំងមូលនៅពេលអនាគត ។

## ២- ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវខ្មែរ

ប្រទេសជាច្រើនក្នុងលោកបានធ្វើវិសោធនកម្មអក្ខរាវិរុទ្ធរបស់គេ ពីព្រោះ សូរចេះតែវិវត្តមិនឈប់ឈរ ហើយ ការវិវត្តនេះបានបណ្តាលឱ្យមានគម្លាតរវាងសូរនិងអក្ខរាវិរុទ្ធ។ ពាក្យបារាំង *sauter* ពីដើមគេអានថា [sautɛr] ហើយ ឥឡូវនេះ គេអានថា [sote] ប្លែកឆ្ងាយពីអក្ខរាវិរុទ្ធ។ ប៉ុន្តែ សាធារណជនបារាំងមិនទាន់ព្រមឱ្យគេកែអក្ខរាវិរុទ្ធនៅឡើយ ផ្ទុយពីជនជាតិឯទៀត មានជនជាតិ នៃប្រទេសអេស្ប៉ាញ , នៃប្រទេសអ៊ីតាលី ជាដើម ។

អ្វីដែលខ្ញុំបានអធិប្បាយខាងលើ បង្ហាញឱ្យឃើញថាការកែអក្ខរាវិរុទ្ធជាការធម្មតា ប៉ុន្តែ ការកែនោះត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នបំផុត ដោយមានការជជែកវែកញែក ដោយមានការបំភ្លឺគ្នាទៅវិញទៅមករវាងអ្នកស្រាវជ្រាវ ហើយ ត្រូវទុកពេលឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយៗបន្តការស្រាវជ្រាវជជែកវែកញែកទាល់តែឃើញថាពិតជាត្រឹមត្រូវ (បើនៅមានការភាន់ច្រឡំក៏មានយ៉ាងតិចតួចបំផុត) ព្រមទាំងថ្លឹងថ្លែងអំពីផលវិបាកដែលអាចកើតមានដល់ភាសា មុននឹងធ្វើវិសោធនកម្មអក្ខរាវិរុទ្ធ ពីព្រោះការកែអក្ខរាវិរុទ្ធសន្ធឹកសន្ធាប់អាចមានផលវិបាកដល់ភាសា : ការអនុវត្តទំនាញសូរបានធ្វើឱ្យអក្សរខ្មែរខ្វះលទ្ធភាពកត់ត្រាសូរជាច្រើន , ឧទាហរណ៍ : ពាក្យ *បាឡី* ត្រូវបានជំនួសដោយ *បាលី* ដែលត្រូវអានថា [balej][៤] ចុះភាសា [bali] នៃកោះ[bali] ត្រូវសរសេរបែបណាទៅ? តើយើងត្រូវសរសេរ ឈ្មោះ ឯ.ឧ. អ៊ិច សារូ [saru] បែបណាទៅ ដើម្បីកុំឱ្យគេអានថា [saro] ? , ...។

ដើម្បីឱ្យការស្រាវជ្រាវបន្តបន្ទាប់អាចទទួលការទុកចិត្តបាន អ្នកស្រាវជ្រាវត្រូវមានភាព ជាអ្នកស្រាវជ្រាវឯករាជ្យ ជាម្ចាស់ការ គឺមិនមែនអ្នកសូត្រតាមគ្រូត្រង់ៗនោះទេ[៥] ទោះបីគេមិនអាចមិនប្រើទ្រឹស្តីបានពីគ្រូរបស់គេនោះក៏ដោយ ។

---

ជើងអក្សរ *យ* ទៅប្រើជាតួប្រកបជាកំហុសតាមតក្កភាព ហើយ ការយកសញ្ញាដំលើ (॰) ទៅតាងព្យាង្គ [អ៊ម/អ៊ំម]ក៏ជាកំហុសដូចគ្នាដែរ ។ ប៉ុន្តែ នេះគ្រាន់តែជាការពិចារណាទេ,ខ្មែរម្នាក់ៗត្រូវគោរពកេរដំណែលរបស់ជាតិ (លើកលែងតែជាតិសុខចិត្តផ្លាស់ប្តូរ) ។

[៤] គប្បីយើងទទួលស្គាល់ថា ទំនាញសូរត្រូវបានបុព្វបុរសខ្មែរអនុវត្តមុន*ចលនាទំនាញសូរ* ដែលធ្វើឱកាសកម្មនៃការជំនួស *ណ* ដោយ *ន* និង *ឡ* ដោយ *ល* ទៅទៀត ។

[៥] សាស្ត្រាចារ្យខ្មែរខាងភាសាវិទ្យាមានករណីយកិច្ចបណ្តុះបណ្តាលនិស្សិតឱ្យមានគំនិតទិតៀន (esprit critique) កុំឱ្យចេះតែសូត្រតាមគ្រូដូចសត្វសេក ។

# ពាក្យកម្លាយ កើតចេញពីពាក្យដើមជាព្យាង្គតម្រួត ដោយប្រើអន្តបទ /-អ´ខ-/ ឬ /-អ៊´ខ-/

(តាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ស្រង់ចេញដោយឧបការីរបស់បណ្ឌិត ព្រុំ ម៉ល់)

<u>កំណត់ចំណាំ</u> :

១-គប្បីយើងប្រើវាក្យសព្ទបារាំងអមវាក្យសព្ទខ្មែរសិន ពីព្រោះ វាក្យសព្ទខ្មែរមិនទាន់មានឯកភាពរវាងអ្នកប្រើ ហើយ គួររំលឹកដែរថា អព្ភាសបទ (affixes) អាចជា បុព្វបទ (préfixes) ឬ អន្តបទ (infixes) ឬ បច្ឆិមបទ (suffixes) ។

២-ក្នុងរូបសព្ទ (morphème) /-អ´ខ-/ ឬ /-អ៊´ខ-/, សញ្ញា (´) មិនមែនជាសញ្ញាបន្តក់ទេ គឺជាសញ្ញាប្រើក្នុងសូរវិទ្យាសម្រាប់សម្គាល់ស្រះខ្លី។ ចំពោះ /ខ/វិញ គឺជាព្យញ្ជនៈសម្រាប់សម្គាល់ចុងរូបសព្ទដែលអាចក្លាយក្នុងកាឡរូបសព្ទ (allomorphes) ក្លាយទៅជា [ង], [ញ] , [ណ] , [ន] , [ម] ទៅតាមបរិបទ ដូចមានឧទាហរណ៍ខាងក្រោម។

៣-ដោយសារសម្រង់នេះ អ្នកអានអាចមើលឃើញថា ពាក្យណាអាចសរសេរពីរបែបបាន ពាក្យណាត្រូវសរសេរតែមួយបែប ដោយមិនបាច់បើករកពាក្យរប៉ាត់រប៉ាយក្នុងវចនានុក្រមឡើយ។

*<u>ប្រយ័ត្ន</u> . សញ្ញា/.../ និង សញ្ញា[...] មានន័យខុសគ្នា : សញ្ញា/.../ កត់ត្រារូបសព្ទ , សញ្ញា[...] កត់ត្រាកាឡរូបសព្ទ) ។*

| ល.រ | ប្រភេទពាក្យដើម | ពាក្យដើមជាព្យាង្គតម្រួត | អន្តបទ (infixes) /-អ´ខ-/ ឬ /-អ៊´ខ-/ | ពាក្យកម្លាយ | | ប្រភេទនៃពាក្យកម្លាយ |
|---|---|---|---|---|---|---|
| | | | | ព្យាង្គតម្រួត | ព្យាង្គរាយ | |
| ១ | កិ. | ក្ដាប់ | [-អ´ណ-] | កណ្ដាប់ | គ្មានព្យាង្គរាយ | ន. |
| ២ | - | ក្ដារ | [-អ´ណ-] | កណ្ដារ | - | - |
| ៣ | - | ក្លាស់ | [-អ´ន-] | កន្លាស់ | - | - |
| ៤ | - | ក្ដៅ | [-អ´ម-] | កម្ដៅ | - | កិ. ; ន. |
| ៥ | - | ក្បង់ | [-អ´ម-] | កម្បង់ | - | ន. |
| ៦ | គុ. | ក្រ | [-អ´ម-] | កម្រ | - | - |
| ៧ | កិ. | ក្រង | [-អ´ម-] | កម្រង | - | - |
| ៨ | កិ. | ក្រាញ | [-អ´ម-] | កម្រាញ | - | - |
| ៩ | កិ. | ក្រាប | [-អ´ម-] | កម្រាប | - | កិ. |
| ១០ | កិ. ; គុ. | ក្រាល | [-អ´ម-] | កម្រាល | - | ន. |
| ១១ | គុ. | ក្រាស់ | [-អ´ម-] | កម្រាស់ | - | គុ. ; ន. |
| ១២ | កិ. | ក្រិត | [-អ´ម-] | កម្រិត | - | - |
| ១៣ | គុ. | ក្រិន | [-អ´ម-] | កម្រិន | - | ន. ; គុ. |
| ១៤ | - | ក្រៀម | [-អ´ម-] | កម្រៀម | - | គុ. |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥ | គុ. | គ្រៀម<br>គ្រោះ | [-អ់ម-] | កម្រៀម<br>កម្រោះ | គ្មានព្យាង្គរាយ | គុ. |
| ១៦ | កិ. | គ្រៀវ | [-អ់ម-] | កម្រៀវ | - | - |
| ១៧ | គុ. | ក្លា | [-អ់ម-] | កម្លា | - | កិ. ; កិ.វិ. |
| ១៨ | - | ក្សាន្ត | [-អ់ម-] | កម្សាន្ត | - | កិ. |
| ១៩ | កិ. | ក្ងួត | [-អ់ម-] | កម្ងួត | - | ន. |
| ២០ | ន. | ក្ដែល | [-អ់ម-] | កម្ដែល | - | - |
| ២១ | គុ. | ខ្ទក | [-អ់ញ-] | កញ្ចក | - | ន. ; គុ. |
| ២២ | កិ. | ខ្ទប់ | [-អ់ញ-] | កញ្ចប់ | - | ន. |
| ២៣ | - | ខ្វាយ | [-អ់ម-] | កម្វាយ | - | កិ. |
| ២៤ | កិ. | ខ្វាត់ | [-អ់ម-] | កម្វាត់ | - | កិ. |
| ២៥ | គុ. ; កិ. | ខ្ទី | [-អ់ម-] | កម្ទី | - | ន. ; គុ. |
| ២៦ | គុ. ; កិ.វិ. | ខ្ទោត[១] | [-អ់ញ-] | កញ្ចោត | - | គុ. |
| ២៧ | កិ. | ខ្ទោប | [-អ់ញ-] | កញ្ចោប | - | ន. |
| ២៨ | - | ខ្ទាក់ | [-អ់ញ-] | កញ្ចាក់ | - | - |
| ២៩ | កិ.វិ. | ខ្ទះខ្ទាយ | [-អ់ញ-] | កញ្ចះកញ្ចាយ | - | កិ. ; គុ. |
| ៣០ | គុ. ; កិ.វិ. | ខ្ទាប់ | [-អ់ម-] | កញ្ចាប់ | - | កិ. |
| ៣១ | គុ. | ខ្ទិល | [-អ់ម-] | កម្ទិល | - | ន. ; គុ. |
| ៣២ | កិ. ; គុ. | ខ្ទេញ | [-អ់ម-] | កម្ទេញ | - | កិ. |
| ៣៣ | គុ. ; កិ.វិ. | ខ្ទរ | [-អ់ម-] | កម្ទរ | - | កិ. ; កិ.វិ. |
| ៣៤ | - | ខ្ទារ | [-អ់ម-] | កម្ទារ | - | កិ. |
| ៣៥ | គុ. | ខ្ទេច | [-អ់ម-] | កម្ទេច | - | កិ. ; ន. |

[១] ពាក្យ *ខ្ទោត* នេះពុំមានជាមេពាក្យទេ តែមាននៅក្នុងសេចក្ដីពន្យល់របស់មេពាក្យ *កញ្ចោត*។

| | | | | | | |
|---|---|---|---|---|---|---|
| ៣៦ | គុ. | ខ្ពស់ | [-អ´ម-] | កម្ពស់ | គ្មានព្យាង្គរាយ | ន. |
| ៣៧ | កិ. | ខ្លាច | [-អ´ម-] | កម្លាច | - | គុ. |
| ៣៨ | ន. | ខ្លោង | [-អ´ន-] | កន្លោង | - | ន. ; គុ. |
| ៣៩ | គុ. | ខ្លោច | [-អ´ម-] | កម្លោច | - | កិ. ; ន. |
| ៤០ | - | ខ្លៅ | [-អ´ម-] | កម្លៅ | - | ន. |
| ៤១ | - | ខ្លាំង | [-អ´ម-] | កម្លាំង | - | - |
| ៤២ | - | ខ្សត់ | [-អ´ម-] | កម្សត់ | - | ន. ; គុ. |
| ៤៣ | ប. | ខ្សួល | [-អ´ម-] | កម្សួល | - | ន. |
| ៤៤ | គុ. | ខ្សោយ | [-អ´ម-] | កម្សោយ | - | - |
| ៤៥ | កិ. | ខ្វារ | [-អ´ង-] | កង្វារ | - | - |
| ៤៦ | គុ. | ខ្វល់ | [-អ´ង-] | កង្វល់ | - | ន. |
| ៤៧ | - | ខ្វាក់ | [-អ´ង-] | កង្វាក់ | - | គុ. ; ន. |
| ៤៨ | - | ខ្វិន | [-អ´ង-] | កង្វិន | - | - |
| ៤៩ | កិ. | គ្រង | [-អ៊´ម-] | គម្រង | - | ន. |
| ៥០ | កិ. ; ន. | គ្រប | [-អ៊´ម-] | គម្រប | - | - |
| ៥១ | គុ. | គ្រប់ | [-អ៊´ម-] | គម្រប់ | - | កិ. ; បូ.សំ ; គុ. |
| ៥២ | កិ. | គ្រៀវ | [-អ៊´ម-] | គម្រៀវ | - | គុ. ; ន. |
| ៥៣ | កិ. ; ន. ; គុ. | គ្រោង | [-អ៊´ម-] | គម្រោង | - | ន. |
| ៥៤ | ន. | ឃ្លង់ | [-អ៊´ម-] | គម្លង់ | - | គុ. ; ន. |
| ៥៥ | កិ. | ឃ្លាន | [-អ៊´ម-] | គម្លាន | - | ន. |
| ៥៦ | គុ. | ច្បង | [-អ´ម-] | ចម្បង | - | គុ. |
| ៥៧ | កិ. | ច្បាំង | [-អ´ម-] | ចម្បាំង | - | ន. |
| ៥៨ | - | ច្រក | [-អ´ម-] | ចម្រក | - | - |
| ៥៩ | កិ. ; ន. | ច្រត់ | [-អ´ម-] | ចម្រត់ | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| ៦០ | កិ. | ច្រូត | [-អ´ម-] | ចម្រូត | គ្មានព្យាង្គរាយ | ន. ; គុ. |
| ៦១ | កិ. ; កិ.វិ. | ច្រប់ | [-អ´ង-] | ចង្រប់ | - | ន. |
| ៦២ | កិ. ; កិ.វិ. | ច្រុះ | [-អ´ម-] | ចម្រុះ | - | គុ. ; កិ.វិ. |
| ៦៣ | គុ. | ច្រាញ | [-អ´ម-] | ចម្រាញ | - | ន. |
| ៦៤ | កិ. | ច្រាន | [-អ´ម-] | ចម្រាន | - | - |
| ៦៥ | - | ច្រាល់ | [-អ´ម-] | ចម្រាល់ | - | - |
| ៦៦ | - | ច្រាស | [-អ´ម-] | ចម្រាស | - | កិ. |
| ៦៧ | កិ. | ច្រុង | [-អ´ម-] | ចម្រុង | - | ន. |
| ៦៨ | កិ. | ច្រុះ | [-អ´ម-] | ចម្រុះ | - | គុ. ; កិ.វិ. |
| ៦៩ | គុ. ; កិ.វិ. | ច្រូង | [-អ´ម-] | ចម្រូង | - | ន. |
| ៧០ | គុ. | ច្រើន | [-អ´ម-] | ចម្រើន | - | កិ. ; គុ. |
| ៧១ | កិ. | ច្រៀក | [-អ´ម-] | ចម្រៀក | - | ន. |
| ៧២ | - | ច្រៀង | [-អ´ម-] | ចម្រៀង | - | - |
| ៧៣ | - | ច្រេះ | [-អ´ម-] | ចម្រេះ | - | - |
| ៧៤ | - | ច្រោះ | [-អ´ម-] | ចម្រោះ | - | - |
| ៧៥ | កិ.វិ.; និ. | ឆ្កុយ | [-អ´ម-] | ចម្កុយ | - | កិ. |
| ៧៦ | កិ. | ឆ្ការ | [-អ´ម-] | ចម្ការ | - | ន. |
| ៧៧ | គុ. ; ឧ. | ឆ្កួត | [-អ´ម-] | ចម្កួត | - | គុ. |
| ៧៨ | - | ឆ្កៀល[២] | [-អ´ង-] | ចង្កៀល | - | ន. |
| ៧៩ | កិ. | ឆ្កៀស | [-អ´ង-] | ចង្កៀស | - | ន. |
| ៨០ | - | ឆ្កឹះ | [-អ´ង-] | ចង្កឹះ | - | - |
| ៨១ | គុ. ; កិ.វិ. | ឆ្ងាញ់ | [-អ´ម-] | ចម្ងាញ់ | - | ន. |
| ៨២ | គុ. | ឆ្ងាយ | [-អ´ម-] | ចម្ងាយ | - | - |

[២] ពាក្យ *ឆ្កៀល* នេះមិនមានជាមេពាក្យក្នុងវចនានុក្រមទេ តែមាននៅក្នុងសេចក្ដីពន្យល់របស់មេពាក្យ *ចង្កៀល* និង *ឆ្កឹះឆ្កៀល*។

| | | | | | | |
|---|---|---|---|---|---|---|
| ៨៣ | កិ. | ឆ្លាម | [-អ´ម-] | ចម្លាម | គ្មានព្យាង្គរាយ | ន. |
| ៨៤ | - | ឆ្លូង | [-អ´ម-] | ចម្លូង | - | កិ. |
| ៨៥ | កិ. | ឆ្លាក់ | [-អ´ម-] | ចម្លាក់ | - | ន. |
| ៨៦ | - | ឆ្លើយ | [-អ´ម-] | ចម្លើយ | - | - |
| ៨៧ | គុ. | ឆ្លែក | [-អ´ម-] | ចម្លែក | - | គុ. |
| ៨៨ | កិ. | ឆ្ងាយ | [-អ´ង-] | ចង្ងាយ | - | ន. |
| ៨៩ | គុ. | ឆ្អាប | [-អ´ម-] | ចម្អាប | - | - |
| ៩០ | - | ឆ្អិន | [-អ´ម-] | ចម្អិន | - | កិ. |
| ៩១ | ន. | ឆ្អឹង | [-អ´ម-] | ចម្អឹង | - | គុ. |
| ៩២ | កិ. ; គុ. | ឆ្ងើរ | [-អ´ង-] | ចង្ងើរ | - | ន. |
| ៩៣ | កិ. | ឆ្អែត | [-អ´ម-] | ចម្អែត | - | កិ. ; ន. |
| ៩៤ | កិ. ; គុ. | ឆ្អេះ | [-អ´ម-] | ចម្អេះ | - | ន. ; គុ. |
| ៩៥ | កិ. | ជ្រំ | [-អ៊´ញ-] | ជញ្រ្ជំ | - | កិ.វិ. |
| ៩៦ | - | ជ្រក | [-អ៊´ម-] | ជម្រក | - | កិ. ; ន. |
| ៩៧ | - | ជ្រាប | [-អ៊´ម-] | ជម្រាប | - | - |
| ៩៨ | គុ. | ជ្រាល | [-អ៊´ម-] | ជម្រាល | - | កិ. ; កិ.វិ. ; ន. |
| ៩៩ | កិ. ; កិ.វិ. | ជ្រុល | [-អ៊´ម-] | ជម្រុល | - | កិ. |
| ១០០ | កិ. ; គុ. | ជ្រួញ | [-អ៊´ម-] | ជម្រួញ | - | កិ. ; ន. |
| ១០១ | កិ. | ជ្រុះ | [-អ៊´ម-] | ជម្រុះ | - | កិ. |
| ១០២ | - | ជ្រះ | [-អ៊´ម-] | ជម្រះ | - | - |
| ១០៣ | - | ជ្រើស | [-អ៊´ម-] | ជម្រើស | - | ន. ; គុ. |
| ១០៤ | កិ. ; គុ. | ជ្រេញ | [-អ៊´ម-] | ជម្រេញ | - | កិ. |
| ១០៥ | កិ. | ជ្រែក | [-អ៊´ម-] | ជម្រែក | - | ន. |
| ១០៦ | - | ជ្រោង | [-អ៊´ម-] | ជម្រោង | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| ១០៧ | កិ. | ឈ្នះ | [-អ៊ʹម-] | ជម្នះ | គ្មានព្យាង្គរាយ | កិ. ; ន. |
| ១០៨ | ន. ; គុ. | ឈ្លើយ | [-អ៊ʹម-] | ជម្លើយ | - | ន. ; គុ. |
| ១០៩ | កិ. | ឈ្លៀស | [-អ៊ʹម-] | ជម្លៀស | - | ន. |
| ១១០ | - | ឈ្លោះ | [-អ៊ʹម-] | ជម្លោះ | - | - |
| ១១១ | កិ. | ត្បាញ | [-អʹម-] | តម្បាញ | - | ន. |
| ១១២ | - | ត្បារ | [-អʹម-] | តម្បារ | - | - |
| ១១៣ | - | ត្បូត | [-អʹម-] | តម្បូត | - | - |
| ១១៤ | - | ត្បៀត | [-អʹម-] | តម្បៀត | - | - |
| ១១៥ | - | ត្រង | [-អʹម-] | តម្រង | - | - |
| ១១៦ | គុ.;កិវិ;ន. ; អាធិ. | ត្រង់ | [-អʹម-] | តម្រង់ | - | កិ. ; កិ.វិ. |
| ១១៧ | កិ. | ត្រា | [-អʹម-] | តម្រា | - | ន. |
| ១១៨ | - | ត្រាប់ | [-អʹម-] | តម្រាប់ | - | - |
| ១១៩ | - | ត្រាយ | [-អʹម-] | តម្រាយ | - | - |
| ១២០ | - | ត្រាស់ | [-អʹម-] | តម្រាស់ | - | - |
| ១២១ | - | ត្រិះ | [-អʹម-] | តម្រិះ | - | - |
| ១២២ | គុ. ; កិ.វិ. | ត្រឹម | [-អʹម-] | តម្រឹម | - | កិ. ; កិ.វិ. |
| ១២៣ | គុ.;កិវិ.; កិ.នុ. | ត្រូវ | [-អʹម-] | តម្រូវ | - | កិ. ; កិ.វិ. |
| ១២៤ | កិ. | ត្រួត | [-អʹម-] | តម្រួត | - | កិ. ; ន. |
| ១២៥ | កិ.វិ. | ត្រៀប | [-អʹម-] | តម្រៀប | - | កិ. |
| ១២៦ | កិ. | ត្រែក | [-អʹម-] | តម្រែក | - | ន. |
| ១២៧ | ន. ; កិ. | ត្រាំ | [-អʹម-] | តម្រាំ | - | - |
| ១២៨ | ប. | ត្អឹង | [-អʹម-] | តម្អឹង | - | កិ. ; កិ.វិ. |
| ១២៩ | កិ. | ត្អូញ | [-អʹម-] | ម្អូញ | - | ន. |
| ១៣០ | កិ. | ថ្កូវ | [-អʹង-] | តង្កូវ | - | ន. |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣១ | កិ. | ថ្កៀប | [-អ´ង-] | តង្កៀប | គ្មានព្យាង្គរាយ | ន. |
| ១៣២ | កិ. ; កិ.វិ. | ថ្កល់ | [-អ´ម-] | តម្កល់ | - | កិ. |
| ១៣៣ | ប. ; កិ. | ថ្កាត់ | [-អ´ម-] | តម្កាត់ | - | ន. |
| ១៣៤ | គុ. | ថ្កើង | [-អ´ម-] | តម្កើង | - | កិ. |
| ១៣៥ | ប. | ថ្កុំ | [-អ´ម-] | តម្កុំ | - | ប. |
| ១៣៦ | កិ. | ថ្កក់ | [-អ´ម-] | តម្កក់ | - | ន. |
| ១៣៧ | - | ថ្កេច | [-អ´ម-] | តម្កេច | - | - |
| ១៣៨ | គុ. | ថ្កែក | [-អ´ម-] | តម្កែក | - | ន. ; គុ. |
| ១៣៩ | - | ថ្លង់ | [-អ´ម-] | តម្លង់ | - | ន. ; គុ. ; កិ. ; កិ.វិ. |
| ១៤០ | - | ថ្លា | [-អ´ម-] | តម្លា | - | ន. |
| ១៤១ | កិ. | ថ្លឹង | [-អ´ម-] | តម្លឹង | - | - |
| ១៤២ | គុ. | ថ្លុញ[៣] | [-អ´ម-] | តម្លុញ | - | ន. ; គុ. |
| ១៤៣ | ន. | ថ្លើង | [-អ´ម-] | តម្លើង[៤] | ដំឡើង[៥] | កិ. ; ន. ; គុ. |
| ១៤៤ | គុ. កិ.វិ ; ន. | ថ្លៃ | [-អ´ម-] | តម្លៃ | គ្មានព្យាង្គរាយ | ន. |
| ១៤៥ | កិ. | ថ្លោះ | [-អ´ម-] | តម្លោះ | - | កិ. |
| ១៤៦ | - | ថ្ងាយ | [-អ´ង-] | តង្ងាយ | - | - |
| ១៤៧ | កិ.; ន. | ទ្រ | [-អ៊´ម-] | ទម្រ | - | ន. |
| ១៤៨ | កិ. ; បុ.ស. ; ន. | ទ្រង់ | [-អ៊´ម-] | ទម្រង់ | - | ន. |
| ១៤៩ | គុ. ; កិ. | ទ្រម | [-អ៊´ម-] | ទម្រម | - | - |
| ១៥០ | កិ. ; កិ.វិ. | ទ្រឹង | [-អ៊´ម-] | ទម្រឹង | - | កិ. |

[៣] ពាក្យ *ថ្លុញ* នេះពុំមានជាមេពាក្យទេ តែមាននៅក្នុងសេចក្ដីពន្យល់របស់មេពាក្យ *តម្លុញ* ។

[៤] ពាក្យ *តម្លើង* នេះពុំមានជាមេពាក្យទេ តែមាននៅក្នុងសេចក្ដីពន្យល់របស់មេពាក្យ *ឡើត* ។

[៥] សម្ដេចព្រះសង្ឃរាជ ជួន ណាត ហាក់ដូចជាមិនចាត់ទុកថា ពាក្យ *ដំឡើង* នេះជាពាក្យក្លាយចេញពីពាក្យ *ថ្លើង* ទេ បើពុំនោះសោត ព្រះអង្គបានសរសេរ *តំឡើង* ទៅហើយ ។ បើពាក្យ *ដំឡើង* មិនមែនជាពាក្យកម្លាយកើតចេញពីពាក្យ *ថ្លើង* ទើបនោះ យើងត្រូវចាត់ទុកថាភាសាខ្មែរមានបុព្វបទ *ដំ* ផងទៀត សម្រាប់បង្កើតកិរិយាហេតុ *ដំឡើង* តែមួយគត់ (សូមមើលតារាងនៃការបង្កើតពាក្យជំពូកនេះ នៅក្នុងតារាងទី២ ខាងចុង) ។

| | | | | | | |
|---|---|---|---|---|---|---|
| ១៥១ | កិ. | ទ្រុឌ | [-អ៊ ́ម-] | ទម្រុឌ | គ្មានព្យាង្គរាយ | កិ. |
| ១៥២ | គុ. | ទ្រើស | [-អ៊ ́ម-] | ទម្រើស | - | កិ. ; គុ. |
| ១៥៣ | គុ. | ទ្រេត | [-អ៊ ́ម-] | ទម្រេត | - | កិ. |
| ១៥៤ | កិ. ; កិ.វិ. ; ន. | ទ្រេល | [-អ៊ ́ម-] | ទម្រេល | - | កិ. ; ន. |
| ១៥៥ | - | ទ្រោប | [-អ៊ ́ម-] | ទម្រោប | - | - |
| ១៥៦ | កិ. | ទ្រោម | [-អ៊ ́ម-] | ទម្រោម | - | - |
| ១៥៧ | - | ទ្រាំ | [-អ៊ ́ម-] | ទម្រាំ | - | និ. |
| ១៥៨ | គុ. | ធ្ងន់ | [-អ៊ ́ម-] | ទម្ងន់ | - | ន. |
| ១៥៩ | កិ. | ធ្លាក់ | [-អ៊ ́ន-] | ទន្លាក់ | - | ន. |
| ១៦០ | - | ធ្លាក់ | [-អ៊ ́ម-] | ទម្លាក់ | - | កិ. |
| ១៦១ | និ. | ធ្លាប់ | [-អ៊ ́ម-] | ទម្លាប់ | - | កិ. ; ន. |
| ១៦២ | កិ. | ធ្លាយ | [-អ៊ ́ម-] | ទម្លាយ | - | កិ. |
| ១៦៣ | កិ. | ធ្លឹង | [-អ៊ ́ម-] | ទន្លឹង | - | ន. |
| ១៦៤ | គុ. ; កិ. ; កិ.វិ. | ធ្លុះ | [-អ៊ ́ម-] | ទម្លុះ | - | កិ. |
| ១៦៥ | កិ. | ប្តឹង | [-អ ́ណ-] | បណ្តឹង | - | ន. |
| ១៦៦ | - | ប្រាប | [-អ ́ម-] | បម្រាប | - | - |
| ១៦៧ | - | ប្រាប់ | [-អ ́ម-] | បម្រាប់ | - | - |
| ១៦៨ | - | ប្រាម | [-អ ́ម-] | បម្រាម | - | កិ. |
| ១៦៩ | - | ប្រាស | [-អ ́ង-] | បង្រាស | - | - |
| ១៧០ | - | ប្រាស | [-អ ́ម-] | បម្រាស | - | - |
| ១៧១ | ប. | ប្រាស់ | [-អ ́ម-] | បម្រាស់ | - | ប. |
| ១៧២ | កិ. | ប្រឹង | [-អ ́ម-] | បម្រឹង | - | ន. |
| ១៧៣ | - | ប្រុង | [-អ ́ម-] | បម្រុង | - | កិ. ; គុ. |
| ១៧៤ | - | ប្រើ | [-អ ́ម-] | បម្រើ | - | កិ. ; ន. |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧៥ | កិ. | ប្រោស | [-អ'ង-] | បង្រោស | គ្មានព្យាង្គរាយ | គុ. ; ន. |
| ១៧៦ | - | ប្រោស | [-អ'ម-] | បម្រោស | - | - |
| ១៧៧ | - | ប្រះ | [-អ'ង-] | បង្រះ | - | កិ. |
| | - | ប្រះ | [-អ'ម-] | បម្រះ | - | - |
| ១៧៨ | - | បួង | [-អ'ន-] | បន្ទួង | - | កិ. ; ន. |
| ១៧៩ | - | ផ្ញើ | [-អ'ញ-] | បញ្ញើ | - | ន. |
| ១៨០ | - | ផ្តាច់ | [-អ'ណ-] | បណ្តាច់ | - | កិ. |
| ១៨១ | - | ផ្តាំ | [-អ'ណ-] | បណ្តាំ | - | ន. |
| ១៨២ | - | ផ្តុំ | [-អ'ណ-] | បណ្តុំ | - | ន. |
| ១៨៣ | - | ផ្ទាប់ | [-អ'ន-] | បន្ទាប់ | - | គុ.; កិ.វិ. |
| ១៨៤ | - | ផ្ទារ | [-អ'ន-] | បន្ទារ | - | ន. |
| ១៨៥ | - | ផ្ទាល | [-អ'ន-] | បន្ទាល | - | កិ. |
| ១៨៦ | - | ផ្ទុក | [-អ'ន-] | បន្ទុក | - | ន. |
| ១៨៧ | - | ផ្ទាស់ | [-អ'ន-] | បន្ទាស់ | - | - |
| ១៨៨ | កិ.វិ. | ផ្តិច[៦] | [-អ'ន-] | បន្តិច | - | កិ. |
| ១៨៩ | កិ. | ផ្លៀក | [-អ'ន-] / [-អ៊'ន-] | បន្លៀក/ពន្លៀក | - | ន. |
| ១៩០ | - | ផ្សារ | [-អ'ន-] | បន្សារ | - | - |
| ១៩១ | កិ. ; គុ. | ភ្លឺ | [-អ'ន-] | ពន្លឺ | - | ន. |
| ១៩២ | គុ. | ល្អ | [-អ៊'ម-] | លម្អ | លំអ[៧] | ន. |
| ១៩៣ | - | ល្អាច | [-អ៊'ម-] | លម្អាច | លំអាច | - |

---

[៦] ពាក្យ *ផ្តិច* នេះមិនមានជាមេពាក្យក្នុងវចនានុក្រមទេ តែមាននៅក្នុងសេចក្តីពន្យល់របស់មេពាក្យ *តូច* ឬ *តូចៗ*។

[៧] នៅសម័យសម្តេចព្រះសង្ឃរាជ ជួន ណាត មានការសរសេរជាព្យាង្គរាយជាញឹកញាប់ចំពោះពាក្យមួយចំនួន ដូចេះ ព្រះអង្គក៏រក្សាទុកនូវអក្ខរាវិរុទ្ធនោះ ដើម្បីសម្រួលដល់សាធារណជនជំនាន់នោះ ប៉ុន្តែ ព្រះអង្គគ្រាន់តែបានបញ្ចូលពាក្យជិតពួកនោះក្នុងវចនានុក្រមតាមលំដាប់ពាក្យ ដោយឥតពន្យល់ន័យទេ ហើយ ព្រះអង្គបានបញ្ជូនទៅពាក្យដែលសរសេរជាព្យាង្គតម្រួតដើម្បីពន្យល់ន័យ ពីព្រោះ ព្រះអង្គសង្ឃឹមថា គេនឹងឈប់ប្រើព្យាង្គរាយនៅអនាគត (សូមអាន *និទាន* សម្រាប់បោះពុម្ពគ្រាទី៥ , ទំព័រឃ) ។

| | | | | | | |
|---|---|---|---|---|---|---|
| ១៩៤ | គុ. | ល្ហើយ | [-អ៊´ម-] | លម្ហើយ | លំហើយ | កិ. |
| ១៩៥ | ន. ; គុ. | ល្ហែ | [-អ៊´ម-] | លម្ហែ | លំហែ | - |
| ១៩៦ | គុ. ; កិ.វិ. | ល្ហ | [-អ៊´ម-] | លម្ហ | លំអ | ន. |
| ១៩៧ | គុ. | ល្ហក់ | [-អ៊´ម-] | លម្ហក់ | លំអក់ | កិ. |
| ១៩៨ | ន. | ល្ហង | [-អ៊´ម-] | លម្ហង | លំអង | ន. |
| ១៩៩ | គុ. ; ប. | ល្ហន់ | [-អ៊´ម-] | លម្ហន់ | លំអន់ | ប. |
| ២០០ | ន. | ល្ហាន | [-អ៊´ម-] | គ្មានព្យាង្គតម្រួត | លំអាន[៨] | ន. |
| ២០១ | គុ. ; កិ.វិ. | ល្ហិត | [-អ៊´ម-] | លម្ហិត | លំអិត | កិ. ; ន. |
| ២០២ | គុ. | ល្ហៀង | [-អ៊´ម-] | លម្ហៀង | លំអៀង | ន. |
| ២០៣ | គុ. ; កិ. | ស្កក | [-អ´ម-] | សម្កក | សំកក | កិ. ; ន. ; គុ. |
| ២០៤ | គុ. | ស្កុល | [-អ´ម-] | សម្កុល | សំកុល | គុ. |
| ២០៥ | - | ស្កួញ | [-អ´ម-] | សម្កួញ | សំកួញ | គុ. ; ន. |
| ២០៦ | គុ. ; ន. | ស្កូវ | [-អ´ម-] | សម្កូវ | សំកូវ | - |
| ២០៧ | គុ. | ស្គម | [-អ´ម-] | សម្គម | សំគម | - |
| ២០៨ | កិ. ; គុ | ស្គាល់ | [-អ´ម-] | សម្គាល់ | សំគាល់ | កិ. ; ន. |
| ២០៩ | គុ. | ស្គុល | [-អ´ម-] | សម្គុល | សំគុល | គុ. ; ន. |
| ២១០ | - | ស្គោក | [-អ´ម-] | សម្គោក | សំគោក | - |
| ២១១ | ប. | ស្គាំង | [-អ´ម-] | សម្គាំង | សំគាំង | ប. |
| ២១២ | គុ. | ស្ងាច | [-អ´ម-] | សម្ងាច | សំងាច | កិ. ; កិ.វិ. |
| ២១៣ | - | ស្ងាត់ | [-អ´ម-] | សម្ងាត់ | សំងាត់ | កិ. ; គុ. |
| ២១៤ | កិ. | ស្ងើច | [-អ´ម-] | សម្ងើច | សំងើច | ន. |

[៨] ពាក្យ *លំអាន* នេះមិនមានជាមេពាក្យក្នុងវចនានុក្រមទេ តែមាននៅក្នុងមេពាក្យ *ល្ហាន*។

| | | | | | | |
|---|---|---|---|---|---|---|
| ២១៥ | កិ.វិ ; គុ. | ស្វាញ | [-អ៉ម-] | សម្វាញ | គ្មានព្យាង្គរាយ | គុ. |
| ២១៦ | - | ស្វេញ | [-អ៉ម-] | សម្វេញ | - | - |
| ២១៧ | កិ. | ស្វែង | [-អ៉ម-] | សម្វែង | - | កិ. |
| ២១៨ | កិ. | ស្ដាប់ | [-អ៉ណ-] | សណ្ដាប់ | - | ន. ; កិ. |
| ២១៩ | - | ស្ដី | [-អ៉ម-] | សម្ដី | សំដី | ន. |
| ២២០ | កិ.វិ ; គុ. | ស្ដឹង | [-អ៉ម-] | សម្ដឹង | សំដឹង | កិ. |
| ២២១ | គុ. | ស្ដឹត | [-អ៉ម-] | សម្ដឹត | សំដឹត | គុ. ; ន. |
| ២២២ | កិ.វិ ; គុ. | ស្ដួក | [-អ៉ណ-] | សណ្ដួក | គ្មានព្យាង្គរាយ | កិ. |
| ២២៣ | - | ស្ដើង | [-អ៉ម-] | សម្ដើង | សំដើង | - |
| ២២៤ | កិ.វិ. | ស្ដែង | [-អ៉ម-] | សម្ដែង | សំដែង* | - |
| ២២៥ | កិ. | ស្ដោះ | [-អ៉ម-] | សម្ដោះ | សំដោះ | - |
| ២២៦ | គុ. | ស្ដូត | [-អ៉ម-] | សម្ដូត | សំដូត | គុ. ; ន. |
| ២២៧ | កិ.វិ. ; គុ. | ស្ដុល | [-អ៉ម-] | សម្ដុល | សំដុល | - |
| ២២៨ | កិ.វិ. | ស្ដោក | [-អ៉ម-] | សម្ដោក | សំតោក | កិ. |
| ២២៩ | គុ. | ស្ទក់ | [-អ៉ម-] | សម្ទក់ | សំទក់ | គុ. ; ន. |
| ២៣០ | កិ. | ស្ទង់ | [-អ៉ម-] | សម្ទង់ | សំទង់ | ន. |
| ២៣១ | គុ. ; កិ.វិ. | ស្ទល | [-អ៉ម-] | សម្ទល | សំទល | គុ. ; ន. |
| ២៣២ | គុ. | ស្ទាញ | [-អ៉ម-] | សម្ទាញ | សំទាញ | - |
| ២៣៣ | - | ស្ទឹក | [-អ៉ម-] | សម្ទឹក | សំទឹក | - |
| ២៣៤ | កិ. | ស្ទុះ | [-អ៉ម-] | សម្ទុះ | សំទុះ | ន. |
| ២៣៥ | - | ស្ទុះ | [-អ៉ន-] | សន្ទុះ | គ្មានព្យាង្គរាយ | - |
| ២៣៦ | - | ស្ទូង | [-អ៉ន-] | សន្ទូង | - | - |
| ២៣៧ | - | ស្ទូង | [-អ៉ម-] | សម្ទូង | សំទូង | - |
| ២៣៨ | គុ. | ស្ទើញ | [-អ៉ម-] | សម្ទើញ | សំទើញ | គុ. ; ន. |

| | | | | | | |
|---|---|---|---|---|---|---|
| ២៣៩ | កិ.វិ ; គុ. | ស្ទែល | [-អ´ម-] | សម្ទែល | សំទែល | - |
| ២៤០ | គុ. | ស្ទេះ | [-អ´ម-] | សម្ទេះ | សំទេះ | - |
| ២៤១ | គុ. | ស្ទេះ | [-អ´ន-] | សន្ទេះ | គ្មានព្យាង្គរាយ | គុ. ; ន. |
| ២៤២ | កិ. | ស្ទុះ | [-អ´ន-] | សន្ទុះ | - | ន. |
| ២៤៣ | ន. | ស្នា( ដៃ) | [-អ´ម-] | សម្នា( ដៃ) | សំណា( ដៃ) | - |
| ២៤៤ | - | ស្នាម | [-អ´ម-] | សម្នាម | សំណាម* | - |
| ២៤៥ | កិ. | ស្ពាយ | [-អ´ម-] | សម្ពាយ | សំពាយ | - |
| ២៤៦ | គុ. | ស្ពឹក | [-អ´ម-] | សម្ពឹក | សំពឹក | គុ. ; ន. |
| ២៤៧ | - | ស្ពៀត | [-អ´ម-] | សម្ពៀត | សំពៀត | ន. |
| ២៤៨ | - | ស្ពែះ | [-អ´ម-] | សម្ពែះ | សំពែះ | គុ. ; ន. |
| ២៤៩ | កិ. | ស្រក | [-អ´ម-] | សម្រក | គ្មានព្យាង្គរាយ | កិ. ; ន. |
| ២៥០ | - | ស្រក់ | [-អ´ម-] | សម្រក់ | - | កិ. |
| ២៥១ | - | ស្រង់ | [-អ´ម-] | សម្រង់ | - | ន. |
| ២៥២ | កិ. ; ប. | ស្រន់ | [-អ´ម-] | សម្រន់ | - | កិ. |
| ២៥៣ | គុ. ; កិ.វិ. | ស្រប | [-អ´ម-] | សម្រប | - | - |
| ២៥៤ | - | ស្រស់ | [-អ´ម-] | សម្រស់ | - | កិ. ; ន. |
| ២៥៥ | កិ. ; គុ. | ស្រាក | [-អ´ម-] | សម្រាក | - | កិ. |
| ២៥៦ | - | ស្រាត | [-អ´ម-] | សម្រាត | - | - |
| ២៥៧ | គុ. | ស្រាន្ត | [-អ´ម-] | សម្រាន្ត | - | កិ. ; គុ. |
| ២៥៨ | កិ.វិ. ; គុ. ; និ. | ស្រាប់ | [-អ´ម-] | សម្រាប់ | - | គុ. ; ន. |
| ២៥៩ | កិ. | ស្រាយ | [-អ´ម-] | សម្រាយ | - | ន. |
| ២៦០ | គុ. | ស្រាល | [-អ´ម-] | សម្រាល | - | កិ. |
| ២៦១ | កិ. | ស្រាស់ | [-អ´ម-] | សម្រាស់ | -- | ន. |
| ២៦២ | - | ស្រិត | [-អ´ម-] | សម្រិត | - | កិ. ; គុ. |

| | | | | | | |
|---|---|---|---|---|---|---|
| ២៦៣ | គុ. | ស្រិល | [-អ’ម-] | សម្រិល | គ្មានព្យាង្គរាយ | កិ. |
| ២៦៤ | - | ស្រុង | [-អ’ម-] | សម្រុង | - | ន. |
| ២៦៥ | កិ. ; គុ. | ស្រុញ | [-អ’ម-] | សម្រុញ | - | កិ. |
| ២៦៦ | កិ. | ស្រុត | [-អ’ម-] | សម្រុត | - | - |
| ២៦៧ | កិ.វិ. ; គុ. | ស្រុះ | [-អ’ម-] | សម្រុះ | - | - |
| ២៦៨ | កិ. | ស្រុះស្រួល | [-អ’ម-] | សម្រុះសម្រួល | - | - |
| ២៦៩ | - | ស្រួប | [-អ’ម-] | សម្រួប | - | ន. ; គុ. |
| ២៧០ | គុ. | ស្រួច | [-អ’ម-] | សម្រួច | - | កិ. |
| ២៧១ | - | ស្រួត | [-អ’ម-] | សម្រួត | - | - |
| ២៧២ | គុ. ; កិ.វិ. | ស្រួល | [-អ’ម-] | សម្រួល | - | - |
| ២៧៣ | កិ. | ស្រើប | [-អ’ម-] | សម្រើប | - | ន. ; កិ. |
| ២៧៤ | - | ស្រេក | [-អ’ម-] | សម្រេក | - | ន. |
| ២៧៥ | - | ស្រេច | [-អ’ម-] | សម្រេច | - | កិ. |
| ២៧៦ | កិ. ; ន. | ស្រេះ | [-អ’ម-] | សម្រេះ | - | ន. |
| ២៧៧ | កិ. | ស្រែក | [-អ’ម-] | សម្រែក | - | - |
| ២៧៨ | ន. | ស្រែង | [-អ’ម-] | សម្រែង | - | គុ. ; ន. |
| ២៧៩ | កិ. ; កិ.វិ. | ស្រោច | [-អ’ម-] | សម្រោច | - | - |
| ២៨០ | កិ. ; គុ. | ស្រោប | [-អ’ម-] | សម្រោប | - | ន. |
| ២៨១ | គុ. | ស្រាំង | [-អ’ម-] | សម្រាំង | - | កិ.វិ. |
| ២៨២ | កិ. | ស្លូ | [-អ’ម-] | សម្លូ | - | ន. |
| ២៨៣ | គុ. | ស្លក់ | [-អ’ម-] | សម្លក់ | - | កិ. |
| ២៨៤ | កិ. | ស្លន់ | [-អ’ម-] | ចន្លន់ | - | កិ.វិ. |
| ២៨៥ | គុ. | ស្លប | [-អ’ម-] | សម្លប | - | កិ. |
| ២៨៦ | ន. | ស្លាក | [-អ’ម-] | សម្លាក | - | ន. |

| | | | | | | |
|---|---|---|---|---|---|---|
| ២៨៧ | កិ. | ស្លាប់ | [-អ´ម-] | សម្លាប់ | គ្មានព្យាង្គរាយ | កិ. |
| ២៨៨ | ន. | ស្លឹក | [-អ´ន-] | សន្លឹក | - | ន. |
| ២៨៩ | កិ.វិ. | ស្លឹង | [-អ´ម-] | សម្លឹង | - | ន. |
| ២៩០ | ប. | ស្លុក | [-អ´ម-] | សម្លុក | - | ប. |
| ២៩១ | កិ.; កិ.វិ.; គុ. | ស្លុត | [-អ´ម-] | សម្លុត | - | កិ. |
| ២៩២ | គុ. | ស្លួយ | [-អ´ម-] | សម្លួយ | - | កិ. ; កិ.វិ. |
| ២៩៣ | - | ស្លូត | [-អ´ម-] | សម្លូត | - | ន. |
| ២៩៤ | - | ស្លើត | [-អ´ម-] | សម្លើត | - | គុ. ; ន. |
| ២៩៥ | - | ស្លែវ | [-អ´ម-] | សម្លែវ | - | - |
| ២៩៦ | ន. | ស្លោក | [-អ´ម-] | សម្លោក | - | ន. |
| ២៩៧ | កិ. | ស្ងោយ | [-អ´ង-] | សង្ងោយ | - | - |
| ២៩៨ | គុ. | ស្អក | [-អ´ម-] | សម្អក | សំអក | គុ. ; ន. |
| ២៩៩ | កិ. | ស្អប់ | [-អ´ម-] | សម្អប់ | សំអប់ | - |
| ៣០០ | - | ស្អាង | [-អ´ម-] | សម្អាង | សំអាង | - |
| ៣០១ | គុ. ; កិ.វិ. | ស្អាត | [-អ´ម-] | សម្អាត | សំអាត | កិ. |
| ៣០២ | គុ. | ស្អិត | [-អ´ម-] | សម្អិត | សំអិត/សំឥត | ប. ; ន. |
| ៣០៣ | គុ. ; កិ.វិ. | ស្អុយ | [-អ´ម-] | សម្អុយ | សំអុយ | ន. |

# តារាងសរុប បង្ហាញការបង្កើតពាក្យ សម្គាល់កិរិយាហេតុ

(រៀបរៀងដោយ បណ្ឌិត ព្រុំ ម៉ល់)

<u>បុព្វយោគ</u> :

១- គប្បីយើងប្រើវាក្យសព្ទបារាំងអមវាក្យសព្ទខ្មែរសិន ពីព្រោះ វាក្យសព្ទខ្មែរមិនទាន់មានឯកភាពរវាងអ្នកប្រើ ហើយ គួររំលឹកថា : អព្ភាសបទ (affixes) អាចជា បុព្វបទ (préfixes) ឬ អន្តោបទ (infixes) ឬ បច្ឆិមបទ (suffixes) ។

២- រូបសព្ទ (morphème) /ប៉-/ អាចចេញជាកាឡរូបសព្ទ (allomorphes) [ប៉-] , [ព-] , [ផ-] , [ភ-] , [ប´ង-/ព´ង-] , [ប´ញ-/ព´ញ-] , [ប´ណ-/ព´ណ-] , [ប´ន-/ព´ន-] , [ប´ម-> ប៉-/ព´ម-> ពំ-] ទៅតាមបរិបទ ។

៣- គួររំលឹកថា ការប្រើព្យញ្ជនៈ *ប* ឬ *ព* ខាងដើមនៃកាឡរូបសព្ទនានា គឺសម្របទៅតាមមូលភាព អ/អ៊ ដែលមានក្នុងភាសាខ្មែរ។

៤- សញ្ញា (´) មិនមែនជាសញ្ញាបន្តក់ទេ គឺជាសញ្ញាប្រើក្នុងសូរវិទ្យា សម្រាប់សម្គាល់ស្រះខ្លី។

*<u>ប្រយ័ត្ន</u> . សញ្ញា/.../ និង សញ្ញា [...] មានន័យខុសគ្នា : សញ្ញា/.../ កត់ត្រារូបសព្ទ , សញ្ញា [...] កត់ត្រាកាឡរូបសព្ទ) ។*

| ល.រ. | ពាក្យកម្លាយ / ពាក្យដើម | ១ | | ២ | | ៣ | |
|---|---|---|---|---|---|---|---|
| | | រូបសព្ទ /ប៉-/ និង កាឡរូបសព្ទនានា | កិរិយាហេតុ | រូបសព្ទ /រំ-/ និង ឯកកាឡរូបសព្ទ | កិរិយាហេតុ | រូបសព្ទ /-អ´ɔ/អ៊´ɔ-/ និង ឯកកាឡរូបសព្ទ | កិរិយាហេតុ |
| ១ | កិល | ០ | ០ | [រំ-] | រំកិល | ០ | ០ |
| ២ | កើត | [ប´ង-] | បង្កើត | ០ | ០ | ០ | ០ |
| ៣ | ខាន | ០ | ០ | [រំ-] | រំខាន | ០ | ០ |
| ៤ | ខំ | [ប´ង-] | បង្ខំ | ០ | ០ | ០ | ០ |
| ៥ | គេច | ប´ង-] | បង្គេច | ០ | ០ | ០ | ០ |
| ៦ | គាប់ | [ផ-] | ផ្គាប់ | ០ | ០ | ០ | ០ |
| ៧ | ងើយ | [ភ-] | ភ្ញើយ | ០ | ០ | ០ | ០ |
| ៨ | ចុក | [ប´ញ-] | បញ្ចុក | ០ | ០ | ០ | ០ |
| ៩ | ជាប់ | [ភ-] | ភ្ជាប់ | ០ | ០ | ០ | ០ |
| ១១ | ជិះ | [ប´ញ-] | បញ្ជិះ | ០ | ០ | ០ | ០ |
| ១២ | ឈឺ | [ប´ញ-] | បញ្ឈឺ | ០ | ០ | ០ | ០ |
| ១៣ | ញាស់ | [ភ-] | ភ្ញាស់ | ០ | ០ | ០ | ០ |
| ១៤ | ដឹង | [ប៉-] | ប្ដឹង | ០ | ០ | ០ | ០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥ | តូច | [ប'ន-] | បន្តូច | ០ | ០ | ០ | ០ |
| ១៦ | ថយ | [ប'ន-] | បន្ថយ | ០ | ០ | ០ | ០ |
| ១៧ | ទន់ | [ប'ន-] | បន្ទន់ | ០ | ០ | ០ | ០ |
| ១៨ | ទឹម | [ផ-] | ផ្ទឹម | ០ | ០ | ០ | ០ |
| ១៩ | ធំ | [ប'ន-] | បន្ធំ | ០ | ០ | ០ | ០ |
| ២០ | បាក់ | [ប'ម-] | បំបាក់ | ០ | ០ | ០ | ០ |
| ២១ | ផឹក | [ប'ម-] | បំផឹក | ០ | ០ | ០ | ០ |
| ២២ | ពើង | [ប'ម-] | បំពើង | ០ | ០ | ០ | ០ |
| ២៣ | ភ័យ | [ប'ម-] | បំភ័យ | ០ | ០ | ០ | ០ |
| ២៤ | មូល | [ប៉-] | ប្មូល ><br>ប្រមូល | ០ | ០ | ០ | ០ |
| ២៥ | យល់ | [ព'ន-] | ពន្យល់ | ០ | ០ | ០ | ០ |
| ២៦ | រងាប់ | ០ | ០ | ០ | ០ | [-អ៊ិ'ម-] | រំងាប់ |
| ២៧ | រដោះ | ០ | ០ | ០ | ០ | [-អ៊ិ'ម-] | រំដោះ |
| ២៨ | រលត់ | ០ | ០ | ០ | ០ | [-អ៊ិ'ម-] | រំលត់ |
| ២៩ | រាប | [ប៉-] | ប្រាប | ០ | ០ | ០ | ០ |
| | រាប | [ព'ន-] | ពង្រាប | ០ | ០ | ០ | ០ |
| ៣០ | វក់ | [ព'ន-] | ពង្វក់ | ០ | ០ | ០ | ០ |
| ៣១ | ឮ | [ប'ន-] | បន្លឺ | ០ | ០ | ០ | ០ |
| ៣២ | លិច | [ព'ន-] | ពន្លិច | ០ | ០ | ០ | ០ |
| ៣៣ | លេប | ០ | ០ | [រំ-] | រំលេប | ០ | ០ |
| ៣៤ | លើស | [ព'ន-] | ពន្លើស | ០ | ០ | ០ | ០ |
| ៣៥ | សាយ | [ផ-] | ផ្សាយ | ០ | ០ | ០ | ០ |
| ៣៦ | ស៊ី | [ប'ន-] | បន្ស៊ី | ០ | ០ | ០ | ០ |
| ៣៧ | សោះ | ០ | ០ | [រំ-] | រំសោះ | ០ | ០ |
| ៣៨ | ហាត់ | [ប'ង-] | បង្ហាត់ | ០ | ០ | ០ | ០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៩ | ហួត | ० | ० | [រំ-] | រំហួត | ० | ० |
| ៤០ | អាប់ | [ផ-] | ផ្អាប់ | ० | ० | ० | ० |
| | អាប់ | [ប´ង-] | បង្អាប់ | ० | ० | ० | ० |
| ៤១ | ខ្លាច | [ប´ន-] | បន់ខ្លាច > បន្លាច | ० | ० | ० | ० |
| ៤២ | គ្រប់ | [ប´ង-] | បង្គ្រប់ | ० | ० | [-អ៊ិ´ម-] | គម្រប់ |
| ៤៣ | ឃ្លាត | [ប´ង-] | បង់ឃ្លាត | ० | ० | ० | ० |
| ៤៤ | ឆ្លង | ० | ० | ० | ० | [-អ´ម-] | ចម្លង |
| ៤៥ | ថ្លើង | ० | ० | ० | ० | [-អ´ម-] | តម្លើង[១] |
| ៤៦ | ធ្លុះ | ० | ० | ० | ० | [-អ៊ិ´ម-] | ទម្លុះ |
| ៤៧ | ព្រាត់ | [ប´ម-] | បំព្រាត់ | ० | ० | ० | ० |
| ៤៨ | ភ្លឺ | [ប´ម-] | បំភ្លឺ | ० | ० | ० | ० |
| ៤៩ | ល្អ | ० | ० | ० | ० | [-អ៊ិ´ម-] | លម្អ |

<u>សង្កេត</u> :

(១) - អន្តេបទ /-អ!ម-/-អ៊ិ!ម-/ ប្រើតែជាមួយពាក្យដើមដែលកើតពីកន្សោមព្យញ្ជនៈ (ព្យាង្គតម្រួត) ប៉ុន្តែ ទម្រង់ /រ+ព្យញ្ជនៈ/ ក៏អាចចាត់ទុកជាកន្សោមព្យញ្ជនៈបានដែរ ពីព្រោះ មកពីអក្សរ "រ" រៀវពេកបានជាបុព្វបុរសខ្មែរមិនសរសេរតម្រួត : យើងអាចផ្អែកលើការប្រើប្រាស់អន្តេបទ /-ប-/ សម្គាល់លទ្ធផល/អំពើ ដើម្បីបង្ហាញឱ្យឃើញថា អំណះអំណាងរបស់យើងមានភាពសមស្រប :

- លាស់ + /-ប-/ > ល្បាស់ : លោកទុកព្យាង្គតម្រួត ពីព្រោះ ព្យញ្ជនៈ *ល* ឥតមានភាពរៀវឆ្ការ ;
- រៀប + /-ប-/ > រៀប > របៀប : លោកយកព្យាង្គតម្រួតចេញ ពីព្រោះ ព្យញ្ជនៈ *រ* មានភាពរៀវឆ្ការ ។

ដោយហេតុថា ទម្រង់ /រ+ព្យញ្ជនៈ/ ត្រូវបានចាត់ទុកដូចព្យាង្គតម្រួត ដូច្នេះហើយ ទើបបុព្វបុរសខ្មែរបានទាញកម្លាយ ដូចនេះ : *រងាប់ > រំងប់ , រលត់ > រំលាត់* ,... ដូច *ធ្លុះ > ទម្លុះ , ឆ្លង > ចម្លង* ,... ដែរ ។

២ ) - ជាមួយពាក្យដើមកើតពីកន្សោមព្យញ្ជនៈ (ព្យាង្គតម្រួត) គេក៏អាចប្រើបុព្វបទ /ប´ខ-/ ដែរ , ឧ. គ្រប់ > បង្គ្រប់ ។ បើគេអាចធ្វើឱកាសកម្មនៃការប្រើប្រាស់បុព្វបទ /ប´ខ-/ គេអាច (សម្រាប់កិរិយាហេតុ) ឈប់ប្រើអន្តេបទ [-អ´ម-] ឬ [-អ៊ិ´ម-] ហើយទុកវាសម្រាប់តែពាក្យកម្លាយសម្គាល់លទ្ធផល/អំពើ ដើម្បីចៀសវាងការប្រើអព្ភាសបទក្នុងភាពច្របូកច្របល់ ។

(៣) - ចំពោះការបង្កើតពាក្យកម្លាយសម្គាល់កិរិយាហេតុ បុព្វបុរសខ្មែរក៏បានប្រើអាគមដែរ (មូល > បួល > ប្រមូល) ដូចក្នុងពាក្យកម្លាយសម្គាល់ឧបករណ៍ (ជង់ > ជ្នង់ > ជ្រនង់) និង ដូចក្នុងពាក្យកម្លាយសម្គាល់ភ្នាក់ងារ (បាញ់ > ប្នាញ់ > ប្រមាញ់) , ... ។

---

១ : ក្នុងវចនានុក្រមសម្ដេច ជួន ណាត ពាក្យ *តម្លើង* មិនមែនជាមេពាក្យទេ តែជាពាក្យដែលគេប្រទះឃើញក្នុងការពន្យល់ពាក្យ *ថ្កើត* ។ ពាក្យដែលជាមេពាក្យក្នុងវចនានុក្រមនេះ គឺពាក្យ *ដំឡើង* ដែលសម្ដេចព្រះសង្ឃរាជហាក់ដូចជាមិនបានចាត់ទុកថាជាប់ជៅសន្តានជាមួយពាក្យ *ថ្លើង* ទេ។ ក្នុងករណីនេះ កម្ទេចពាក្យ *ដំ* ត្រូវចាត់ទុកជាបុព្វបទមួយម្នាក់ឯងសម្រាប់បង្កើតកិរិយាហេតុ *ដំឡើង* តែមួយគត់។ ខ្ញុំគិតថាពាក្យ *តម្លើង* ជាពាក្យក្លាយចេញពីពាក្យ *ថ្លើង* ហើយ បើគេចង់សរសេរជាព្យាង្គរាយ គប្បីគេសរសេរ *តំឡើង* វិញ។

# Development of Minority Languages in Cambodia

Presentation of Dr.IV Chan, Director of National Language Institute
of RAC, in the International Conference on National Language Policy,
July 4-5, 2008, Bangkok, Thailand

---------

Cambodia has a population of over 13 million people. Besides the national language Khmer whose speakers make up 93% of the population, there are approximately 23 Austro-Asiatic, Mon-Khmer languages with about 94.278 speakers' total. There are also 3 Austronesian languages whose speakers make up about 214.418 speakers total.

Ethnic Groups :

| N° | Ethnic Name | Population | % | Province |
|---|---|---|---|---|
| 1 | Tumpoun | 21,189 | 3.78 | Ratanakiri, Mondulkiri |
| 2 | Phnong | 19,000 | 3.13 | Ratanakiri, Mon., Steng Treng |
| 3 | Kouy | 15,771 | 2.78 | Preah Vihear, Kampong Thom |
| 4 | Jarai | 13,969 | 2.53 | Ratanakiri |
| 5 | Kreung | 12,711 | 1.07 | Ratanakiri |
| 6 | Brao | 5,379 | 1.05 | Ratanakiri, Steng Treng |
| 7 | Kravet | 5,318 | 1.04 | Ratanakiri (Veunsai), Steng Treng |
| 8 | Stieng | 5,234 | 0.79 | Kratie (Snoul), Mon.(Keo Seyma) |
| 9 | Kraol | 2,667 | 0.53 | Kratie, Mon. (Koh Nyek) |

| | | | | |
|---|---|---|---|---|
| 10 | Mel | 2,178 | 0.43 | Kratie |
| 11 | Kachac | 2,172 | 0.43 | Ratanakiri |
| 12 | Robel | 1,640 | 0.32 | Ratanakiri |
| 13 | Poar | 1,440 | 0.28 | Pursat, Koh Kong |
| 14 | Suoy | 1,158 | 0.23 | Kampong Speu |
| 15 | Thmaun | 523 | 0.10 | Kratie, Mondulkiri |
| 16 | Rhade | 12 | 0.00 | Mondulkiri |
| 17 | Lun | 464 | 0.09 | Ratanakiri (Taveng), Steng Treng |
| 18 | Lemourn | 335 | 0.07 | Pursat |
| 19 | Poang | 260 | 0.05 | Mondulkiri |
| 20 | Kanin | 150 | 0.02 | Mondulkiri |
| 21 | Arach | 100 | 0.01 | Mondulkiri |
| 22 | Roong | 5 | 0.00 | Mondulkiri |
| 23 | Saoch | 175 | 0.03 | Sihanouk Ville, Pursat |
| 24 | Kola | 31 | 0.00 | Paylin |
| 25 | Khmer Khe | 1,600 | ... | Steng Treng (Siempang) |
| Total | | 113.481 | | |

Source : Ministry of Interior in 1996

It is estimated that 90% of the world's languages may be replaced by more dominant languages by the end of the 21st century. The same statistic

may be true for the languages spoken in Cambodia. Several are in danger of extinction. For example, 5 of the 6 language varieties in the Pearic grouping are spoken only in Cambodia and may be in such danger. There is urgency to act before this becomes a reality!

## NATIONAL POLICY

In regard to national policy Cambodia's first two development strategies are particularly relevant to the situation of ethnic minorities:

1-Reduce poverty and starvation

2-Provide all citizens with free basic education for at least 9 years.

There is also a national policy on the development of ethnic minorities which provides the opportunity for many other interventions including:

-Establish cultural center(s) of ethnic minority communities, with their consent, to study and protect their culture including : customs, traditions, language, knowledge, point of view, values, belief system, handicrafts, weaving, architecture, textiles and other arts with the aim of providing education, knowledge, experiences and information related to the development of the ethnic minorities.

-Develop vocational training for ethnic minorities, especially women and those who are not literate, by providing and expanding basic education and vocational training.

-Develop the academic curriculum which useful to the social setting.

-Include the culture, belief and customs of ethnic minorities in the

academic curriculum.

## THE INSTITUTE OF NATIONAL LANGUAGE

The Institute of National Language (INL) is one of 5 institutes in tl Royal Academy of Cambodia. The Mission of the INL is to research ar develop the Khmer language and the minority languages of Cambodia. Tl INL has 4 departments: epigraphy, linguistics, lexicography, and literatur Our research is published twice a year in the Bulletin of the Institute ( National Language. In addition to this, we cooperate with other researche and organizations to publish other special publications such as Parlons Kı by Dr. Jacques Rongier and the Tampuan Khmer English Dictionaı published in cooperation with EMU International.

The INL has cooperated with the MoEYS and ICC (an internation NGO) to develop orthographies (writing systems) for several minorit languages. These orthographies make use of the Khmer script. To date, writing systems have been developed for the following languages: Bunon Tampuan and Brao/Krung/Kavet. In the latter case one orthography is bein used by three closely related languages. Our involvement in the process c orthography development has three stages: 1) Examination of the phonolog of the minority language and examination of the proposed writing system, 2 Compromise between the phonology of the minority language and the Khme script. This is done in cooperation with the local community, 3) Afte compromise has been reached, the INL approves that the minority writin system conforms with the proper use of the Khmer script and is suitable fo use in education and other domains. We are currently in the process oı

valuating an orthography of the Kuy language.

It is our hope that by learning to read and write in their mother tongue irst the ethnic minority peoples of Cambodia will find it easier to go on to earn to read and write in the national language. In this way they can enjoy all he benefits of participation in the nation of Cambodia.

## Reference


គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច របស់រាជរដ្ឋាភិបាលកម្ពុជា , មករា ២០០៧

ICC-Rider Project, ICC's paper exhibited in International Conference, in Bangkok (1-3 July 2008)

Language of Cambodia, Ethnologue.com, (2008)

Statistic of Ministry of Interior (1996)

សាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណព្វ**
-ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា
-អនុប្រធានវិទ្យាស្ថានភាសាជាតិ
-អនុប្រធានគណៈកម្មការបច្ចេកទេសទី២
នៃគណៈកម្មាធិការជាតិភាសាខ្មែរ
-សមាជិកគណៈកម្មការបណ្ឌិតសភា
អនុម័តពាក្យច្បាប់

# ជុំវិញបញ្ហាអក្ខរាវិរុទ្ធខ្មែរ

បច្ចុប្បន្ននេះ បញ្ហាអក្ខរាវិរុទ្ធបានចោទជាសំណួរមួយយ៉ាងជ្រៅនៅក្នុងសំណេរពាក្យខ្មែរ។ បទអន្តរាគមន៍របស់ខ្ញុំនឹងបង្ហាញជូនពីប្រភពនិងពីមធ្យោបាយដើម្បីជៀសវាងវិបត្តិនេះ។ ខ្ញុំនឹងសាកល្បងធ្វើសំណើស្ដីពីនយោបាយនៃភាសាប្រយោជន៍នឹងធ្វើអោយមានស្ថេរភាពនៃអក្ខរាវិរុទ្ធខ្មែរ។

អត្ថបទដែលនឹងលើកមកបង្ហាញជូននេះ គឺប្រសូតចេញពីការស្រាវជ្រាវមួយដែលផ្អែកទៅលើការវិភាគតាមបែបភាសាវិទ្យានិងមានបំណងពង្រឹងនិងអភិរក្សអក្សរសាស្ត្រនិងភាសាជាតិយើង។

## ១.ផ្ដើម

នៅក្នុងកំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ ភាសាខ្មែរមានការវិវត្តគួរអោយកត់សម្គាល់។ ខ្ញុំពុំយល់ស្របទេថា ភាសាខ្មែរកំពុងតែធ្លាក់ចុះអន់ថយនោះ។ ពិតមែនតែថា មានវោហាជនមួយចំនួនអានពាក្យខ្មែរពុំត្រឹមត្រូវតាមអក្ខរាវិរុទ្ធ ឬ ស្មេរមួយចំនួនសរសេរពាក្យក្នុងភាសាខ្មែរខុសអក្ខរាវិរុទ្ធក្ដី ក៏យើងមិនត្រូវសន្និដ្ឋានថា ភាសាខ្មែរកំពុងធ្លាក់ចុះនោះទេ។ ជាការពិតណាស់ មានពិធីករ ពិធីការិនីនៃស្ថានីយវិទ្យុនិងទូរទស្សន៍មួយចំនួនប្រើប្រាស់ពាក្យខ្មែរខុសវេយ្យាករណ៍ ខុសបរិបទ តែយើងមិនត្រូវនាំគ្នាស្រែកប្រកាសថា ភាសាខ្មែរកំពុងតែចុះអន់ថយនោះទេ ត្បិតអីអ្នកទាំងនោះមិនសូវបានរៀនសូត្រជ្រៅជ្រះពីភាសាខ្មែរ ហើយក៏មិនមែនជាអ្នកតំណាងតែម្នាក់គត់នៃភាពរុងរឿងផ្នែកភាសាខ្មែរនោះដែរ។ នៅប្រទេសដទៃទៀតក្នុងពិភពលោក ក៏មានស្ថានីយវិទ្យុមួយចំនួនដែលបង្កើតកម្មវិធីសន្ទនាឬជជែកកំសាន្ត

ដើម្បីបង្កើតបរិយាកាសមួយដែលគេយល់ថាសម្រាប់ការរីករាយបន្ធូរអារម្មណ៍នោះ។ នៅក្នុងកម្មវិធីទាំងនោះ ក៏មានពាក្យលេបខាយលេងសើចដែរ តែគេមិនដែលចោទថាភាសាគេកំពុងធ្លាក់ចុះនោះទេ ព្រោះវាជារឿងលេងសើច។ ប៉ុន្តែ បើគេយល់ថា ការលេងសើចនោះសមរម្យឬពុំសមរម្យនោះវាជារឿងមួយដោយឡែក សូមកុំភ្ជាប់ទៅនឹងភាសានិងអក្សរសាស្ត្រឱ្យសោះ។

ប្រសិនបើវិទ្យុ និង ទូរទស្សន៍នីមួយៗយល់ព្រមផ្តល់ប្រាក់កំរៃខ្លះដល់វាគ្មិនផ្នែកភាសាវិទ្យា និងអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យគាត់មកបកស្រាយពន្យល់ហេតុផលនៃការប្រើប្រាស់ពាក្យនៅក្នុងភាសាខ្មែរដូចដែលស្ថានីយវិទ្យុនិងស្ថានីយទូរទស្សន៍ទាំងនោះបានផ្តល់ជូនពិធីករ ពិធីការិនីនោះ ម្ល៉េះសមមហាជនទាំងអស់នឹងបានដឹងថាភាសានិងអក្សរសាស្ត្រខ្មែរកំពុងរីកចម្រើនទៅវិញ។

ជនជាតិខ្មែរច្រើនណាស់មានឱកាសបានអាន និង ស្តាប់ការលេងសើចតាមបណ្តាញព័ត៌មាននានា តែ គេសឹងតែគ្មានភ័ព្វសំណាងបានស្តាប់សេចក្តីវិភាគទៅលើភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរទេ។ តាមពិតទៅ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានការបណ្តុះបណ្តាលការស្រាវជ្រាវយ៉ាងសកម្មខាងផ្នែកភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរនៅក្នុងដេប៉ាតឺម៉ង់ភាសាវិទ្យា។ នៅក្នុងគ្រឹះស្ថានដទៃទៀតក៏មានការស្រាវជ្រាវច្រើនណាស់ដែរ គ្រាន់តែយើងមិនសូវមានលទ្ធភាពផ្សព្វផ្សាយពីស្នាដៃទាំងនោះតែប៉ុណ្ណោះ។

នៅក្នុងបទអន្តរាគមន៍នេះ ខ្ញុំសូមទុកកំហុសឆ្គងផ្នែកសំណួរនិងផ្នែកបរិបទមួយដោយឡែកសិនចុះ ដោយខ្ញុំសូមជូនការកត់សម្គាល់មួយចំនួនទៅលើបញ្ហាអក្ខរាវិរុទ្ធតែប៉ុណ្ណោះ។

## ២.មូលហេតុដែលបណ្តាលឱ្យមានកំហុសអក្ខរាវិរុទ្ធនាពេលបច្ចុប្បន្ន

ដូចយើងបានដឹងនិងឃើញស្រាប់ហើយថា ក្នុងពេលបច្ចុប្បន្ននេះ មានកំហុសអក្ខរាវិរុទ្ធគួរឱ្យកត់សម្គាល់នៅក្នុងអត្ថបទសៀវភៅសិក្សា សារព័ត៌មាន ទស្សនាវដ្តី ចំរៀងកាយវិការ និងទូរបទ។ល។

ខ្ញុំបានពិចារណាទៅលើកំហុសអក្ខរាវិរុទ្ធ ដែលខ្ញុំបានដកស្រង់ចេញពីប្រភពផ្សេងៗហើយបានធ្វើចំណាត់ថ្នាក់ស្តីពីប្រភេទនៃកំហុសទាំងនោះដូចខាងក្រោម។

### ២.១.ការសរសេរពាក្យខុសដោយសារស្មេរពុំស្គាល់ពីឫសរបស់ពាក្យនោះ

នៅក្នុងពង្រាងច្បាប់មួយគេបានប្រើពាក្យ "រំលស់បំណុល" ដោយសរសេរខុសអក្ខរាវិរុទ្ធ។ នៅក្នុងពង្រាងច្បាប់នោះ គេបានសរសេរ *រម្លោះ* ដែលការសរសេរបែបនេះគឺខុសអក្ខរាវិរុទ្ធទាំងស្រុង។ តាមពិតពាក្យថា រំលស់ គឺមកពីឫស លស់ ហេតុនេះ គេគ្មានហេតុផលណាមួយដែលតម្រូវឱ្យសរសេរជា រម្លោះ ឬ រំលោះនោះទេ។

### ២.២.ការសរសេរពាក្យខុសដោយសារស្មេរមិនស្គាល់ច្បាស់ពីច្បាប់ទំនាញសូរ

ខ្ញុំសូមលើកបញ្ហាមកបង្ហាញជូន ដែលឆ្លុះឱ្យឃើញពីភាពច្របូកច្របល់នៅក្នុងការសរសេរពាក្យខ្មែរ។ កំហុសឆ្គងបណ្ដាលមកពីស្មេរមិនស្គាល់ច្បាស់ពីច្បាប់ទំនាញសូរផងនិងពីឫសរបស់ពាក្យផង។ ជាក់ស្ដែង ពាក្យ *ត្រឡប់* សៀវភៅខ្លះសរសេរ *ត្រលប់* ខ្លះទៀតថាសរសេរ *ត្រលប់* ក៏បាន *ត្រឡប់* ក៏បាន។ តែតាមខ្ញុំយល់ ពាក្យនេះគួរតែសរសេរ *ត្រឡប់* បែបនេះទើបត្រូវត្បិតអីវាជាពាក្យដែលក្លាយចេញពីពាក្យ *ឡប់* ដែលមានន័យថា *បកមកវិញ* ផ្សំនឹងផ្នត់ដើម *ត្រ* ។ ការសរសេរ ត្រលប់ ដូចនៅក្នុងសៀវភៅរៀនភាសាខ្មែរថ្នាក់ទីពីរ (ទំព័រទី១៩) របស់ក្រសួងអប់រំ យុវជន និង កីឡានោះ គឺខុសហើយព្រោះវាមិនមែនជាពាក្យក្លាយមកពីពាក្យ *លប់* នោះទេ។ ប្រការដែលនាំឱ្យគេសរសេរខុសនោះ ព្រោះត្អែងសៀវភៅនោះយល់ច្រឡំពីច្បាប់ទំនាញសូរក្នុងភាសាខ្មែរ ដែលជាក្បួនមួយត្រូវបានគេអនុវត្តនៅក្នុងករណីផ្សេងទៅវិញ។ ម្យ៉ាងទៀត ត្អែងអាចសំអាងទៅលើវចនានុក្រមដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាឆ្នាំ១៩៦៧ ដែលអនុញ្ញាតដោយគ្មានហេតុផលឱ្យសរសេរ *ត្រលប់* បែបនេះក៏បាន។

### ២.៣.ការសរសេរពាក្យខុសដែលបណ្ដាលមកពីការពុំយល់ច្បាស់ពីគោលការណ៍សំរាយនិងតម្រួត

នៅក្នុងសៀវភៅសិក្សាភាសាខ្មែរថ្នាក់ទី៨និងទី៩ បោះពុម្ពដោយក្រសួងអប់រំ យុវជន និង កីឡា គេបានសរសេរពាក្យ *ប៉ុណ្ណោះ* ដោយប្ដូរមកសរសេរតាមបែបរាយព្យាង្គ *ប៉ុននោះ* ទៅវិញ។ ការប្ដូរនេះដោយត្អែងអត្ថបទឬអ្នកត្រួតពិនិត្យសៀវភៅទាំងនោះយល់ឃើញថា ត្រូវតែសរសេររាយព្យាង្គទើបងាយស្រួលឬឆាប់ចងចាំ។ ខ្ញុំបរល់ឃើញថា ការប្ដូរនេះខុសទាំងស្រុង ដោយហេតុថា *ប៉ុណ្ណោះ* និង *ប៉ុននោះ* ជាពាក្យពីរផ្សេងគ្នាមិនអាចជំនួសគ្នាបាននោះទេ។ នៅឆ្នាំ២០០០ មានមន្ត្រីជាន់ខ្ពស់ក្រសួងអប់រំ យុវជននិងកីឡាម្នាក់បានពន្យល់ប្រាប់ខ្ញុំថា គាត់តម្រូវឱ្យសរសេរពាក្យ *ប៉ុណ្ណោះ* ជាព្យាង្គរាយ ព្រោះលោកចង់លុបបំបាត់ការប្រកបសូរនឹង ណ និងចង់តម្រូវឱ្យគេសរសេររាយព្យាង្គ ហើយម្យ៉ាងទៀត លោកថាគោរពតាមច្បាប់ទំនាញសូរ។

ពេលនោះខ្ញុំបានជម្រាបលោកថា ការកែប្រែបែបនេះគឺខុសហើយ ព្រោះពាក្យទាំងពីរនេះ មានន័យខុសគ្នាទាំងស្រុង។ ខ្ញុំបានជម្រាបលោកថា ពាក្យទាំងពីរប្រើក្នុងបរិបទខុសគ្នា ហើយច្បាប់ទំនាញសូរក៏ពុំអាចអនុវត្តចំពោះពាក្យ *ប៉ុននោះ* បានដែរដោយហេតុថា វាជាពាក្យពីរផ្សេងគ្នា ពោលគឺពុំមែនជាពាក្យមួយដែលមានពីរព្យាង្គនោះទេ។ ទីបញ្ចប់ លោកក៏បានទទួលស្គាល់ហើយទទួលយកសេចក្ដីពន្យល់របស់ខ្ញុំទៅ។

### ២.៤.ការសរសេរខុសអក្ខរាវិរុទ្ធដោយសារតែស្មេរពុំស្គាល់ពីប្រភពដើមរបស់ពាក្យនិងក្បួនខ្នាត ដែលខ្ចីពាក្យពីបរទេស

រហូតមកដល់ពេលនេះ ពាក្យ *ការអនុវត្ត* គេសរសេរដោយមានថែម *ន៍* នៅខាងបែបនេះ *ការអនុវត្តន៍*។ ការសរសេរបែបនេះ វាពុំត្រឹមត្រូវតាមក្បួនខ្នាតទេ ត្បិតអីវាជាពាក្យដែលខ្ចីពីភាសាបាលី-សំស្ក្រឹត ហើយនៅក្នុងភាសាទាំងនេះ *អនុវត្ត* (គ្មាន *ន៍*) ជាកិរិយាស័ព្ទ ហើយ អនុវត្តនៈ (មាន *ន*) ខាងចុងជានាមស័ព្ទ។ ក្នុងភាសាបាលី-សំស្ក្រឹត នាមស័ព្ទ *អនុវត្តនៈ* អានមានសូរ [ណាក់] នៅខាងចុង លុះខ្មែរខ្ចីពាក្យនេះយកមកប្រើ ខ្មែរយើងមិនប្រើសូរ [ណាក់] នេះទេ ហើយខ្មែរយើង ក៏ប្រើទណ្ឌឃាតសម្លាប់សូរចុងនោះចោល។ ហេតុនេះហើយ បានជាយើងមាននាមស័ព្ទ *អនុវត្តន៍* បែប នេះ។ ប៉ុន្តែ ខ្មែរយើងក៏អាចខ្ចីកិរិយាស័ព្ទ *អនុវត្ត* មកប្រើប្រាស់ដែរ ហើយនៅពេលដែលយើងចង់បាននាមស័ព្ទចេញពីកិរិយាស័ព្ទ *អនុវត្ត* នោះ យើងក៏បន្ថែមបុព្វបទ *ការ* នៅពីមុខកិរិយាស័ព្ទនោះទៅ យើងក៏បាននាមស័ព្ទមួយដែលសរសេរជា *ការអនុវត្ត* បែបនេះឯង។ ចុះសំណេរ *ការអនុវត្តន៍* បានមកពីណា? ហើយមានហេតុផលដូចម្តេចខ្លះ? ខ្ញុំយល់ថា វាគ្រាន់តែជាការយល់ច្រឡំតែប៉ុណ្ណោះ គ្មានអំណះអំណាងអ្វីមកបញ្ជាក់បានទេ។

### ២.៥ ការសរសេរខុសអក្ខរាវិរុទ្ធដោយយើងពុំបានបង្កើតឱ្យមានលំនឹងវេយ្យាករណ៍

ការដែលយើងមិនបានកំណត់បង្កើតឱ្យមានលំនឹងវេយ្យាករណ៍មួយស្តីពី សំណេរនៃពាក្យកម្ចីពីបរទេស អាចជាកត្តាដែលញុំាងឱ្យសរសេរពាក្យដែលចាត់ទុកថាខុសអក្ខរាវិរុទ្ធ។ ជាក់ស្តែងពាក្យថា *ស៊ីម៉ង់ត៍* យើងសរសេរមាន *ត៍* នៅខាងចុងព្រោះវាជាពាក្យកម្ចីពីពាក្យបារាំង *Ciment* ដែលមាន *t* នៅខាងចុង។ ព្យញ្ជនៈ *t* នេះត្រូវនឹងព្យញ្ជនៈ *ត* របស់ខ្មែរយើង ហើយវាមិនមានឮសូរអានទេ ហេតុនេះហើយបានជាខ្មែរយើងសរសេរ *ត៍* នៅខាងចុងពាក្យ *ស៊ីម៉ង់ត៍* យ៉ាងដូច្នេះទៅ។ ការសរសេរពាក្យកម្ចីបែបនេះ គឺដោយសារស្មេរអនុវត្តប្រព័ន្ធកត់ត្រាតាមបែបត្រង់ស្លីតេរ៉ាស្យុង (Translittération) លុះក្រោយមកស្មេរមួយចំនួនសរសេរពាក្យកម្ចីខ្លះ ដោយមិនគោរពតាមប្រព័ន្ធត្រង់ស្លីតេរ៉ាស្យុងទេ តែសរសេរតាមបែបកត់ត្រាពាក្យដោយប្រើអក្សរកត់ត្រាសូរអន្តរជាតិ(Transcription phonétique)វិញម្តង។ ដោយហេតុនេះហើយបានជាពាក្យបារាំង Département ដែលមាន *t* នៅខាងចុងដែរនោះ ត្រូវបានគេសរសេរជាអក្សរខ្មែរ *ដេប៉ាតឺម៉ង់* ដោយគ្មាន *ត៍* នៅខាងចុងរហូតមក។ បញ្ហាមួយអាចចោទឡើងនៅពេលដែលស្មេរមួយចំនួនគោរពតាមប្រព័ន្ធត្រង់ស្លីតេរ៉ាស្យុង ហើយមួយចំនួនទៀតគោរពតាមប្រព័ន្ធសរសេរពាក្យដោយសារការកត់តែសូរសំឡេងអាន។ ពេលនោះហើយ ការសរសេរមាន *ត៍* ឬគ្មាន *ត៍* នៅ ខាងចុងចោទជាបញ្ហាចម្រូងចម្រាស់ ហើយស្មេរទាំងនោះនឹងចោទគ្នាទៅវិញទៅមកថា សរសេរខុសអក្ខរាវិរុទ្ធ។

ប៉ុន្តែបើយើងកំណត់យកការសរសេរពាក្យកម្ចីតាមប្រព័ន្ធណាមួយច្បាស់លាស់នោះ យើងនឹងគ្មានបញ្ហាចំពោះអក្ខរាវិរុទ្ធប្រភេទនេះទៀតទេ។ តាមយោបល់ខ្ញុំ គួរតែប្រកាន់យកប្រព័ន្ធកត់ត្រាតែសូរសំឡេងវិញ ព្រោះវាស្រួលជាង ហើយវាក៏ពុំមានទាស់ខុសន័យសេចក្តីអ្វីដែរ។

## ៣.កត្តាផ្សេងៗដែលបណ្តាលឱ្យមានកំហុសអក្ខរាវិរុទ្ធ

ក្រៅពីភាពអវិជ្ជាឬភាពគ្មានជំនាញភាសាវិទ្យា ដែលបណ្តាលឱ្យអ្នកអក្សរសាស្ត្រមួយចំនួនធំមានការភាន់ច្រឡំរហូតបង្កើតបានជាកំហុសអក្ខរាវិរុទ្ធដូចដែលខ្ញុំបានបង្ហាញជូនខាងលើនោះ នៅមានកត្តាផ្សេងៗទៀតដែលបណ្តាលអោយមានកំហុសអក្ខរាវិរុទ្ធនៅក្នុងអត្ថបទនានា។ កត្តាទាំងនោះរួមមាន: ការធ្វេសប្រហែស កង្វះការត្រួតពិនិត្យ ការបំភាន់ពីមជ្ឈដ្ឋានជុំវិញនឹងការធ្វើកំណែប្រែខុស។

### ៣.១ ការធ្វេសប្រហែស

ភាសាវិទូ ឬអ្នកប្រាជ្ញអក្សរសាស្ត្រណាក៏ដោយ ឱ្យតែធ្វេសប្រហែសនៅក្នុងការសរសេរនោះ គេពិតជាមានកំហុសឆ្គងផ្នែកអក្ខរាវិរុទ្ធជាក់ជាមិនខាន បើមិនច្រើនក៏តិចដែរ។ ពិសេសភាសាវិទូដែលតែងតែផ្តោតអារម្មណ៍លើបញ្ញត្តិដែលត្រូវបកស្រាយ ឬវិភាគឱ្យគេយល់ ហើយក៏ភ្លាំងភ្លេច ឬធ្វេសប្រហែសនៅក្នុងការសរសេរពាក្យ។ ហេតុនេះ វាតម្រូវឱ្យមានអ្នកជំនាញអក្ខរាវិរុទ្ធត្រួតពិនិត្យ និងកែលំអឡើងវិញ។

### ៣.២ ការវាយអត្ថបទ ឬ កុំព្យូទ័រ

ការប្រគល់អត្ថបទទៅឱ្យលេខាជាអ្នកវាយកុំព្យូទ័រ និងជាអ្នកគ្មានជំនាញអក្ខរាវិរុទ្ធនោះ អាចបណ្តាលឱ្យមានកំហុសអក្ខរាវិរុទ្ធជាក់ជាមិនខាន។ ជាក់ស្តែងអត្ថបទសំណេរដែលជាភាសាបារាំង ដែលខ្ញុំប្រគល់ឱ្យលេខាផ្នែកស្រាវជ្រាវនោះ ពេលគេយកទៅវាយកុំព្យូទ័រ ឃើញថាមានកំហុសជាច្រើន ព្រោះអ្នកវាយកុំព្យូទ័រនោះចេះតែភាសាអង់គ្លេស មិនសូវចេះភាសាបារាំង។

ជួនកាល ការសរសេរខុស *ល* ទៅជា *ឡ* ឬ *ន* ទៅ *ណ* គឺបណ្តាលមកពីកម្មវិធីកុំព្យូទ័រផ្ទាល់តែម្តង។ ជាក់ស្តែងបើយើងសរសេរ ន នៅដើមបន្ទាត់ ឬបន្ទាប់ពីសញ្ញាខណ្ឌ (។) ហើយយើងដកឃ្លានោះ *ន* ប្តូរទៅជា *ណ* ដោយស្វ័យប្រវត្ត ឯ *ល* ក៏ប្តូរទៅជា *ឡ* ដែរ។

ដើម្បីចៀសវាងប្រការនេះ ត្រូវប្រុងប្រយ័ត្ននិងត្រួតពិនិត្យឡើងវិញ។

### ៣.៣ កង្វះខាតការត្រួតពិនិត្យ

នៅស្រុកខ្មែរបច្ចុប្បន្ន បើនិយាយពីអ្នកត្រួតពិនិត្យនោះ គឺមានហូរហៀច្រើនណាស់ មិនថាឡើយ តែនៅក្នុងវិស័យភាសានិងអក្សរសាស្ត្រទេ។ ប៉ុន្តែការត្រួតពិនិត្យនៅក្នុងផ្នែកភាសាវិទ្យានិងអក្សរសាស្ត្រ ដែលជាផ្នែកមិនត្រូវប៉ាន់នោះមានតិចតួចបំផុត ឬសឹងតែគ្មានតែម្តង។ ហេតុនេះហើយ បានជាមាន កំហុសអក្ខរាវិរុទ្ធនៅក្នុងបទចំរៀងខារ៉ាអូខេជាច្រើនសន្ធឹកសន្ធាប់ និងបែបអនាធិបតេយ្យបំផុត។

### ៣.៤ ការចំរានចំរាន់ពីមជ្ឈដ្ឋានជុំវិញ

ដោយសារមានកំហុសអក្ខរាវិរុទ្ធនៅក្នុងអត្ថបទសារព័ត៌មាន ទស្សនាវដ្តី សៀវភៅផ្សេងៗ លើ កញ្ចក់ទូរទស្សន៍ ។ល។ អ្នកអានជាច្រើនក៏ចងចាំពាក្យទាំងនោះ ហើយក៏ទម្លាប់សរសេរខុសបែបនោះជា បន្តទៅទៀតទៅ។ ប្រភពកំហុសទាំងនោះ វាពិតជាថ្នាំពុលសម្រាប់កូនខ្មែរជំនាន់ក្រោយ។

លុះដល់ពេលមានអ្នកចេះដឹងធ្វើការកែលំអនោះ ជួនកាលក៏ស្ទុះជាសង្គ្រាមប៉ាកកាឡើង ហើយ ម្នាក់ៗ តែងលើកយកគោលសំអាងរៀងៗខ្លួន ដើម្បីជជែកយកឈ្នះលើគ្នាទៅវិញទៅមក។

### ៣.៥ ការធ្វើគំរូណែប្រែខុស

ចំពោះចំណុចនេះ ខ្ញុំសូមលើកយកការបកស្រាយ និងកំណែអក្ខរាវិរុទ្ធនៃ ឃាតករ មកបង្ហាញ ជូន។ រហូតមកដល់ឆ្នាំ២០០៣ ស្ទើរទាំងឡាយសរសេរពាក្យ ឃាតករ ដោយមាន "រ" នៅខាងចុងជានិច្ច។ លុះនៅក្នុងកំឡុងឆ្នាំ២០០៣នោះ មានមន្ត្រីម្នាក់នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានធ្វើការពន្យល់ណែនាំ តាមរយៈទូរទស្សន៍ ស៊ីធីអិន (CTN) ត្រូវសរសេរ ឃាតក គ្មាន រ នៅខាងចុងយ៉ាងនេះ ទើបត្រូវទៅ តាមវចនានុក្រមសង្ឃរាជ ជួន ណាត។ តែបើយើងបើកវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ទៅ យើងពុំឃើញមានពាក្យ ឃាតក សរសេរបែបហ្នឹងទេ គឺមានតែពាក្យ ឃាតកៈ ដែលត្រូវអានថា ឃាត-តៈ-កៈ មានន័យថាអ្នកសម្លាប់ ហេតុនេះ វាពុំខុសអ្វីទេ។ ក៏ប៉ុន្តែ តើអ្នកនិយាយឬអ្នកសរសេរ គេ និយាយពី ឃាតកៈ (ឃាត-តៈ-កៈ) ឬលើ ឃាតករ (ឃាត-តៈ-ក)? ចម្លើយឆ្លើយថា គឺគេនិយាយពី ឃាត-តៈ-ក ហេតុនេះហើយបានជា គេសរសេរ ឃាតករទៅព្រោះម្យ៉ាងវាត្រូវតាមអំណានសូរពាក្យ ហើយម្យ៉ាងទៀតគេបង្កើតពាក្យនេះឡើងតាមក្បួនវេយ្យាករណ៍ដូចតទៅ : ឃាត+ករ ទៅជា ឃាតករ។ គេយល់ឃើញថា បើ នេសាទ+ករ បានទៅជា នេសាទករ (អ្នកនេសាទ) ចុះហេតុអ្វីជាគេ មិនអាច បង្កើតវេយ្យាករណ៍នោះ?

ការផ្លាស់ប្តូរមកសរសេរជា ឃាតក តម្រូវឱ្យយើងអានថា ឃាត-តក ដូចដែលយើងធ្លាប់អានពាក្យ នាយក (នាយ + អកៈ) ឧបាសក (ឧបាសៈ + អកៈ) យ៉ាងដូច្នេះដែរ ។ យើងគ្មានទម្លាប់អានថា នាយក់ ក ឬ ឧបាសៈកនោះទេ ។

បើយើងវិភាគទៅឃើញថា ការសរសេរជា ឃាតក មានបញ្ហាចម្រូងចម្រាស់ដូចតទៅ :

-ទី១ : ខុសពីអក្ខរាវិរុទ្ធដែលមាននៅក្នុងវចនានុក្រម ជួន ណាត ។

-ទី២ : ខុសពីអំណានសូរទាំងនៅក្នុងវចនានុក្រម ទាំងនៅក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ។

-ទី៣ : ខុសពីទម្លាប់ដែលតែងតែសរសេរមាន រ នៅខាងចុង ។

-ទី៤ : គួរតែលើកគ្នានិយាយថា ឃាតក់ វិញដើម្បីតម្រូវទៅតាមកំណែប្រែអក្ខរាវិរុទ្ធ ។

## ៤.វិធានការ

ដើម្បីជៀសវាង កំហុសឆ្គងអក្ខរាវិរុទ្ធតទៅទៀតនោះ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចតទៅ :

១.ជំរុញការបណ្តុះបណ្តាលឱ្យបានផុសផុល ដោយត្រូវពង្រឹងគុណភាពអប់រំនៅគ្រប់កំរិតសិក្សាពិសេសនៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ ។

២.រកមធ្យោបាយធ្វើយ៉ាងណាឱ្យមានការបណ្តុះបណ្តាលបន្តជាបន្ទាន់ដែលមានលក្ខណៈជាប្រព័ន្ធ ព្រោះវិធានការនេះ អាចឱ្យមានការចែករំលែកចំណេះដឹងដល់គ្នាទៅវិញទៅមកចំពោះសាស្ត្រាចារ្យគ្រប់កម្រិត ។

៣.ស្មេរគ្រប់រូប ត្រូវតែគោរពតាមគោលការណ៍អក្ខរាវិរុទ្ធដែលត្រឹមត្រូវ ហើយចៀសវាងការសរសេរពាក្យទៅតាមការយល់ឃើញផ្ទាល់ខ្លួនដែលប្រាសចាកពីការពិត ។

៤.ឈប់ធ្វើកំណែប្រែអក្ខរាវិរុទ្ធដោយពុំសមហេតុផលតទៅទៀត ហើយរួមគ្នាធ្វើកំណែតម្រូវឡើងវិញ ហើយការកែតម្រូវនេះទៀតសោតត្រូវធ្វើទៅតាមជំនាញបច្ចេកទេសច្បាស់លាស់ ។

៥.គួរតែប្បីតម្រូវឱ្យមាននយោបាយជាតិមួយស្តីភាសា និង អក្សរសាស្ត្រខ្មែរប្រចាំក្រសួងអប់រំ យុវជន និង កីឡា ដោយសហការគ្នាជាមួយរាជបណ្ឌិតសភាកម្ពុជា ។ យន្តការនៃការស្រាវជ្រាវមួយដ៏មានប្រសិទ្ធភាព នឹងត្រូវបង្កើតឡើងប្រសិនបើយើងមានលទ្ធភាព ពោលគឺធនធានមនុស្ស និងថវិកា ។

៦.សូមមេត្តាបណ្តាញសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនានា ជួយធ្វើជាគំរូឈានមុខគេក្នុងការផ្សព្វផ្សាយ និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវសំណេរពាក្យ និងអក្ខរាវិរុទ្ធខ្មែរយើង ។ គួរតែប្បីកុំឱ្យកំហុសអក្ខរាវិរុទ្ធមាននៅក្នុងអត្ថបទ ឬ ទំព័រផ្សាយរបស់ខ្លួន ។

# ឯកសារពិគ្រោះ


កេង វ៉ាន់សាក់ (១៩៦៤) *មូលភាពនៃការបង្កើតពាក្យថ្មី* ភ្នំពេញ។

ច័ន្ទ សំណព្វ (១៩៩៩) *វិជ្ជមានន័យអវិជ្ជមានន័យនិងបរិធាតុរបស់វា* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ច័ន្ទ សំណព្វ (២០០៣) *ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ច័ន្ទ សំណព្វ (២០០៥) *គោលការណ៍នៃការបង្កើតពាក្យនិងកម្ម* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ច័ន្ទ សំណព្វ (២០០៦) *ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ* ការ *និង* ផ្ចត់ដែក *[-អំម/ណ]/[-អំម/ន-]* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ពុំ ម៉ល់ (២០០៦) *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប* រាជបណ្ឌិតសភាកម្ពុជា។

អៀវ កើស (១៩៦៧) *ភាសាខ្មែរ* បណ្ណាគារមិត្តសេរី។

# គុណនាមក្នុងភាសាខ្មែរ

(Adjective in Khmer Language)

"យើងខ្ញុំសូមឧទ្ទិសអត្ថបទនេះជូនចំពោះវិញ្ញាណក្ខន្ធ
លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម"

តាមការសិក្សាប្រវត្តិភាសាវិទ្យា យើងបានដឹងថា *គុណនាម* គឺជាប្រភេទពាក្យមួយដែលគេបានស្គាល់តាំងពីយូរយារណាស់មកហើយ គឺតាំងពីសម័យកាលមុនគ្រិស្តសករាជមកម្ល៉េះ។ គេបានដឹងថា នៅសម័យកាលក្រិចបុរាណដែលល្បីរន្ទឺដោយកេរ្តិ៍ឈ្មោះទស្សនវិទូជាច្រើនរូប , លោកអារីស្តូត (៣៨៤-៣២២ មុន គ.ស) បានបន្តគំនិតពីលោកប្លាតុង (៤២៨-៣៤៨ មុន គ.ស) ទាក់ទងនឹងការពិចារណាអំពីភាសាក្នុងនោះគាត់បានបន្ថែមប្រភេទពាក្យមួយទៀតគឺ*គុណនាម* ទៅលើពាក្យពីរប្រភេទគឺ នាមស័ព្ទ និង កិរិយាស័ព្ទ ដែលលោកប្លាតុងបានពិចារណាឃើញ។ ទោះបីយ៉ាងនេះក្តីប្រភេទពាក្យ *គុណនាម* ក៏នៅតែជាបញ្ហាជជែកពិភាក្សាមួយក្នុងចំណោមបញ្ហាជាច្រើននៃការសិក្សាភាសានានា។ នៅក្នុងការសិក្សាស្រាវជ្រាវភាសាខ្មែរ អ្នកស្រាវជ្រាវខ្លះបានបញ្ចេញមតិថា ភាសាខ្មែរគ្មានគុណនាមទេ ឯអ្នកស្រាវជ្រាវខ្លះទៀតហាក់នៅស្ទាក់ស្ទើរក្នុងការបែងចែករវាង គុណនាម និង នាមស័ព្ទ , រវាង គុណនាម និង កិរិយាស័ព្ទ។ តាមរយៈអត្ថបទនេះ ខ្ញុំនឹងធ្វើការបង្ហាញថា អ្វីជាគុណនាម , ពិចារណាអំពីការបែងចែកប្រភេទគុណនាម និងអំពី អត្ថិភាពនៃគុណនាមកម្មសិទ្ធិ នៅក្នុងភាសាខ្មែរ។

## ១-អ្វីជាគុណនាម

### ១.១-ការពិនិត្យក្នុងសម្ព័ន្ធ

ដើម្បីឱ្យឃើញច្បាស់ថាអ្វីជាគុណនាម យើងចាំបាច់ត្រូវតែធ្វើការពិនិត្យលក្ខណៈរបស់វានៅក្នុងល្បះ។ ល្បះដែលយើងយកមកធ្វើការសិក្សា មានដូចខាងក្រោម :

(១.ក) - *"កម្មករថ្មី លើកដៃសំពះសួរនាងនារី "*

(២.ក) - *"បុរសនោះ ក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ"*

(៣.ក) - *"បុរសជរាម្នាក់(...) ដេកស្តូកស្តឹង នាកណ្តាលល្វែងបន្ទប់"*

(៤.ក) - *"យើងចាប់ត្រីធំៗ (...) "*

(ល្បះ(១.ក) (២.ក) (៣.ក) ដកស្រង់ពីរឿង *កុលាបប៉ៃលិន* របស់លោក ញ៉ុក ថែម , ឯល្បះ (៤.ក) ដកស្រង់ពីរឿង *សម្លាញ់ពីរនាក់* នៅក្នុង ប្រជុំរឿងព្រេងខ្មែរភាគ១)

- **<u>ការសាកល្បងទី១</u> :** (ដកនាមចេញ ទុកតែគុណនាម)

បើយើងដកនាម *កម្មករ* ចេញពីល្បះ(១.ក) , ដកនាម *បុរស* ចេញពីល្បះ(២.ក) , ដក *បុរសម្នាក់* ចេញពីល្បះ(៣.ក) និង ដកនាម *ត្រី* ចេញពីល្បះ(៤.ក) យើងបានខ្សែសម្ដី ដូចតទៅ :

(១.ខ) - * *"ថ្មីលើកដៃសំពះសួរនាងនារី "*

(២.ខ) - * *"នោះ ក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ"*

(៣.ខ) - * *"ជរា ដេកស្ដូកស្ដឹងនាកណ្ដាលល្វែងបន្ទប់ "*

(៤.ខ) - * *"យើងចាប់ធំៗ (...) "*

តាមរចនាសម្ព័ន្ធល្បះក្នុងភាសាខ្មែរ ខ្សែសម្ដីខាងលើនេះ ពុំអាចប្រព្រឹត្តទៅបានទេ។ លទ្ធផលនេះបង្ហាញថាពាក្យ *ថ្មី , នោះ , ជរា , ធំៗ* ពុំអាចឈរតែឯងក្នុងកន្សោមនាម ដើម្បីបំពេញមុខងារជាប្រធានក្នុងល្បះឡើយ ។

- **ការសាកល្បងទី២ :** (ប្ដូរទីតាំងជាមួយនឹងនាមស័ព្ទ)

បើយើងធ្វើការផ្លាស់ប្ដូរទីតាំងនៃពាក្យ *ថ្មី* មកខាងមុខ (ខាងឆ្វេង) នាមស័ព្ទ *កម្មករ* នៅក្នុងល្បះ(១.ក), ប្ដូរទីតាំងនៃពាក្យ *នោះ* មកខាងមុខនាម *បុរស* នៅក្នុងល្បះ(២.ក), ប្ដូរទីតាំងនៃពាក្យ *ជរា* មកខាងមុខនាមស័ព្ទ *បុរស* នៅក្នុងល្បះ (៣.ក), ប្ដូរទីតាំងនៃពាក្យ *ធំៗ* មកខាងមុខនាម *ត្រី* , និងយើងនឹងទទួលបានខ្សែសម្ដីដូចខាងក្រោម :

(១.គ) - * *"ថ្មីកម្មករ លើកដៃសំពះសួរនាងនារី "*

(២.គ) - * *"នោះបុរស ក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ"*

(៣.គ) - * *"ជរាបុរសម្នាក់ ដេកស្ដូកស្ដឹងនាកណ្ដាលល្វែងបន្ទប់"*

(៤.គ) - * *"យើងចាប់ធំៗត្រី (...) "*

ខ្សែសម្ដីដែលទទួលបានខាងលើនេះ ពុំអាចចាត់ទុកជាល្បះត្រឹមត្រូវតាមប្រព័ន្ធភាសាខ្មែរឡើយ ព្រោះការប្ដូរទីតាំងពាក្យមួយចំនួននៅក្នុងកន្សោមនាម ដូចការសាកល្បងនេះ បានធ្វើឱ្យប្រាសចាករចនាសម្ព័ន្ធកន្សោមពាក្យក្នុងភាសាខ្មែរដែលគោរពតាមលំដាប់ *ពាក្យគោល-ពាក្យរណប (complété-complétif)* ។

តាមរយៈលទ្ធផលនៃការធ្វើតេស្តសាកល្បងទាំងពីរខាងលើ បង្ហាញថា ពាក្យ *ថ្មី, នោះ, ជរា, ធំៗ*:

(១) -មិនអាចឈរតែឯង ជាប្រធានក្នុងល្បះ ឬជាកម្មរបស់កិរិយាស័ព្ទ ;

(២) -មិនអាចឈរនៅខាងមុខនាម ។

ពាក្យបែបនេះហើយ ដែលគេហៅថា "គុណនាម " ។

## ១.២-ការពិនិត្យនិយមន័យដែលមានកន្លងមក :

អ្នកនិពន្ធ ពូវ អ៊ុម(១៩៥៥) បានសរសេរថា "ពាក្យដែលសម្ដែងលក្ខណៈរបស់នាម ឬធ្វើនាមឱ្យមានបទ ដូចពាក្យថា : ថ្មីរឹង មនុស្សចាស់ ...រឹង ចាស់ ប្រាប់លក្ខណៈ ថ្ម មនុស្ស ... ហៅថាគុណនាម " ។

អ្នកនិពន្ធ អ៊ុយ ជួន ចាត់ទុកគុណនាមថាជានាមមួយបែប។ គាត់សរសេរថា "នាមដែលសម្ដែងលក្ខណៈរបស់នាមនាមណាមួយ ដើម្បីឱ្យដឹងថា នាមនាមនោះល្អ ឬ អាក្រក់ , ខ្មៅ ឬ ស , ខ្ពស់ ឬ ទាប , ដូចពាក្យថា "ខ្មៅ , ស , ល្អ , អាក្រក់" ជាដើម ហៅថាគុណនាម"[១] ។

អ្នកនិពន្ធ ខៀវ ជុំ បានសរសេរថា " ... ពាក្យសម្រាប់ធ្វើនាមនិងសព្វនាម ឱ្យមានសេចក្ដីផ្លែក (ប្លែក) ផ្សេងចេញទៅ "[២] ។

សៀវភៅវេយ្យាករណ៍ថ្នាក់ទី៥ របស់ក្រសួងអប់រំ (១៩៨៣) បានឱ្យនិយមន័យគុណនាម ដោយសរសេរថា "គុណនាម គឺជាសម្ដីសម្ដែងលក្ខណៈរបស់នាម " (ទំព័រ៩៤) ។

តាមលោកសាស្ត្រាចារ្យ ឃិន សុខ " គុណនាមជាពាក្យដែលគេប្រើជាមួយនាម ដើម្បីបញ្ជាក់ន័យ ឬ កំណត់ន័យឱ្យនាម នោះ "[៣] ។

ឯលោក អ៊ុក វិបុល ឱ្យនិយមន័យគុណនាមថា "គឺជាពាក្យ ដែលបញ្ជាក់លក្ខណៈឱ្យនាមឬសព្វនាម"[៤] ។

ដើម្បីឱ្យការសិក្សាអំពីភាសាមានលក្ខណៈបែបវិទ្យាសាស្ត្រ គប្បីយើងចែកឱ្យដាច់រវាង "ប្រភេទពាក្យ" និង "មុខងារនៃពាក្យ" ហើយ យើងក៏មិនគួរប្រើពាក្យតែមួយសម្រាប់សំគាល់ប្រភេទពាក្យផង និងមុខងាររបស់ពាក្យផង នោះទេ ព្រោះវានាំឱ្យមានការច្របូលច្របល់ ។ ចំពោះនិយមន័យសម្រាប់គុណនាមវិញ យើងក៏ត្រូវលៃយ៉ាងណាឱ្យនិយមន័យនោះសំគាល់តែមុខងាររបស់គុណនាមសុទ្ធសាធ ។

តាមរយៈនិយមន័យខាងលើ គុណនាមគឺជាពាក្យសម្រាប់ "សម្ដែងលក្ខណៈរបស់នាម" ។ និយមន័យនេះបានបញ្ជាក់ត្រឹមតែមុខងាររបស់គុណនាមដែលមិនប្លែកគ្នាពីមុខងារនៃកម្មរបស់នាមសព្ទ ដែលអាចជានាមសព្ទដូចគ្នាឬជាកិរិយាសព្ទ , ឧទាហរណ៍: *ផ្ទះថ្ម* , *សៀវភៅសរសេរ* ។[៥]

យោងតាមការបញ្ជាក់ខាងលើ យើងខ្ញុំសូមសាកល្បងឱ្យនិយមន័យសម្រាប់គុណនាម ដូចនេះ :

---

[១] - អ៊ុយ ជួន : ***វេយ្យាករណ៍ពិសេស*** , ជ-ឯ-ម, ទំព័រ៥៩។ *នាម* ដែលលោក អ៊ុយ ជួន បានប្រើ មិនមែនជានាមស័ព្ទ ដែលយើងប្រើសព្វថ្ងៃនេះទេ។ គាត់ប្រើ *នាម* សំគាល់ប្រភេទពាក្យ ដែលមាន នាមស័ព្ទ (ដែលគាត់ហៅថា *នាមនាម*) និង គុណនាម ។

[២] - ខៀវ ជុំ : ***វេយ្យាករណ៍យើង***, ជ-ឯ-ម, ទំព័រ៥៩។

[៣] - Khin Sok, ***La grammaire du Khmer moderne,*** Op.cit., p.233: *"L'adjectif est un mot qu'on ajoute à un nom soit pour le qualifier(...), soit pour le déterminer."*

[៤] - អ៊ុក វិបុល : ***វេយ្យាករណ៍ទំនើប ថ្នាក់ទី១២***, ជ-ឯ-ម, ទំព័រ១៧។

[៥] - នាមស័ព្ទ *ថ្ម* និង កិរិយាស័ព្ទ *សរសេរ* មានមុខងារជាកម្មរបស់នាម ។

*គុណនាមជាពាក្យដែលគេប្រើសម្រាប់បញ្ជាក់លក្ខណៈឱ្យនាមសព្ទ ដូចកម្មរបស់នាមសព្ទដែរ ដែលអាចជានាមសព្ទដូចគ្នាឬជាកិរិយាសព្ទ ប៉ុន្តែវាប្លែកពីកម្ម ដោយហេតុថា វាមិនអាចស្ថិតនៅតែឯងក្នុងល្បះ ជាប្រធានឬជាកម្មរបស់កិរិយា និង មិនអាចជាស្នូលនៃល្បះបានទេ (លើកលែងតែគេប្រើវាជាកិរិយាស័ព្ទ)។ ក្នុងភាសាខ្មែរ កន្សោមពាក្យដែលកើតពីនាមនិងគុណនាម , គុណនាមច្រើនតែស្ថិតនៅខាងស្តាំនាម។ ប៉ុន្តែមានគុណនាម មួយចំនួនតូចប៉ុណ្ណោះដែលអាចមានទីតាំងនៅខាងឆ្វេងនាម។*

ពាក្យ : ខ្ពស់ ធំ ទាំងឡាយ នានា ក្រហម ...... គឺជាគុណនាម។

**កំណត់សម្គាល់** : គុណនាមមួយចំនួនដែលខ្ចីពីភាសាបាឡី អាចឈរនៅពីមុខនាម : ឧ- *សាធារណការ*, *សាធារណនាម*, *រាជរដ្ឋាភិបាល*, ... តែនៅក្នុងការប្រើប្រាស់បច្ចុប្បន្ន យើងឃើញមានអ្នកប្រើប្រាស់ជាច្រើនកំពុងតែទាញគុណនាមខ្លះក្នុងជំពូកនេះ ឱ្យទៅជាគុណនាមដូចគុណនាមខ្មែរឯទៀត : ឧ- *សាធារណនាម* ប្រើទៅជា *នាមសាធារណ៍*, *អកម្មកិរិយា* ប្រើទៅជា *កិរិយាអកម្ម* ...។

## ១.៣-សិក្សាបន្លែករវាងគុណនាម និង កម្មរបស់នាមដែលជាកិរិយាស័ព្ទ

នៅក្នុងភាសាខ្មែរ គេអាចច្រឡំគុណនាមជាមួយនឹងកិរិយាស័ព្ទ ព្រោះវាមានលក្ខណៈដូចគ្នាជាច្រើន។ ក្នុងកន្សោមនាម កិរិយាស័ព្ទក៏អាចប្រើសម្រាប់បញ្ជាក់ន័យឱ្យនាមស័ព្ទ ដូចគុណនាមបានដែរ។ ប៉ុន្តែ បើយើងធ្វើការពិនិត្យសិក្សាឱ្យស៊ីជម្រៅទៅ ទើបយើងឃើញថា គុណនាម និង កិរិយាស័ព្ទ មានលក្ខណៈផ្សេងគ្នា ដែលអាចឱ្យយើងធ្វើបន្លែកវាបាន។

យើងពិនិត្យកន្សោមខាងក្រោម :

-ផ្ទះខ្ពស់

-ផ្ទះជួល

-បើយើងថែមពាក្យ *ដ៏* ក្នុងកន្សោមទាំងពីរ យើងបាន :

-ផ្ទះដ៏ខ្ពស់

-*ផ្ទះដ៏ជួល (កន្សោមមិនអាចទទួលយកបាន)

-បើយើងថែមពាក្យ *សម្រាប់* ក្នុងកន្សោមទាំងពីរ យើងបាន :

-*ផ្ទះសម្រាប់ខ្ពស់ (កន្សោមមិនអាចទទួលយកបាន)

-ផ្ទះសម្រាប់ជួល

-បើយើងថែមពាក្យ *ណាស់* យើងបាន :

-ផ្ទះខ្ពស់ណាស់

-*ផ្ទះជួលណាស់ (កន្សោមមិនអាចទទួលយកបាន)

តាមរយៈការសាកល្បងខាងលើនេះ យើងឃើញថា ថ្វីត្បិតតែពាក្យ *ខ្ពស់* និងពាក្យ *ថ្មល* អាចប្រើសម្រាប់បញ្ជាក់ន័យឱ្យពាក្យ *ផ្ទះ* ដូចគ្នាមែន តែវានៅមានលក្ខណៈពិសេសផ្សេងគ្នា ដែលអាចឱ្យយើងទទួលស្គាល់ថា ពាក្យ *ខ្ពស់* និងពាក្យ *ថ្មល* ស្ថិតនៅក្នុងប្រភេទពាក្យផ្សេងគ្នា គឺ *ខ្ពស់* ជាគុណនាម , *ថ្មល* នៅតែជាកិរិយាស័ព្ទដែលគេប្រើជាកម្ម (complément) របស់នាមសព្ទ *ផ្ទះ* ។

## ១.៤-សិក្សាបន្លែករវាងគុណនាម និង កម្មរបស់នាមស័ព្ទដែលជានាមស័ព្ទដែរ

នៅក្នុងភាសាខ្មែរ គេក៏អាចច្រឡំគុណនាម និង នាមស័ព្ទ។ នៅក្នុងកន្សោមនាម នាមស័ព្ទក៏អាចប្រើសម្រាប់បញ្ជាក់ន័យឱ្យនាមស័ព្ទមួយទៀតដែលនៅខាងដើម ដូចគុណនាមដែរ , ឧទាហរណ៍ :

-ផ្ទះធំ

-ផ្ទះថ្ម

ប៉ុន្តែ បើយើងធ្វើការសិក្សាដើម្បីរកបន្លែករវាងពាក្យ *ធំ* និងពាក្យ *ថ្ម* ក្នុងកន្សោមខាងលើនេះ ដោយសាកល្បងបញ្ចូលពាក្យ ដ៏ ក្នុងកន្សោមទាំងពីរ យើងបាន :

-ផ្ទះដ៏ធំ

-* ផ្ទះដ៏ថ្ម ( កន្សោមមិនអាចទទួលយកបាន)

ម្យ៉ាងទៀត បើយើងសាកល្បងបញ្ចូលពាក្យ *ណាស់* ក្នុងកន្សោមទាំងពីរ យើងបាន :

-ផ្ទះធំណាស់

-* ផ្ទះថ្មណាស់ ( កន្សោមមិនអាចទទួលយកបាន)

ការធ្វើតេស្តសាកល្បងខាងលើ ល្មមគ្រប់គ្រាន់អាចឱ្យយើងទទួលស្គាល់ថា ពាក្យ *ធំ* និងពាក្យ *ថ្ម* ជាពាក្យស្ថិតក្នុងប្រភេទពាក្យផ្សេងគ្នា គឺ *ធំ* ជាគុណនាម និង *ថ្ម* នៅតែជានាមស័ព្ទដែលត្រូវបានគេប្រើជាកម្ម (complement) របស់នាម *ផ្ទះ* ។

## ២-ការពិចារណាអំពីការបែងចែកប្រភេទផ្សេងៗនៃគុណនាម :

### ២.១-គុណនាមប្រក្រតី និង គុណនាមកំណត់

នៅក្នុងសៀវភៅវេយ្យាករណ៍ខ្មែរមួយចំនួន គុណនាមក្នុងភាសាខ្មែរ ត្រូវបានគេបែងចែកជាពីរបែបសំខាន់ៗ គឺ *គុណនាមប្រក្រតី* ( បកតិគុណនាម) ត្រូវនឹងភាសាបារាំង *adjectif qualificatif,* និង *គុណនាមកំណត់* [៦] ។ លោក Georges Maspéro (*Grammaire de la langue khmère, 1915* ) ហៅគុណនាមកំណត់ ថា *adjectif déterminatif* ដែលក្នុងនោះ គាត់បាននិយាយដល់គុណនាម៤ប្រភេទ

---

[៦] - ពាក្យបច្ចេកទេស *គុណនាមប្រក្រតី* , *គុណនាមកំណត់* ប្រើតាមសៀវភៅវេយ្យាករណ៍ ថ្នាក់ទី៧ របស់ក្រសួងអប់រំ( ១៩៨២) ។

គឺគុណនាមចង្អុល គុណនាមកម្មសិទ្ធិ គុណនាមសំណួរ និង គុណនាមមិនច្បាស់លាស់។ ចំណែកឯលោកសាស្ត្រាចារ្យ ឃិន សុខ *(La grmmaire du khmer moderne, 1999)* ហៅគុណនាមកំណត់ ថា *adjectif non-qualificatif* ដែលក្នុងនោះ គាត់បានបង្ហាញគុណនាម៥ប្រភេទ គឺ : គុណនាមចំនួន , គុណនាមកម្មសិទ្ធិ , គុណនាមចង្អុល , គុណនាមសំណួរ និង គុណនាមមិនច្បាស់។

ការបែងចែកគុណនាមក្នុងភាសាខ្មែរ ជាគុណនាមប្រក្រតី និង គុណនាមកំណត់ មានលំនាំស្រប គ្នាទៅនឹងការបែងចែកគុណនាម នៅក្នុងវេយ្យាករណ៍និយាមភាសាបារាំង។ នៅក្នុងអត្ថបទមេរៀន *ភាសាវិទ្យាអនុវត្តន៍* (២០០២) លោកសាស្ត្រាចារ្យ ព្រុំ ម៉ល់ បានបង្ហាញពីលក្ខណៈខុសគ្នាផ្នែកមុខងារសម្ព័ន្ធរវាងគុណនាមប្រក្រតី និង គុណនាមកំណត់ នៅក្នុងភាសាបារាំង ដោយសរសេរថា *" ក្នុងភាសានេះ "adjectifs qualificatif" ឥតមានមុខងារសម្ព័ន្ធ (fonction syntaxique) ជា "déterminant" (នាមវិសេសន៍) ទេ ផ្ទុយពី "adjectifs" ឯទៀត ដែលសុទ្ធតែជានាមវិសេសន៍ទាំងអស់"* ។ ស្របតាមការពន្យល់របស់លោកសាស្ត្រាចារ្យ ព្រុំ ម៉ល់ ខាងលើនេះ យើងអាចនិយាយថា ការបែងចែកគុណនាមបារាំងជាគុណនាមប្រក្រតីនិងគុណនាមកំណត់ ជាការបែងចែកដែលឈរលើមូលដ្ឋានរូប-សម្ព័ន្ធ ជាពិសេសគឺលក្ខណៈសម្ព័ន្ធ។ ចុះនៅក្នុងភាសាខ្មែរវិញ តើការចែកគុណនាម ជាគុណនាមប្រក្រតី និង គុណនាមកំណត់ ដូចភាសាបារាំងដែរនោះ ឈរលើមូលដ្ឋានអ្វី ហើយ គុណនាមទាំងពីរប្រភេទនេះ អាចមានលក្ខណៈខុសប្លែកគ្នាបែបណា?

សៀវភៅវេយ្យាករណ៍ដែលមានកន្លងមក បានបង្ហាញថា គុណនាម *"ខ្ពស់ ទាប តូច ធំ ស ... "* ជាគុណនាមប្រក្រតី។ ឯគុណនាមផ្សេងទៀត ដូចជា *"ប្រាំ នេះ អ្វី ខ្លះ ... "* ជាគុណនាមកំណត់។

**<u>ការពិនិត្យលក្ខណៈសម្ព័ន្ធក្នុងកន្សោម:</u>**

នៅក្នុងភាសាខ្មែរ គេអាចនិយាយនូវកន្សោម ដូចខាងក្រោម :

*-ផ្ទះខ្ពស់*
*-ត្រីធំ*
*-គុប្រាំ*
*-សៀវភៅនេះ*
*-សៀវភៅអ្វី ?*
*-កៅអីខ្លះ , ...*

នៅក្នុងកន្សោមខាងលើនេះ យើងឃើញថា គុណនាម *ខ្ពស់ , ធំ , ប្រាំ , នេះ , អ្វី , ខ្លះ* សុទ្ធតែជា*ពាក្យរណប* មានទីតាំងនៅខាងស្តាំនាមដែលជាពាក្យគោលរបស់វាដូចៗគ្នា។ លក្ខណៈបែបនេះ បញ្ជាក់ថា គុណនាម *ខ្ពស់ ធំ* (ដែលគេចាត់ ទុកជាគុណនាមប្រក្រតី) និងគុណនាម *ប្រាំ នេះ អ្វី អ្វីខ្លះ* (ដែលគេចាត់ទុកជាគុណនាមកំណត់) ពុំមានលក្ខណៈសម្ព័ន្ធខុសប្លែកគ្នាអាចឱ្យយើងសំគាល់ថា ណាមួយជាគុណនាម

ប្រក្រតី ណាមួយជាគុណនាមកំណត់ឡើយ ។

ការពិនិត្យក្នុងទម្លាប់ប្រើប្រាស់:

បើយើងពិនិត្យនៅក្នុងទម្លាប់នៃការប្រើប្រាស់វិញ យើងសង្កេតឃើញថា គុណនាមកំណត់មួយចំនួនអាចគេប្រើជាសព្វនាមចង្អុល ឬ សព្វនាមសំណួរ បាន ដោយមិនចាំបាច់បន្ថែមពាក្យណាមួយឡើយ ។ ឧទាហរណ៍ :

-នេះ ជាសៀវភៅខ្ញុំ នោះជាសៀវភៅឯង ។

-ឯងនិយាយអំពីអ្វី ?

-នរណាដើរ?

ចំណែកគុណនាមប្រក្រតីវិញ ពុំមានលទ្ធភាពប្រើជាសព្វនាមបានឡើយ លុះណាតែគេបន្ថែមពាក្យសមស្របណាមួយ ។ ឧទាហរណ៍ :

*ធំ ជារបស់ឯង ។

អាធំជារបស់ឯង ។

អាធំនេះ ជារបស់ឯង ។

អាធំៗ ជារបស់ឯង ។

នេះបានសេចក្ដីថា ការបែងចែកគុណនាមក្នុងភាសាខ្មែរ ជា គុណនាមប្រក្រតី និង គុណនាមកំណត់ ធ្វើឡើងដោយពុំផ្អែកលើលក្ខណៈសម្ពន្ធឡើយ តែយកទម្លាប់ប្រើប្រាស់ជាមូលដ្ឋាន ។

ដូច្នេះ បើតាមលក្ខណៈវិនិច្ឆ័យរូបនិយមផ្អែកលើលក្ខណៈសម្ពន្ធ យើងអាចនិយាយថា គេពុំអាចធ្វើការបែងចែកគុណនាមក្នុងភាសាខ្មែរជាគុណនាមប្រក្រតី ជាគុណនាមកំណត់ ដូចការបែងចែកគុណនាមនៅក្នុងភាសាបារាំងឡើយ [៧] ។

## ២.២-ការពិចារណាអំពីអត្ថិភាពគុណនាមកម្មសិទ្ធិ ក្នុងភាសាខ្មែរ

វេយ្យាករណ៍ប្រពៃណីបានបង្រៀនយើងផងដែរ អំពីគុណនាមកម្មសិទ្ធិ ដែលត្រូវបានគេចាត់ទុកជាគុណនាមកំណត់មួយ ក្នុងចំណោមគុណនាមកំណត់ដទៃទៀត ។ គេយល់ថា នៅក្នុងកន្សោមនាម *សៀវភៅខ្ញុំ*, *ស្រូវគាត់*, *កំហុសវា* ពាក្យ *ខ្ញុំ*, *គាត់*, *វា* សុទ្ធតែជាគុណនាមកម្មសិទ្ធិ ។

---

[៧] - ផ្ទុយពីអ្នកនិពន្ធសៀវភៅវេយ្យាករណ៍ដទៃទៀត, លោក Jean Dubois *(La nouvelle grammaire du français)* ពុំបានចែកគុណនាមបារាំងជា adjectif qualificatif, adjectif non-qualificatif ឡើយ ។ ពាក្យ adjectif ដែលគាត់បានប្រើ គឺសំដៅរក adjectif qualificatif ។ ចំណែកពាក្យទាំងឡាយ ដែលគេបានចាត់ជា adjectif non-qualificatif នោះ ត្រូវបានគាត់ចាត់ចូលក្នុងប្រភេទ *"déterminant"* ជាមួយនឹង article ដែរ ។

តទៅ យើងនឹងធ្វើការវិភាគដើម្បីឱ្យឃើញច្បាស់ថា តើគុណនាមកម្មសិទ្ធិ ពិតជាមានអត្ថិភាពនៅក្នុងភាសាខ្មែរមែនឬទេ? យើងនឹងលើកយកពាក្យ *"គាត់"* មកពិនិត្យពីមុខងារផ្សេងៗរបស់វា តាមរយៈល្បះ មួយចំនួន។ យើងសន្មតយកល្បះដូចតទៅ :

(១.ក) - *"ពូសុខ សង់ផ្ទះ "*

(១.ខ) - *"ខ្ញុំជួបពូសុខ"*

(១.គ) - *"ផ្ទះពូសុខ នៅក្បែរវត្ត"*

ដែលនាម *ពូសុខ* នៅក្នុងល្បះ(១.ក) គឺជាប្រធាននៃកិរិយាសព្ទ។ នៅក្នុងល្បះ(១.ខ) នាម *ពូសុខ* ជាកម្មបទ។ ឯនៅក្នុងកន្សោម *ផ្ទះពូសុខ* នៃល្បះ(១.គ) នាម *ពូសុខ* ជាគុណវិសេសន៍នៃនាម *ផ្ទះ* ។ បើយើងជំនួសនាម *ពូសុខ* នៃល្បះទាំងបី ខាងលើ ដោយពាក្យ *"គាត់ "*យើងបានល្បះថ្មី ដូចខាង ក្រោម :

(២.ក) - *"គាត់សង់ផ្ទះ "*

(២.ខ) - *"ខ្ញុំជួបគាត់ "*

(២.គ) - *"ផ្ទះគាត់ នៅក្បែរវត្ត "*

ដែលពាក្យ *"គាត់ "*ក្នុងល្បះ (២.ក) ជាប្រធាននៃកិរិយា *សង់; "គាត់ "*នៅក្នុងល្បះ (២.ខ)ជា កម្មបទនៃកិរិយាស័ព្ទ *ជួប; "គាត់ "* នៅក្នុងល្បះ (២.គ) ជាគុណវិសេសន៍នៃនាម *ផ្ទះ* ។

ការសាកល្បងនេះបង្ហាញថា ពាក្យ*គាត់* នៅក្នុងល្បះទាំងបីខាងលើសុទ្ធតែជំនួសនាម *ពូសុខ* ហើយវាមានលក្ខណៈរូបតែមួយ ទោះបីវាស្ថិតនៅក្នុងល្បះផ្សេងគ្នា។ មិនតែប៉ុណ្ណោះ ពាក្យ*គាត់* ក៏អាចបំពេញមុខងារផ្សេងៗ ដូចគ្នានឹងមុខងាររបស់នាម *ពូសុខ* ដែលវាជំនួសផងដែរ។ ទាំងអស់នេះ អាចបញ្ជាក់ថាពាក្យ *គាត់* នៅក្នុងល្បះ (២.ក), (២.ខ), (២.គ) នៅតែជាសព្វនាមទាំងអស់។ ដូច្នេះ តាមទិដ្ឋភាពរូប-សម្ព័ន្ធ យើងមិនអាច និយាយថា ពាក្យ*គាត់* នៅក្នុងកន្សោម *ផ្ទះគាត់* ជាគុណនាមកម្មសិទ្ធិឡើយ ទោះបីវាមានន័យសំគាល់ម្ចាស់កម្មសិទ្ធិក៏ដោយ។ ផ្ទុយទៅវិញ ពាក្យ *គាត់* នៅតែជាសព្វនាម និយាយឱ្យចំគឺ សព្វនាមបុរិសៈ ដែលត្រូវបានគេប្រើជាគុណវិសេសន៍របស់ *ផ្ទះ* ដើម្បី សំគាល់ន័យម្ចាស់កម្មសិទ្ធិ។ លក្ខណៈបែបនេះ គឺមិនខុសអ្វីពីកន្សោម *ផ្ទះពូសុខ* ដែលពាក្យ *ពូសុខ* នៅតែជានាម មិនអាចទៅជាគុណនាមកម្មសិទ្ធិ ដូច្នោះដែរ។

លទ្ធផលនៃការវិភាគខាងលើនេះ ស្របគ្នានឹងទស្សនៈរបស់លោក Georges Maspéro និងទស្សនៈរបស់លោកសាស្ត្រាចារ្យ ព្រុំ ម៉ល់។ នៅក្នុងស្នាដៃរបស់គាត់ លោក Georges Maspéro បាននិយាយដល់គុណនាមកម្មសិទ្ធិផងដែរ តែគាត់សរសេរថា *"តាមពិតទៅ ភាសាខ្មែរគ្មានគុណនាមកម្មសិទ្ធិទេ"* [៨]។ ចំណែកលោកសាស្ត្រាចារ្យ ព្រុំ ម៉ល់ សរសេរថា *"កាលណាគេនិយាយពីគុណនាមកម្មសិទ្ធិក្នុងភាសាខ្មែរ គឺ*

---

[៨] - Georges Maspéro, ***Grammaire de la langue khmère***, Op.cit., p.249 : *"L'adjectif possessif n'existe pas à proprement parler en khmer."*

*គេយកន័យជាបង្អែកផង ហើយគេយកវេយ្យាករណ៍បារាំងជាលំនាំផង ។ (...) បើកុំតែមានប្រភេទពាក្យនៃភាសាបារាំងជាប់ក្នុងស្មារតីអ្នកវេយ្យាករណ៍ខ្មែរ គេប្រាកដជាមិននឹកភ្នកទៅរកប្រភេទគុណនាមកម្មសិទ្ធិនេះទេ*[៩] ។ ដោយយកលក្ខណៈវិនិច្ឆ័យរូបវិធីជាមូលដ្ឋាន លោកសាស្ត្រាចារ្យ ព្រុំ ម៉ល់ ក៏បានធ្វើការបដិសេធនឹពីអត្ថិភាពនៃគុណនាមកម្មសិទ្ធិ និង សព្វនាមកម្មសិទ្ធិក្នុងភាសាខ្មែរ ដោយសរសេរថា *"ពុំមានប្រយោជន៍អ្វី នឹងនិយាយអំពី គុណនាមកម្មសិទ្ធិ ឬ អំពីសព្វនាមកម្មសិទ្ធិឡើយ"* [១០] ។

ការវិភាគខាងលើនេះ បង្ហាញឱ្យឃើញថា តាមលក្ខណៈរូប-សម្ព័ន្ធ យើងពុំចាំបាច់ធ្វើការបែងចែកគុណនាមក្នុងភាសាខ្មែរ ជាគុណនាមប្រក្រតី, ជាគុណនាមកំណត់ ដូចក្នុងភាសាខ្លះនៅអឺរ៉ុបឡើយ ។ ម្យ៉ាងទៀត យើងក៏ពុំចាំបាច់និយាយ អំពីអត្ថិភាពនៃគុណនាមកម្មសិទ្ធិក្នុងភាសាខ្មែរដែរ ព្រោះក្នុងភាសាខ្មែរ គេប្រើនាមឬសព្វនាមបុរិសៈ ជាគុណវិសេសន៍សម្រាប់ បញ្ជាក់ម្ចាស់កម្មសិទ្ធិ តែវាមិនមែនជាគុណនាមកម្មសិទ្ធិទេ ។

ដោយ **ប៊ី សុខគង់**
bsokkong@yahoo.com
ផ្នែកភាសានិងភាសាវិទ្យា

---

[៩] - ព្រុំ ម៉ល់ : *មេរៀនភាសាវិទ្យាអនុវត្តន៍* នៅរាជបណ្ឌិតសភាកម្ពុជា ២០០២ ។

[១០] - Prum Marc, "Analyse sommaire des structures du cambodgien", Op.cit., p.51: *"Il est absurde de parler d'adjectifs possessifs ou de pronoms possessifs en cambodgien."*

# គន្ថនិទ្ទេស


**ស្នាដៃជាភាសាខ្មែរ:**

-ក្រសួងអប់រំ : ***វេយ្យាករណ៍ ថ្នាក់ទី៨***, រោងពុម្ពរណសិរ្ស , ភ្នំពេញ ១៩៨៦។

-ក្រសួងអប់រំ : ***វេយ្យាករណ៍ ថ្នាក់ទី៧***, រោងពុម្ពរណសិរ្ស , ភ្នំពេញ ១៩៨៣។

-ព្រុំ ម៉ល់ : "លទ្ធភាពបង្កើតពាក្យ និងការបង្កើតពាក្យក្នុងភាសាខ្មែរ ", នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ*** នៃរាជបណ្ឌិតសភាកម្ពុជា , លេខ០២ មិថុនា ២០០១។

-នៅ ស៊ុន : "ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់ និង ភាសាមិនមែនអ៊ីសូឡង់" នៅក្នុង : Som Samnang (Ed.) ***ខេមរវិទ្យា*** volume II, ១៩៩៩។

-ឡុង សៀម : ***បញ្ហាវចនសព្ទវិទ្យាខ្មែរ***, ផ្សាយដោយអ្នកនិពន្ធ , ភ្នំពេញ ១៩៩៩។

- អៀវ កើស : ***ភាសាខ្មែរ***, បណ្ណាគារ មិត្តសេរី , ភ្នំពេញ ១៩៦៧។

**ស្នាដៃជាភាសាបរទេស:**

-Huffman Franklin, *Modern spoken Cambodia* , New Haven & London , Yale University Press , 1970;

-Judith Jacob, ***Cambodian linguistics , litterature and history***, School of Oriental and African Studies (London) 1993 ;

-Khin Sok, ***La grammaire du khmer moderne***, You Feng , Paris 1999 ;

-Lemaréchal Alain, ***Les parties du discours***, Presses Universitaires de France 1989 ;

-Long Seam , "contacts externes des langues Mon-Khmer ", in : ***Bulletin de l'École Française d'Extrême- Orient,*** Tome LXX, Paris 1981;

-Maspéro Georges, ***Grammaire de la langue khmère***, École française d'Extrêne -Orient , Imprimerie Nationale (Paris), 1915;

-Prum Marc , "Esquisse d'un cadre théorique pour une sociolinguistique systémique ", in: ***Cahier Ivorien de Recherche Linguistique*** – Décembre 1996, pp.155-186, Institut de Linguistique Appliquée,Université d'Abidjan, Côte d'Ivoire ;

-Prum Marc , ***Linguistique appliquée à l'enseignement*** , Université Nationale de Côte d'Ivoire, 1995;

-Prum Marc, ***Initiation à la Linguistique***,Université de Toliara (Madagascar),1990;

-Prum Marc , "Processus sociolinguistique de la transformation du système lexicologique du khmer ", in: ***Revue Tétralogiques*** , N° 7 - 1989, pp.61-73, UFR du Langage, Presses Universitaires Rennes II, France ;

-Prum Marc, " Notion de genre et de nombre en cambogien ", in : ***Bulletin de la Communauté Khmère d'Outre-Mer***, N° 3-1964, Paris ;

-Prum Marc, "Analyse sommaire des structures du cambodgien", in: ***Bulletin de la CommunautéKhmère d'Outre-Mer***, N° 2 – 1962 , Paris;

-Vogel Sylvain, " Introduction à une grammaire du secondaire pour le Cambodge", in : ***Cahiersd'Etudes franco-cambodgiens***, N°1-1994, Cercle de Linguistique Franco-Khmer de l'Université de Phnom Penh;

# ការសិក្សាស្រាវជ្រាវវចនស័ព្ទមួយចំនួននៅក្រុងប៉ៃលិន

នៅថ្ងៃទី៦-៨ ខែមីនា ឆ្នាំ២០០៨ ក្រុមស្រាវជ្រាវផ្នែកខេមរនីយកម្មវចនានុក្រមនិងបកប្រែនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជាបានធ្វើដំណើរឆ្ពោះទៅកាន់ក្រុង ប៉ៃលិន ដើម្បីធ្វើការស្រាវជ្រាវវចនស័ព្ទមួយចំនួន។

ក្រុមស្រាវជ្រាវយើងបានទទួលស្វាគមន៍ពីឯកឧត្តម *អ៊ិច សារូ* អភិបាលរងក្រុងប៉ៃលិន លោក *ឃ្លោក ទួយ* ជានាយខុទ្ទកាល័យសាលាក្រុងនិងមន្ត្រីខុទ្ទកាល័យ ក្រុងប៉ៃលិនយ៉ាងកក់ក្ដៅបំផុត ជាមួយនោះ ឯកឧត្តមបានផ្ដល់របាយការណ៍បូកសរុបលទ្ធផលការងារលើគ្រប់វិស័យរបស់ក្រុងប៉ៃលិនប្រចាំឆ្នាំ២០០៧ ដល់ក្រុមការងារយើង ។ បន្ទាប់មក ឯកឧត្តមនិងសហការីបានផ្ដល់ពាក្យមួយចំនួនដល់ក្រុមស្រាវជ្រាវយើង ដែលមានជាបន្តបន្ទាប់ដូចខាងក្រោមនេះ :

ឈ្មោះ តំបន់ និង ភូមិ សង្កាត់ មួយចំនួន ដូចជា *បតាំងស៊ូ*[១] *បហ៊ុយឆ្លើរ*[២] បយ៉ាខា ... ឯកឧត្តមមានប្រសាសន៍ថា ប្រភពពាក្យយ៉ាងណានោះ ឯកឧត្តមមិនដឹងទេ ទាល់តែជនជាតិកុឡាវ័យចំណាស់ទើបអាចដឹងបានខ្លះៗ។ ហើយ ពាក្យមួយចំនួនដែលឯកឧត្តមបានផ្ដល់មកនេះ ជាការយល់ឃើញផ្ទាល់ខ្លួនប៉ុណ្ណោះ។

១-**ភូមិ ឆ្លូង់រក្សា** (តាមសៀវភៅឈ្មោះខេត្ត ស្រុក ឃុំ និងភូមិរបស់ក្រសួងមហាផ្ទៃត្រង់ ទំព័រ៣៦៥៦ ឈ្មោះភូមិ លេខរៀង

ទី៩ ) អក្ខរាវិរុទ្ធត្រឹមត្រូវ គឺ «**អន្លង់រក្សា**» មកពី «**អន្លង់**» គឺ ជាកន្លែងដែលមានដក់ទឹកជាប្រចាំហើយជ្រៅ។

២-**បហ៊ុយលើ** (ប្រហែលជា)រណ្ដៅនៅផ្នែកខាងលើ។

៣-**បយ៉ាខា**[៣]

៤-**តាំងយូ** (អាចជាពាក្យជនជាតិកុឡា ?)[៤]

៥-**ឡាំបឿរ** (ពាក្យ កុឡា) ? ថ្មឱ្យមូល, «**បឿរ**» អាចមានន័យថា ជ្រុង កែង ...។

៦-**ហ៊ូ** ពាក្យ នេះទាក់ទងនឹងពាក្យឯទៀតដូចជា «**ហ៊ូពាន់**» គឺ មេក្បាលទ័ព កាន់ទ័ពខ្ទង់ពាន់។

៧-**ភ្នំខៀវ** ជាឈ្មោះហៅតាំងពីសម័យដើម ប៉ុន្តែ បច្ចុប្បន្ន គេហៅថា «ភ្នំប៉ោត»[៥] ។

---

[១] - [២] ពាក្យនេះ លោក ខុន សុភ័ក្ត្រ បានបកស្រាយនៅទំព័រខាងក្រោយ។

[៣] ពាក្យនេះ មានអ្នកខ្លះយល់ថា អាចជាពាក្យមកពីសៀមទេដឹង ? យើងនឹងសិក្សាស្រាវជ្រាវរកន័យជាបន្តទៀត ពីព្រោះ វាជាសម្មតិកម្មមួយ ផ្នែកវចនស័ព្ទ ដែលមានជាប់ទាក់ទងទៅនឹងជាតិពន្ធុ។

[៤] **តាំងយូរ** តាមវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ត្រង់ទំព័រ៣៥៨ថាពាក្យនេះមកពីភាសាចិន ទេ។

[៥] ឈ្មោះ**ភ្នំប៉ោត** នេះ យើងខ្ញុំនឹងលើកយកមតិរបស់លោក ខុន សុភ័ក្ត្រ មកបង្ហាញនៅទំព័រក្រោយ។

៨-**ភ្នំសារទ៉ាន់** ជាឈ្មោះភ្នំមួយក្នុងប្រជុំភ្នំខៀវដែរ ពីដើមមកមិនដឹងគេហៅថាភ្នំអ្វីទេ ប៉ុន្តែ នៅសម័យសង្គ្រាម ក្នុងទសវត្សឆ្នាំ១៩៨០និង១៩៩០ ពេលកងទ័ពខ្មែរទាំងសងខាងប្រយុទ្ធគ្នា សំឡេងកាំភ្លើងស្តាប់ទៅឮដូចជាគេទះ ស្គររាំសារវ៉ាន់ ក៏គេនាំគ្នាហៅភ្នំនោះថា «**ភ្នំសារទ៉ាន់**»រហូតមកដល់ បច្ចុប្បន្ន។

៩-ចំពោះពាក្យ «**ប**»នេះ មិនមាននៅតែប៉ៃលិនទេ នៅរតនៈគីរី ក៏មានឈ្មោះថា «ប»ដែរ ដូចជា «**បកែវ**» ... ហើយពាក្យ «**ប**» មានន័យថា «**អន្លង់, រណ្តៅ**...» ។

១០-ដើម្បីយក **ត្បូង** គេជីកយកដីដូចជាជីកយកដីខ្សាច់អីចឹងដែរ។ គេច្រកអាចម៍ដាក់ក្នុងការ៉ុងរួចហើយស្ទូចឬយោងពីរណ្តៅយកទៅរែងនៅក្នុងស្ទឹងឱ្យទឹកហូរនាំយកអាចម៍ដីចេញ។ ពីដើម កញ្រ្ចែង គេធ្វើពីឫស្សីត្បាញជាក្រឡាមានរន្ធល្អិតៗ ក្រោយមកកញ្រ្ចែង គេធ្វើពីដែកមានចោះរន្ធល្អិតៗ។

១១-**ត្បូងប៉ៃលិន** មានច្រើនពណ៌ល្អណាស់, **ត្បូង ពណ៌ខៀវ** គេហៅ **ត្បូង កណ្តៀង** រីឯ **ត្បូង ទទឹម**[6] មាន**ពណ៌ក្រហម** ដូច **ផ្កាទទឹម**។

១២-**កណ្តៀង** ជាឈ្មោះរុក្ខជាតិទឹក មាន២ប្រភេទ អាចធ្វើជាបន្លែស្លបាន ។

១៣-**ត្បូងថៃ** ជាការសម្គាល់សម្រាប់ហៅឈ្មោះត្បូងប៉ៃលិន ដែលមានគ្រាប់ល្អិតៗតូចៗមានតម្លៃថោកៗ ប្រហែលដូចជាត្បូងដែលពុំសូវមានតម្លៃនៅក្នុងប្រទេសថៃដែរ។ បច្ចុប្បន្ន គេបាននាំគ្នាហៅថា «**ត្បូងប៉ៃលិន**» វិញហើយ។

១៤-**ត្បូង កណ្តៀង** ជាត្បូង មានពណ៌ខៀវដូច ផ្កាកណ្តៀង។

១៥-ឯកឧត្តម មានបំណងចង់ស្នើសុំដល់ក្រសួងមហាឱ្យផ្ដូរឈ្មោះភូមិ «**បហ៊ុយខ្មែរ**» និងភូមិ «**បហ៊ុយខ្មែរត្បូង**»ពីព្រោះឈ្មោះភូមិទាំងពីរ បើជាភាសាសៀមគេនិយាយថា«**បហ៊ួខ្មួន**»បកប្រែមកជាភាសាខ្មែរថា «**ភូមិរណ្តៅ ក្បាលខ្មែរ**» ដែលមានន័យមិនល្អសម្រាប់ខ្មែរ ។

(ឯកឧត្តម បានហៅជាងត្បូង ម្នាក់ពីផ្សារ ប៉ាហ៊ី មកបន្ទប់ប្រជុំ ដើម្បីផ្តល់ពាក្យមួយចំនួនឱ្យក្រុមការងារយើង)។ លោក **គី ទាសនា** ជាជាងថ្នៃត្បូង កូនកាត់ម្នាក់ (ឪពុកជនជាតិកុឡា ម្តាយជាកូនចៅចិន) បានរៀបរាប់ប្រាប់ក្រុមស្រាវជ្រាវយើងថា ៖

១៦- **របៀបរកត្បូង** ការជីកត្បូងត្រូវចេះមើលដី តើជា*ដីកំណើតឬដីឡប់ខ្មៀ* ។

១៧-**ដីឡប់ខ្មៀ** គឺជាប្រភេទដីដែលគេជីកយកត្បូងរួចហើយ វាជាដីច្របូកច្របល់គ្នារវាងដីស្រទាប់លើនិងស្រទាប់ក្រោម។ ដីប្រភេទនេះ មិនមានត្បូងទេ ព្រោះគេជីកយកមួយសារហើយ។

---

[5] ឈ្មោះ**ភ្នំចោត** នេះ យើងខ្ញុំនឹងលើកយកមតិរបស់លោក ខុន សុភ័គ្គ មកបង្ហាញនៅទំព័រក្រោយ។

[6] **ត្បូងទទឹម** មាននៅក្នុងវចនានុក្រមខ្មែរទំព័រ៤០៥ ហើយក៏ជាឈ្មោះឈើស៊ីផ្លែដើមតូចម្យ៉ាងដែរ។ អ្នកខ្លះហៅ «**កន្ទឹម**» មិនត្រឹមត្រូវទេ។

១៨-**ត្បូង** មានទម្ងន់ធ្ងន់ជាងថ្ម។ ដីដែលមានត្បូងពណ៌ខៀវ គឺនៅប៉ៃលិន។ ត្បូងប៉ៃលិន គឺ ល្អទាំងអស់ហើយ ត្បូងដែលល្អស្អាត ជាងគេ គឺនៅ *ស្ទួនអំពៅ*។

១៩-**ត្បូងក្រហម (ទទឹម)និងត្បូងគង** ( **គង** ជាភាសាកុឡា គឺ **ពណ៌ទឹកត្រី**) មាននៅម្តុំ *បឹងព្រាលីត*និង *បឡាង*។

២០-**ដីឡូត** ដីកំណើត ដែលគេមិនទាន់ប៉ះពាល់ឬជីកយកត្បូងនៅឡើយ (លោកថា **ឡូត**[៧] គឺជាពាក្យកុឡា )។

២១-**ពណ៌** (ឬទឹកត្បូង) របស់ត្បូងមាន :

២២-**ត្បូងក្រហម** មានពណ៌ ដូចជា :

២៣-**ពណ៌ឈាមមាន់** (ប្រភេទទឹកត្បូង លេខ៣ ឬ ពណ៌លេខ៣ )

២៤-**ពណ៌ឈាមគ្រាប** (ប្រភេទទឹកត្បូងលេខ១ឬពណ៌លេខ១) ល្អជាងពណ៌ឈាមមាន់ គឺ មានពណ៌ក្រម៉ៅជាង ត្បូងទទឹម។

២៥-**ពណ៌ឈាមពពែ** មានពណ៌ឆើតជាងពណ៌ឈាមមាន់ គុណភាពលេខ២ បន្ទាប់ពីពណ៌ឈាមគ្រាប។

២៦-**ត្បូងពណ៌តាលេឡា** មាន៧ពណ៌ (ពណ៌ឥន្ទធនូ) ពេលពិនិត្យមើលវាឃើញប្រែពណ៌តាមពេល។**តាលេឡា** (ថៃហៅ **សាមស៊ី**) គឺ ពណ៌ខៀវខ្ចីឬខៀវចាស់។

២៧-**ត្បូង ពណ៌ផ្កាត្រប់** ជាប្រភេទត្បូងតាឡេឡា គុណភាពលេខ៤ (ពណ៌វាងស្វាយ ដូចផ្កាត្រប់វែង )។

២៨-**ត្បូងកណ្តៀង** មានទឹកខៀវចាស់ឬខៀវខ្ចី (បញ្ជាក់ឈ្មោះត្បូងប៉ៃលិនមានពីរប្រភេទ គឺ ត្បូងទទឹមនិងត្បូងកណ្តៀង)

២៩-**ពេជ្រថៃប៉ៃលិន**ពីមុនមកគេច្រើននាំគ្នាហៅថា«ពេជ្រថៃ»ពីព្រោះជាត្បូងពេជ្រពុំសូវមានតម្លៃដូចត្បូងដទៃ។

៣០-**ត្បូង ឆៅ** ជាត្បូងមិនទាន់ច្នៃ។

៣១-**ដីត្បូង** ដែលមិនទាន់រែង ហៅថា ដីឆៅ ។

៣២-**យីក** (ថៃ) របៀបរែងត្បូង បែបឧស្សាហកម្មទំនើប។

៣៣-**ត្បូងឆាំង** ត្បូងប្រេះស្រាំឬបែក (ប្រហែលជាពាក្យកុឡា ?) ជាត្បូង គ្មានទឹក។

---

[៧] ខ្មែរយើងមានប្រើពាក្យ **ឡូត** នេះដែរ ក្នុងវចនានុក្រមខ្មែរ ទំព័រ១៥៤៣ ថា *បំពង់តូចមានប្រហោងរហូត សម្រាប់ដាក់ប្រហាកខាងក្នុង ប្រហោងអ៊ីៗ* , ហើយ **ឡូត** ក៏ជាដើមរុក្ខជាតិម្យ៉ាង ច្រើនដុះនៅតាមមាត់ទឹក(ព្រែក ស្ទឹង ទន្លេ ...), ខ្មែរហៅមឈូសសម្រាប់ដាក់សព ដែលធ្វើពីឈើមិនសូវមាំដាក់ពីក្នុងមឈូសដែលគេធ្វើពីឈើល្អប្រកបក្បូរក្បាច់រចនាល្អវិចិត្រ ថា **ឡូត** ដែរ។ នៅពេលបូជា គេលើក **ឡូត** ចេញពី មឈូស ដែលសម្រាប់តែដាក់លម្អនោះ។ ការដែលគេធ្វើ **ឡូត** នេះ គឺសម្រាប់អ្នកដែលទីទាល់ក្រឬសម្រាប់ទីដែលក្រខ្សត់ឈើធ្វើមឈូស។ ចំពោះពាក្យ**ឡូត** ថាជាពាក្យរបស់កុឡា ក្រុមស្រាវជ្រាវយើងមិនទាន់ឯកភាពឡើយ ការលើកឡើងនេះ គ្រាន់តែជាមតិរបស់លោក គឺ វាសនា ដែលលោកប្រើជាទម្លាប់តាំងពីដើមមក ដោយគ្មានការសិក្សាស្រាវជ្រាវពីពាក្យនេះតែប៉ុណ្ណោះ។ តែ នេះក៏ជាសម្មតិកម្មមួយទៀត ដែលជាពន្លឺមួយក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមវចនស័ព្ទយើងទៅថ្ងៃក្រោយ។

៣៤-**ត្បូងថាយឡាយ** ជាត្បូងបែកតែនៅមានទឹកខ្លះ (ភាសាកុឡា ?)។

៣៥-**កុងសែ** (ពាក្យកុឡា ? ) អ្នកទិញត្បូង លក់ត្បូង (ឈ្មួញកណ្តាល)។

៣៦-**កុងសែក្លាង** អ្នកដើរទិញត្បូង តាមរណ្តៅត្បូង។

មុននឹងច្នៃត្បូង គេត្រូវមើលតាមទឹករបស់ត្បូងជាមុនសិន ទឹកណាត្រូវយកទៅដុត គេត្រូវយកវាទៅដុតសិន ប៉ុន្តែ មុននឹងដុតត្រូវយក ត្បូងទៅត្រាំទឹកអាស៊ីត២យប់២ថ្ងៃ ដើម្បីឱ្យជ្រះដីជ្រះថ្មពីសាច់ត្បូង។ ការដុត គឺ ដុតនឹងធ្យូងថ្ម ដើម្បីឱ្យត្បូងប្រែពណ៌(នៅស្រុកខ្មែរចេះដុតត្រឹមតែត្បូងពណ៌ខៀវទេ បើគេចង់ដុតត្បូងពណ៌ ក្រហមត្រូវយកទៅដុតនៅប្រទេសថៃ)។

៣៧-**ត្បូងដុត** ល្អស្រឡះជាងត្បូងមិនទាន់ដុត ត្បូងឆ្នៃរួចហើយមិនទាន់ដុតមានទឹកសរសៃៗ ស្រអាប់ក្នុងសាច់ ត្បូងដែលពាក្យកុឡា ហៅថា *ម៉ា*។

៣៨-**ត្បូងសន្លាល្អ** ហៅថាផលិន ។

៣៩-**ពេជ្រប៉ៃលិន** មានពណ៌ សទឹកភ្លៀង ទឹកអំពៅ បើពណ៌សស្លេក គឺ គេយកពេជ្រពណ៌ទឹកឃ្មុំទៅដុត។

៤០-**ត្បូង មានប្រជ្រុយ**[៨] គឺ ត្បូងមានស្នាមក្នុងសាច់ត្បូង។

លោក គី **វាសនា** ប្រាប់ពួកយើងថា ត្បូងបែកនិងត្បូងមានប្រជ្រុយ គេមិនប្រកាន់ទេ។ ការជ្រើសរើសប្រើ រវាងត្បូងបែកនិងត្បូង ប្រជ្រុយភាគច្រើន គេច្រើនយកត្បូងមានប្រជ្រុយជាង។ លោកបានប្រាប់យើងថា ជនជាតិកុឡានៅប៉ៃលិនសព្វថ្ងៃមានប្រហែល ៤-៥នាក់ប៉ុណ្ណោះ, ប៉ុន្តែ បើតាមប្រសាសន៍របស់ឯកឧត្តម *អ៊ិច សារូ* ថា ជនជាតិកុឡារស់នៅប្រទេសបារាំងសព្វថ្ងៃមានចំនួន ១០ម៉ឺននាក់។

៤១ -**ត្បូងពណ៌ក្រហម** ថ្លៃជាង**ត្បូងពណ៌ខៀវ**។

ក្រុមស្រាវជ្រាវយើងបានជួបអ៊ំប្រុសម្នាក់ឈ្មោះ *អែម វ៉ាន់ឌី* ជាប្រជាជននៅភូមិក្រចាប់ សង្កាត់ អូរតាវ៉ៅ ខ័ណ្ឌប៉ៃលិនក្រុង ប៉ៃលិន បានប្រាប់ពួកយើងថា :

៤២-**ករន្ទៀង** ជារុក្ខជាតិម្យ៉ាង ដើមវាតូចៗមាន មើម ដើម ស្លឹក និង ផ្កា ដូចជាទាល់ (ដើមទាល់) តែដើមនិង ស្លឹកវាងវលោង ជាងដើមទាល់ ដើមវាមានក្រឡាដូចពស់ថ្លាន់ គេអាចយកវាមកធ្វើបន្លែស្លបាន។

៤៣-**កណ្តៀង** ជាឈ្មោះរុក្ខជាតិទឹកម្យ៉ាង (វារិជជាតិ) ដុះដូចម្អម មានរសជាតិល្វីងៗអាចស្លបាន មានផ្កាល្អិតៗ ពណ៌ខៀវប្រៀបបាននឹងពណ៌ត្បូងកណ្តៀង។

---

[៨] លោក *គី វាសនា* យល់ថា **ត្បូងប្រជ្រុយ** គេមិនប្រកាន់ គឺ សំដៅលើត្បូងពេជ្រប៉ៃលិន។ ប៉ុន្តែ តាមអបិជំនឿដែលគេតែង តែជឿតៗគ្នាតាំងពីដើមរៀងមក ប្រសិនបើ គេទិញត្បូងពេជ្រ (ពណ៌ស) គេត្រូវពិនិត្យមើលយ៉ាងប្រយ័ត្នប្រយែងបំផុត ពីព្រោះ គេខ្លាចទិញប៉ះចំត្បូងពេជ្រមានប្រជ្រុយ ដែលគេមានជំនឿថា អាចនឹងធ្វើឱ្យម្ចាស់មានរាសីធ្លាក់ដោយខាតបង់ទ្រព្យ លាភសក្ការៈ ឬ អាចមានឧបទ្វវហេតុផ្សេងៗជាដើម។

អ៊ំប្រុសមានប្រសាសន៍ថា ភូមិកន្ទៀងវ៉ា អាចជាភូមិកណ្ដៀងវ៉ាច្រើនជាង ពីព្រោះ សង្កាត់ស្ទឹងត្រង់ជាតំបន់សម្បូរត្បូងកណ្ដៀងណាស់។ រីឯ ពាក្យ «វ៉ា»[៩] ជាសន្ដានពាក្យដែលជាប់មកពីភាសាដទៃ(ថៃ)ទេ។ ដូចជា **«ប្រឡាយ»** អ្នកខ្លះហៅ **« ឆត់វ៉ង»**, ពាក្យថា **«ក្របីហាច់»** គឺក្របីលោតកញ្ចែងកញ្ចាត់, **« ដើមចន្ទល់ភ្នំ»** អ្នកខាងថ្មពួក ហៅថា **«ដក់ទែន»**, ពាក្យ **«ចាក់រូបទេវ»** ខ្មែរក្រោមហៅ **«នំគ្រប់លេខ»**, ពាក្យ **«ខ្ទឹម»** អ្នកខាងស្វាយរៀង ហៅថា **«តយ»**, **«ម្រេច»** ហៅ **«ធីទ»**, ខ្នុរត្នោតហៅថា **«ចាន»** តាមភាសាយួនជាដើម។

ក្រុមស្រាវជ្រាវយើង បានទទួលពាក្យមួយចំនួនពីលោក **ខុន សុភ័ក្ត្រ** ជាគ្រូបង្រៀនអនុវិទ្យាល័យ នរា ខេត្តបាត់ដំបង ហើយសព្វថ្ងៃ គាត់កំពុងតែសិក្សាបន្តយកបរិញ្ញាប័ត្រ ផ្នែកអក្សរសាស្ត្រខ្មែរនៅសាកលវិទ្យាល័យខេមរៈក្រុងបាត់ដំបង។ លោកគ្រូបានរួមដំណើរក្នុងការស្រាវជ្រាវនេះជាមួយក្រុមយើងខ្ញុំដែរ លោកបានផ្ដល់និងបកស្រាយពាក្យមួយចំនួន ដូចខាងក្រោម :

**៤៤-បយ៉ាខា**[១០] (សៀម *បយ៉ាខាប់*) គឺ **អណ្ដូង យាយខ្ញុំ**។

លោកបានបញ្ជាក់ថា អណ្ដូងរបស់ជនជាតិកុឡាមានរាងជាផ្កាត្រកួន មានបាតប្រហែល២ទៅ៣ម៉ែត្រ មាត់លើរីកធំទៅតាមអណ្ដូងតូចធំ, គេរៀបថ្មពងតម្រៀបគ្នាផ្ទប់តាមផ្ទៃជញ្ជាំងអណ្ដូងយ៉ាងជិតឡើងមក លើមើលពុំឃើញសាច់ដីទេ។

**៤៥ -ភ្នំយ៉ាត** គឺ **ភ្នំយាយ**[១១]។

---

[៩] ចំណាំ ក្នុងភាសាខ្មែរមានពាក្យ**«ចត្តវ៉ា»** ដែលខ្មែរមួយចំនួនលោកច្រើននិយាយគន្លាស់លេងសើចថា **«ទៅវ៉ាលោកតាត់»** គឺ ប្រែថា **«ទៅចត្តលោកតា»**, ការពិត **«វ៉ា»** នេះ ជាពាក្យខ្មែរសុទ្ធមិនមែនជាពាក្យ «ថៃ»ទេ។ ដូច្នេះការអះអាងរបស់លោកអ៊ំ *អែម វ៉ាន់ឌី* មិនទាន់ពិតប្រាកដទេ។

[១០] តាមការពន្យល់របស់កញ្ញា *ហ៊ាបទី ឬក្សូឌី* ជាកូនចៅខ្មែរសុរិន្ទនិងជានិស្សិតភាសាខ្មែរឆ្នាំទី៤មហាវិទ្យាល័យមនុស្សសាស្ត្រសង្គមសាស្ត្រនៃសាកលវិទ្យាល័យមហាសារខាមប្រទេសថៃ ដែលមកធ្វើកម្មសិក្សាភាសាខ្មែរនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជាចំនួន៣ខែ បានពន្យល់ពាក្យ**«បយ៉ាខា»** នេះថាមានថ្នាក់ពាក្យជា(ន.) **អណ្ដូងដែលមាន ស្បូវនៅជុំវិញ**។

[១១] ប្រវត្តិភ្នំយ៉ាត មានក្នុងប្រជុំរឿងព្រេងខ្មែរភាគទី៦ថា ឈ្មោះភ្នំយ៉ាតនេះ គឺយកតាមឈ្មោះប្ដីប្រពន្ធពីរនាក់ដែលមានឈ្មោះយ៉ាតដូចគ្នា។ តាមប្រសាសន៍របស់លោកគ្រូ **ខុន សុភ័ក្ត្រ** ថា ពីសម័យដើម កាលដែលគាត់នៅពីក្មេង*ភ្នំយ៉ាត* ភាគច្រើនសម្បូរដូនជីមកសំណាក់ធម៌កុះករ។ ប្រហែលជាដូច្នេះហើយទើបបានជាគេនាំគ្នាហៅថា*ភ្នំយាយៗ* រួចក៏ក្លាយមកជា*ភ្នំយ៉ាត* យ៉ាងដូច្នេះ ? លោកថា ម្យ៉ាងទៀតអាចជា ពាក្យខ្មែរលាយពាក្យសៀម (ភ្នំ គឺ ខ្មែរ, យ៉ា គឺពាក្យសៀម

៤៦-**មហាធាត**[១២] ជាឈ្មោះតំបន់ត្បូងមួយកន្លែងនៅក្នុងប្រជុំភ្នំខៀវដែរ « **អណ្តូង៥ធាត** »ៗ

៤៧-**មប៉ៃលិន**[១៣] ទៅលេងអណ្តូង។

៤៨-**ត្បូងពេជ្រ** លោក ខុន សុភ័ក្រ្ត យល់ថា ( *ត្បូង គឺ ក្បាល* ; រីឯ *ពេជ្រ* គឺ ជាលទ្ធផលដែល កើតចេញមកពីបន្ទុះភ្នំភ្លើង ដែលកម្តៅភ្លើងបានរំលាយ ថ្ម ដី លោហៈ និង វត្ថុផ្សេងៗទៀតនៅក្នុងដី រួចហើយវត្ថុទាំងនោះរលាយហូរស្រក់ជាដុំតូច (មានតិចតួចលាយឡំជាមួយដុំថ្ម ដុំក្រួសឯទៀត) ក្លាយជា ទ័រ នៅក្នុងដី។ ឯដីត្បូងពេជ្រនោះ បង្កើតបានជាដុំពន្លឺ (ជាពន្លឺធម្មជាតិ) ។[១៤]

៤៩-**បតាំងស៊ូ** ក្លាយមកពីពាក្យ ***បតាំងស្វយ***[១៥] ជាពាក្យដែលមានន័យសរសើរពីទឹកដីខ្មែរ មិនមែនមានន័យបន្តុះបង្អាប់ ដូចពាក្យដែលហៅឃារមកថា «**បហ៊្វូរខ្នុន**»ឬ«**បហ៊ុយខ្នុ**»ដែលមានន័យក្នុងភាសាថៃថា «**អណ្តូងក្បាលខ្មែរ**» នោះទេ។

---

ប្រែជាខ្មែរថា យាយ)?។ នេះគ្រាន់តែជាការអះអាងរបស់លោកសុភ័ក្រ្ត ផ្ទាល់នតែប៉ុណ្ណោះ។ ចំពោះយើងយល់ឃើញថា ពាក្យ*ភ្នំយ៉ាត* នេះ មិនមានជាប់ទាក់ទងទៅនឹងពាក្យសៀមទេ ពីព្រោះ ពាក្យ*យ៉ាត* នេះ ប្រជាជនខ្មែរមួយចំនួនក៏មានឈ្មោះ *យ៉ាត* ដូច្នេះដែរ សូម្បីតែព្រះមហាក្សត្រខ្មែរមួយព្រះអង្គក៏មានព្រះនាមថា *យ៉ាត* ដែរ គឺ *ព្រះបាទពញាយ៉ាត*។

[១២] លោក ខុន សុភ័ក្រ្ត យល់ថា តំបន់ប៉ៃលិននេះមានឋាននាមជាច្រើនសម្បូរទៅដោយពាក្យសៀម ពីព្រោះក្នុងសម័យមុន ប៉ៃលិន, បាត់ដំបង, សៀមរាប, ម្លូព្រៃ...ជាដើមនេះ បានធ្លាក់ក្នុងកណ្តាប់ដៃសៀមមួយរយៈប្រវត្តិសាស្រ្តក៏មានបញ្ជាក់។ ដូច្នេះហើយបានជាមានតំបន់និងភូមិឋានមួយចំនួនមានជាប់ជំពាក់ទៅដោយភាសាសៀមយ៉ាងដូច្នេះ។ យើងយល់ថា នេះជាមតិបកស្រាយរបស់លោក ខុន សុភ័ក្រ្ត ផ្ទាល់តែប៉ុណ្ណោះ។ ចំពោះ យើងយល់ថា ពាក្យនេះអាចមានន័យផ្សេងពីនេះ ដែលឋិតជាសម្មតិកម្មនៅឡើយ។ យើងអាចធ្វើការស្រាវជ្រាវពីវចនស័ព្ទនេះបន្តទៀត ដើម្បីស្វែងរកឱ្យឃើញនូវប្រភពពាក្យនេះ ចៀសវាងយើងនាំគ្នាយល់ថា វាជាពាក្យរបស់ជនជាតិដទៃ ដោយផ្តល់តម្លៃឱ្យទៅជនជាតិគេ ដែលមានកំណើតពូជសាសន៍កើតក្រោយជនជាតិខ្មែររាប់ពាន់ឆ្នាំ ហើយទន្ទឹមនឹងនោះ ជាតិខ្លះបាននាំយក ភាសា អក្សរ វប្បធម៌ ប្រពៃណី ខ្មែរទៅធ្វើជារបស់ខ្លួន ហើយមួយរយៈក្រោយមកស្រាប់តែយើងនាំគ្នាយល់ថា យើងយកពាក្យគេមកប្រើទៅវិញ ?

[១៣] ក្រុមស្រាវជ្រាវយើងយល់ថា នេះជាការយល់ឃើញមួយចំណែករបស់លោកគ្រូ សុភ័ក្រ្ត, ចំពោះប្រវត្តិពាក្យ«**មប៉ៃលិន**» ខ្មែរយើងមានចុះក្នុងសៀវភៅប្រជុំរឿងនៅព្រេងភាគទី៦រួច ដែលបាននិទានថា*ប៉ៃលិន* ជាពាក្យក្លាយមកពីពាក្យ*ភៃលេង* ដែលជនជាតិកុឡាបានហៅ។ ក្រោយពេលដែលពួកបារាំងបានចូលមកធ្វើជាអ្នកអាណាព្យាបាលខ្មែរ បារាំងបានសរសេរពាក្យ *ភៃលេង* ជា*ប៉ៃលិន* អក្សរឡាតាំង PAILIN។

[១៤] ការពន្យល់នេះ គឺជាការយល់ឃើញរបស់លោកគ្រូ ខុន សុភ័ក្រ្ត ប៉ុណ្ណោះ។

[១៥] លោក ខុន សុភ័ក្រ្ត បានបញ្ជាក់ថា ពាក្យ «**បហ៊្វ**»ឬ«**បហ៊ុយ**» មិនដែលឮគេប្រើពីមុនមកទេ, ពីមុនគេហៅថា «**បតាំងស្វយ**» ឬ «**បតាំងស៊ូ**» ។

៥០-**ភ្នំជ៉ាត** ពីដើមភ្នំនេះមានឈ្មោះហៅថា«**ភ្នំបេខ**»។ នៅសម័យសង្គ្រាម គេនាំគ្នាហៅភ្នំនេះថា «**ភ្នំជ៉ាត**» បានជាគេហៅយ៉ាងដូច្នេះ ពីព្រោះ ពេលនោះនៅលើភ្នំនេះមានគេពាក់ប៉ោតលើបង្គោលធ្វើជាសញ្ញាបង្ហាញថាជាសមរភូមិ។ ពីដើមនៅជើង «**ភ្នំបេខ**» នេះ មានអូរមួយ គេហៅថា «**អូរបេខ**», ទីនេះ ពួកកម្មករជីកត្បូងពេជ្រ ផ្សងគ្រោះថ្នាក់ណាស់ ពីព្រោះ រណ្ដៅត្បូងមានជម្រៅជ្រៅលើសពី១០ ម៉ែត្រក៏មានជ្រោះហូតដល់មានពុលកម្មករទៀតផង។

៥១-**ភ្នំខៀវ** គេរាប់តាំងពីជើងភ្នំបញ្ហីយប្ញបតាំងស្ទួយឡើងទៅលើរហូត គឺ នៅប៉ែកខាងលិចនិងខាងត្បូងភ្នំទឹកចេញទាំងភ្នំជីងចក់ នៅខាងលិចភ្នំយ៉ាតសព្វថ្ងៃ។ ភ្នំខៀវមានច្រើនស្រទាប់ណាស់ កំពូលខាងលើគេ គឺ ភ្នំពពកវិល។

៥២-**ភ្នំពពកវិល** ជាកំពូលភ្នំខៀវដែលខ្ពស់ជាងគេ នៅទីនោះសម្បូរសត្វ ខ្លា ដំរីធំៗ និង សម្បូរសត្វទោចផងដែរ បើនិយាយពីត្បូង ពេជ្រវិញ ទីនោះក៏សម្បូរណាស់ដែរ។

៥៣-**ក្បាលផាយ** គឺជាកន្លែងមួយដែលគេលើកដុំថ្មធំតូចរៀបតម្រួតលើគ្នាកាត់ស្ទឹង ដើម្បីបញ្ហាល់ទឹកស្ទឹងឱ្យឡើងខ្ពស់ ហើយហៀរហូរចូលតាមយ៉រ។ *ក្បាលផាយ* នៅក្បាលស្ទឹងខាងលើម្តុំស្ពានអូរតងដែលបាក់ទៅសព្វថ្ងៃទីនោះ ពីដើមមានស្ពានឃោលមួយសម្រាប់ឆ្លងទៅត្រើយម្ខាង។ គេបង្ហូរទឹកពី*ក្បាលផាយ* មកតាម«*យ៉រ*» (ដែលយើង ហៅថា«*ទំនប់*» ឬ«*ប្រឡាយ*», «*យ៉រ*» នេះ សម្រាប់ បង្ហូរទឹកស្រោចស្រពដំណាំផ្សេងៗ ដូចជាសារម៉ាវ, ទុរេន, មង្ឃុត, ចេក... និង ថូររកត្បូង) ដោយបិទទឹកនៅចុង«*យ៉រ*» មិនឱ្យហូរ ទៅណានៅពេលដែលទឹកហូរពេញ យ៉រហើយ ទើបគេអាចបង្ហូរទៅតាមផ្នែកផ្ទៃដីនៅខាងក្រោមយ៉រ តាមចិត្តដែលគេចង់បាន គឺបានន័យថា បង្ហូរទឹកពីទីខ្ពស់ទៅទីទាប ដើម្បីឱ្យងាច់ជ្រះដីដែលនៅជាប់នឹងដី ដុំថ្ម ដុំក្រួសងាយស្រួលរកមើលដី ដែលជាដុំត្បូង។ វិធីនេះ គេហៅថា «*ថូរ*» ដើម្បី ស្វែងរកគ្រាប់ត្បូង។

សូមបញ្ជាក់ថា ការរកត្បូងពេជ្រតាំងពីសម័យដើមមក បើតាមការរៀបរាប់របស់លោក ខុន សុភ័ក្ត្រ គឺមានបីដំណាក់កាលដូចតទៅ :

ក/-សម័យដើមឬជំនាន់ទី១ : គេនាំគ្នាដើររើសត្បូងពេជ្រ ។

ខ/-សម័យបន្ទាប់ឬជំនាន់ទី២ : គេបង្ហូរទឹកពីក្បាលផាយមកតាមយ៉រ ដោយបិទទឹកមិនឱ្យហូរទៅណានៅពេលដែល ទឹកហូរជ្រះដី គេហៅថា *ថូរ* ទើបគេ ដើររើសត្បូង ពេជ្រ។

គ/-សម័យក្រោយមកឬជំនាន់ទី៣ : វិធីរកត្បូង គឺ គេជីកដីយកដីមករែង មានអណ្ដូង រណ្ដៅ ឬ បហែង ដែលជាការជីកដីលើខ្នងភ្នំ សើៗឬបុសដីយកដី ហៅថា *អណ្ដូងស្អូត* ។

ឃ/-ក្រុមអ្នកស្រាវជ្រាវយើងយល់ថា ការរកត្បូងពេជ្រនៅប៉ៃលិននេះ មានមួយដំណាក់កាលទៀត គឺ ដំណាក់កាលទី៤ ដំណាក់កាលនេះ ការរកត្បូង គឺ គេជីកយកត្បូងពេជ្រដោយគ្រឿងចក្រ មានម៉ាស៊ីនរែងត្បូងទំនើបៗជាដើម។ ដំណាក់កាលទី៤ នេះហើយដែលនាំ ឱ្យអស់ត្បូងពីប៉ៃលិន ។

សូមបញ្ជាក់ថា នៅផ្នែកខាងលើ *ក្បាលផាយ* ហៅថា *ទឹកធ្លាក់ដងជ្រោះ* ទឹកធ្លាក់ខាងលើហៅថា *អូរតាផៃ* ទីនេះជាទឹកជ្រោះជ្រាបចេញពីលើជួរដងភ្នំខៀវ បើឡើងពីអូរតាផៃមានស្រទាប់ភ្នំឡើងចុះៗ មានទឹកហូរធ្លាក់យ៉ាងស្អាត។ បើយើងឡើងរហូតទៅខាងលើគ្មានទឹកទេ ពីព្រោះ ទឹកជ្រាបតាមភ្នំខ្សាយទៅៗ។ ផុតពីនេះទៅ ខ្នងភ្នំជាន់ខាងលើមានកូនស្ទឹងតូចមួយមានទទឹងប្រវែងប្រហែល៦-៧ ម៉ែត្រ ទឹកជម្រៅត្រឹមចង្កេះ។ ស្ទឹងនេះ ចែកជាច្រើនផ្នែកហូរធ្លាក់មកដល់ សំឡូត បឡាង និងស្ទឹងសង្កែបាត់ដំបង។ ស្ទឹងនេះ កន្លែងខ្លះចែកជាបី ហើយមានឆ្លាក់តួអក្សរថៃនៅនឹងដើមឈើធំថា «អូរសាមង៉ាម» [16] ទីនេះសម្បូរត្បូងពេជ្រ ហើយក៏ជាកន្លែងដែលប្រកបដោយគ្រោះថ្នាក់ណាស់ដែរ ពីព្រោះ សម្បូរ ខ្លា ដំរី គួរឱ្យខ្លាច។ អ្នកស្នាក់អាស្រ័យបណ្ដោះអាសន្ន ដើម្បីស្វែងរកត្បូងនៅទីនោះ មាន ខ្មែរ ព្នង កុឡា តែងតែប្រាប់គ្នីគ្នាឱ្យប្រុងប្រយ័ត្ន ចំពោះ ជនជាតិថៃ ដែលលបលួចចូលមករកជីកត្បូងពេជ្រ ហើយប្រសិនបើ ពួកគេជួបប្រទះនឹងពួកយើង គឺ ពួកគេអាចប្លន់យើងយកត្បូងពេជ្រអស់គ្មានសល់ ពីព្រោះ ពួកគេមានកាំភ្លើងប្រើ។

ម្យ៉ាងទៀត ពួកគេក៏ខ្លាចពួកម្ចាស់ស្រុកនៅទីនោះចាប់ពួកគេដែរ។ ចាប់ពីបហ្លួយទៅដល់ព្រំប្រទល់ដែននិងក្នុងដែនដីថៃមាន ត្បូងពេជ្រទឹកខ្ចីស្រាលៗ ប្រហាក់ប្រហែលនឹងត្បូងយើងនៅប៉ៃលិនត្រង់បហ្លួយ ដែរដែលមានទឹកខ្ចីស្រាល ហើយដែលពីមុនមកគេច្រើនហៅថា«ពេជ្រថៃ»។ តាមការពិត ត្បូងពេជ្រនេះ ខ្លះមានពណ៌ទឹកភ្លៀងខ្លះពណ៌ទឹកឃ្មុំផ្អិត។ ដោយសារតែពីសម័យមុនសម្បូរត្បូងពេជ្រល្អៗ នៅពេលគេឃើញពេជ្រមួយប្រភេទនេះមានទឹកប្រហាក់ប្រហែលគ្នានឹងត្បូងពេជ្រអន់ៗ ដែលមានក្នុងទឹកដីថៃ គេក៏នាំគ្នាហៅថា«ពេជ្រថៃ»ៗ ទៅ ពីព្រោះ ជាពេជ្រមានទឹកខ្ចីៗ។

៥៤-**កំប្រោងមុខត្បូង** គេធ្វើពីដើមរុក្ខជាតិម្យ៉ាង ដែលមានរាងដូចដើមពក ប៉ុន្តែ សាច់វាវែងជាងពក [17]។

៥៥-**ត្បូងគង** គឺជាត្បូងពេជ្រ មួយក្រុមផ្សេងទៀត ដែលមានពណ៌ក្រហមចាស់មិនសូវឆ្អុះចាំង។ លោក ខុន សុភ័ក្ត្រ បានភ្ជាប់ពាក្យ *គង* នេះថា ខ្មែរយើងប្រើពាក្យ *គងលង* > *គលង* > *គ្លង* ជាគូគ្នារវាងប្រុសនិងស្រី។ ប្រហែលជាគាត់ចង់បង្ហាញថាត្បូងពេជ្រគង ជាគូគ្នាជា មួយ និងត្បូងទទឹម ឬត្បូងកណ្ដៀង ទេដឹង ?

៥៦- **ត្បូងពេជ្រនិល** ជាត្បូង ដែលមានពណ៌ខ្មៅខៀវ។

៥៧-**ត្បូងពេជ្រម៉ា** ជាត្បូង ដែលមានពណ៌ដូចពណ៌គ្រាប់ផ្អែកសេះ។

៥៨-**ត្បូងពេជ្រទឹកភ្លៀង** ជាត្បូង ដែលមានពណ៌ដូចទឹកភ្លៀង។

៥៩-**ត្បូងតារលឡា** ជាត្បូង ដែលមានពណ៌ច្រើនយ៉ាង។

---

[16] ជនជាតិថៃ តែងតែលបចូលមកក្នុងទឹកដីខ្មែរដើម្បីស្វែងរកជីកត្បូងពេជ្រនេះ ហើយដោយ សារទីនោះក្នុងព្រៃស្ងាត់ ពួកនេះក៏ឆ្លៀតឆ្លាក់អក្សរថៃនៅទីនោះ។

[17] តាមការរៀបរាប់របស់លោក ខុន សុភ័ក្ត្រ ពីដើមរុក្ខជាតិម្យ៉ាងនេះ, យើងសន្និដ្ឋានថា ប្រហែលជាពួកឫស្សីម្យ៉ាង, ពីព្រោះ ពក នេះគេហៅ ថា ឫស្សីពក, តាមការពន្យល់ខាងលើ អាចជា ដើមឫស្សីឈ្លោឬដើមឫស្សីងកម៉ៃ (ដើមស្រាលៗ ធ្វើជាកន្ត្របេះផ្លែឈើ) ទេដឹង ?

៦០-**ត្បូងពេជ្រកណ្ដៀង ឬត្បូងកណ្ដៀង** មានពណ៌ខៀវដូចផ្កាកណ្ដៀង។

៦១ -**ត្បូងទទឹម** មានពណ៌ដូចពណ៌ផ្កានិងគ្រាប់ទទឹម។

៦២-**ត្បូងទឹកឃ្មុំ** មានពណ៌ដូចដំណក់ទឹកឃ្មុំផ្អិត។

**ការសម្គាល់ទម្ងន់ត្បូង** :

រង្វាស់ខ្នាតទម្ងន់ ត្បូង តូចបំផុត *មួយខិ* គឺស្មានប្រហែល ប៉ុននឹងគ្រាប់សណ្ដែកបាយ។

ខ្នាតទីពីរ ២ខិ = ១ការ៉ាត់ , ស្មានប៉ុនគ្រាប់ពោត = មួយការ៉ាត់។

ខ្នាតទីបី គឺ គេគិត ៧ ការ៉ាត់ = មួយភ្លង , ជាខ្នាតធំមានចំនួនថ្លៃលើសលុបបំផុត។

ឯតម្លៃគ្រាប់ត្បូងពេជ្រតូចធំ អាស្រ័យទៅលើទឹកត្បូងពេជ្រផ្ទាល់ ទឹកដែលខ្ពស់ជាងគេ ហៅថា «ទឹកវិសេត» ដែលជាត្បូងពេជ្រ ល្អពិសេស គឺ ពណ៌បន្សុត តែមួយ។

ខាងក្រោមនេះជា ពាក្យបានមកពីការផ្ដល់ឱ្យដោយកញ្ញា ឋាបនី ឬក្សឹ :

៦៣-**បខិនឆៀង** (ន.) អណ្ដូងដីឥដ្ឋ ។

៦៤-**បឡាង** (ន.) អណ្ដូង ដែលទុកសម្រាប់ដុសលាងឬធ្វើសម្អាត ។

៦៥- **ប** (ន.) អណ្ដូងទឹក ។

៦៦- **ប** (កិ.) (ពាក្យកាព្យ) មិនមាន, អត់មាន ៗ

៦៧ - **ហ៊ុយ ឬ ហ្វួយ** (ន.) កូនព្រែក, ជ្រោះ , អូរ។

៦៨ -**យ៉ាខា** (ន.) ស្បូវ ។

៦៩ - **បយ៉ាខា** *(ន.)* អណ្ដូងដែលមានស្បូវដុះជុំវិញ ។

ការទទួលព័ត៌មានខាងលើនេះ យើងឃើញថា ពាក្យមួយចំនួនមានលក្ខណៈខុសៗគ្នា។ ការចេះចាំប្រវត្តិពាក្យនីមួយៗ មិនដូចគ្នា មកពីអ្នកផ្ដល់ព័ត៌មាន ទីមួយ ជាមនុស្សចំណូលថ្មី, ទីពីរ ជាមនុស្សដែលធ្លាប់រស់នៅប៉ៃលិនតាំងពីសម័យមុន (នៅក្មេងវ័យនៅឡើយ) និងទីបី អ្នកផ្ដល់ព័ត៌មានឱ្យជាកូនចៅខ្មែរសុរិន្ទសញ្ជាតិថៃ។ ប៉ុន្ដែ ទោះជាយ៉ាងនេះក្ដី ការផ្ដល់ព័ត៌មាននេះ វាជាសម្មតិកម្មមួយជួយជាគំនិតក្នុងការសិក្សាស្រាវជ្រាវរបស់យើងទៅថ្ងៃក្រោយទៀត។ ហើយពាក្យមួយចំនួនដែលយើងទទួលបាន យើងឃើញថាវាមិនទាន់មានលក្ខណៈសុក្រឹត្យល្អនៅឡើយ។ រាល់ការចេះចាំពាក្យ ប្រភពពាក្យឬប្រវត្តិណាមួយ ដែលមានតាំងពីដូនតាមកជាការប្រសើរខ្លាំងណាស់ ប៉ុន្ដែ ពាក្យមួយចំនួន ដែលបុគ្គលខ្លះខិតខំធ្វើការបកស្រាយទៅតាម សញ្ចេតនា ការយល់ឃើញផ្ទាល់ខ្លួន វាមិនមែនជាលក្ខណៈវិទ្យាសាស្ត្រនោះទេ។ ការវិភាគ ឬការធ្វើសន្និដ្ឋានទៅលើពាក្យណាមួយ ទាល់តែយើងសិក្សាស្រាវជ្រាវរកទិន្នន័យឱ្យបានច្រើនបំផុតតាមការដែលអាចធ្វើបាន ទើបយើងយកវាមកវិភាគបានគ្រប់ជ្រុងជ្រោយ។ ក្រុមស្រាវជ្រាវយើងនឹងធ្វើការថ្លឹងថ្លែងនិងពិចារណាទៅលើព័ត៌មានដែល

ទទួលបាននេះ តើពាក្យមួយណាមានលក្ខណៈសុក្រឹត្យជាងគេ។ យើងសង្ឃឹមថា ថ្ងៃក្រោយយើងនឹងបានជួបបងប្អូនជនជាតិកុឡាឬបងប្អូនយើងមានវ័យចំណាស់ៗដែលពួកគាត់រស់នៅទីនោះតាំងពីដូនតាសម័យមុនៗមក ហើយចេះចាំប្រវត្តិទីតាំងនានាបានច្រើនជាងនេះ។ ចំពោះពាក្យមួយចំនួន ដូចជាពាក្យ « **បហ៊ុយខ្មែរ ឬ បហ្វៃខ្មែរ** » តាមការសិក្សាពាក្យនេះ យើងគួរតែរក្សាប្រវត្តិរបស់ពាក្យនិងប្រភពរបស់ពាក្យប្រសើរជាង ពីព្រោះពាក្យ « **បហ៊ុយខ្មែរ ឬ បហ្វៃខ្មែរ** » នេះ ជាពាក្យដ៏ល្អមួយសម្រាប់ប្រវត្តិឋាននាមទីក្រុងប៉ៃលិន របស់យើង បើតាមន័យ ដែលផ្ដល់ដោយលោក ខុន សុភ័ក្ត្រ និង កញ្ញា ឋាបនី ឫក្សឌី។

យើងខ្ញុំទាំងអស់គ្នាជាក្រុមស្រាវជ្រាវផ្នែកវចនស័ព្ទវិទ្យា មកពីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា សូមគោរពថ្លែងអំណរគុណ ចំពោះគណៈគ្រប់គ្រងក្រុងប៉ៃលិនទាំងអស់ដែលមាន ឯកឧត្ដម **អ៊ី ឈាន** អភិបាលក្រុង; ឯកឧត្ដម *អ៊ិច សារូ* អភិបាលរងក្រុង និង លោក *យ៉ោក នួយ* នាយខុទ្ទកាល័យសាលាក្រុង ព្រមទាំងមន្ត្រីសាលាក្រុងទាំងអស់ ដែលបានទទួលក្រុមយើងខ្ញុំយ៉ាងរាក់ទាក់និងកក់ក្ដៅ ជាពិសេស ឯកឧត្ដម *អ៊ិច សារូ* និង លោក *យ៉ោក នួយ* បានជួយខ្នះខ្នែងក្នុងការផ្ដល់ព័ត៌មានដែលទាក់ទងទៅនឹងពាក្យមួយចំនួននៅក្នុងក្រុងប៉ៃលិន ព្រមទាំងជួយសម្រួលដល់ការស្រាវជ្រាវនិងស្នាក់នៅរបស់ក្រុមស្រាវជ្រាវយើងខ្ញុំ។ ទន្ទឹមនឹងនេះ ពួកយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោក **ខុន សុភ័ក្ត្រ** យ៉ាងជ្រាលជ្រៅផងដែរ ដែលលោកបានចំណាយពេលដ៏មាន តម្លៃជូននិងផ្ដល់ព័ត៌មានដល់ពួកយើងខ្ញុំ។

ភ្នំពេញ, ថ្ងៃច័ន្ទ ទី១០ ខែមីនា ឆ្នាំ២០០៨
ផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ

**ក្រុមអ្នកស្រាវជ្រាវ**

- បណ្ឌិត **អ៊ុំ ចំន** ប្រធានបេសកកម្ម
- លោក **ជួរ គារី** អនុប្រធានបេសកកម្ម
- លោកស្រី **ហង់ ថាវី** សមាជិក
- លោក **លី សុធីរត្ន** សមាជិក
- លោកស្រី **តិម ស៊ីណា** សមាជិក
-លោក **សន ពៅ** សមាជិក
- លោក **លាង សុភាព** អនុប្រធាន បេសកកម្ម
- កញ្ញា **សុខ ឧស្សាហ៍** សមាជិក
- លោក **ស៊ិន ពិសិដ្ឋ** សមាជិក
- លោក **ឡុង សុរិន្ទ** សមាជិក

• *សែនលើកទី៥* ពេលស្រូវដុះបានប្រហែលកន្លះម៉ែត្រ គេធ្វើពិធីសែនដើម្បីសុំឱ្យស្រូវបែកគុម្ពល្អ និងទទួលផលបានផលច្រើន។

**គ្រឿងរណ្តាប់** : មានមាន់ ជ្រូក ស្រាបួនប្រាំពាង ដោយគេយកឈើមួយពុះជ្រៀកជាខ្នែង៤ ខ្នែងទីមួយ ដោតជង្គង់មាន់, ខ្នែងទីពីរដោតចំពុះមាន់, ខ្នែងទីបីដោតជង្គង់ជ្រូក, ខ្នែងទីបួនដោតនៅកន្ទុយជ្រូក ហើយគេយកបំពងច្រកស្រូវនោះមកដោតចំកណ្តាលខ្នែងទាំងបួន ដោយគេបួងសួងសុំឱ្យព្រះរបស់ស្រូវប្រទានពរដល់គេ ដើម្បីឱ្យគេប្រកបរបរដាំដំណាំបានផលល្អ ជាពិសេសសុំឱ្យស្រូវនៅឆ្នាំនេះទទួលបានផលច្រើន។

• *សែនលើកទី៦* នៅពេលស្រូវកំពុងដើម ការជម្រះស្មៅស្រូវនោះ វាតែងតែធ្វើឱ្យប៉ះដើមស្រូវបន្តិចបន្តួចជាមិនខាន ដូចនេះគេត្រូវតែធ្វើពិធីដើម្បីហៅព្រលឹងស្រូវឱ្យមកវិញ និង សុំឱ្យស្រូវមានផ្លែដាក់គ្រាប់ល្អ។

**គ្រឿងរណ្តាប់** : មានមាន់មួយ ស្រាមួយពាង

• *សែនលើកទី៧* នៅពេលស្រូវក្រែងទុំ

បងប្អូនជនជាតិទំពួនដាំស្រូវពីរប្រភេទ គឺស្រូវស្រាល និង ស្រូវធ្ងន់។ តែមានស្រូវស្រាលមួយប្រភេទទៀតហៅថា"**ស្រូវក្រែង**"។ ពេលស្រូវនេះទុំ គេធ្វើពិធីសែនមួយដោយគេដុតគ្រឿងក្រអូបជាដើមឈើមួយប្រភេទមានក្លិនក្រអូបឈ្ងុយឈ្ងប់។ សែនរួចគេចាប់ផ្តើមបូតស្រូវដោយដុតឈើក្រអូបបណ្តើររហូតចប់កម្មវិធី រួចយកស្រូវដែលបូតបាននេះទៅស្ងោរហើយឆ្អើរភ្លើងទៀតផង។ បន្ទាប់មកគេយកទៅបុកជាអង្ករយកត្រឡប់មកភូមិវិញ។ គេយកអង្ករស្រូវចាស់មួយកំប៉ុងដាំបាយលាយបញ្ចូលជាមួយអង្ករស្រូវថ្មី ដោយគេនិយាយសុំឱ្យស្រូវចាស់ស្រូវថ្មីនៅជាមួយគ្នាកុំប្រកែប្រកាន់អ្វីប្រៀបដូចចៅតាយាយនៅជាមួយគ្នា។ បន្ទាប់មក គេយកបាយដាំនេះទៅសែនជីដូនជីតាជាមុន ដោយហៅបងប្អូនញាតិមិត្តជិតខាងមកហូបបាយជាមួយគ្នាផង។

**គ្រឿងរណ្តាប់** : មានមាន់មួយ ស្រាមួយពាងតូច ដុតគ្រឿងក្រអូបរហូតចប់កម្មវិធី

• *សែនលើកទី៨* ពេលស្រូវស្រាលទុំ

**គ្រឿងរណ្តាប់** : មាន់មួយ, ស្រាមួយពាង, ស្រូវមួយកួរដាក់លើពាងស្រា។

• *សែនលើកទី៩* : ពេលស្រូវធ្ងន់ទុំ គេសែនឧបកិច្ច ដើម្បីឱ្យស្រូវបានផលច្រើន។

**គ្រឿងរណ្តាប់** : មាន់មួយ, ស្រាមួយពាង, កួរស្រូវមួយកួរ ដាក់លើពាងស្រា។

• *សែនលើកទី១០* ពេលគេបូតស្រូវអស់ពីចម្ការពីរបីថ្ងៃក្រោយពេលបូតរួចគេធ្វើពិធីសែនមួយទៀត គេបូតស្រូវដែលគេទុកពីរបីគុម្ពពីមុននោះទៅចាក់ក្នុងជង្រុក ហើយគេអង្គុយមួយសន្ទុះមុននឹងកើបស្រូវចេញពីជង្រុកដាក់កាផាយកទៅផ្ទះ។

**គ្រឿងរណ្តាប់** : មានស្រាមួយពាង

• *សែនលើកទី១១* ជាពិធីបញ្ចប់នៃការប្រមូលផលទាំងអស់ និង ជាពិធីបញ្ជាក់ថាស្រូវទាំងនេះ ត្រូវយកទៅបរិភោគនិងប្រើប្រាស់ផ្សេងៗ ។

**គ្រឿងរណ្តាប់** : មានស្រាមួយពាង

ពិធីចុងក្រោយនេះ ជាកិច្ចបញ្ចប់នៃការសែនស្រូវ ឬ ហៅថាពិធីសែនធ្វើចម្ការរបស់បងប្អូនជនជាតិទំពួន ។

ជាសរុប យើងឃើញថា ការធ្វើចម្ការរបស់បងប្អូនជនជាតិទំពួននៅខេត្តរតនគីរី ការដាំដុះដំណាំស្រូវ គឺជាការមួយមានការជាប់ពាក់ពន្ធ័ទៅនឹងផ្នែកជំនឿច្រើនបំផុត ។ មុននឹងធ្វើការធ្វើបងប្អូនជនជាតិតែងតែផ្តេកផ្តួលលទ្ធផលរបស់គេទៅតាមការយល់ និង ធ្វើពិធីសែនព្រេនជានិច្ច ។ ទំនៀមទម្លាប់នេះ ត្រូវបានបងប្អូនជនជាតិប្រតិបត្តិ គ្រប់គ្រួសារ ដែលហៅថា "**ពិធីសែនស្រូវ**" ។

ប៉ុន្តែ រហូតមកដល់បច្ចុប្បន្ន បងប្អូនជនជាតិទំពួន ក៏ដូចជនជាតិផ្សេងៗទៀតដែរ ដែលរស់នៅក្នុងខេត្តរតនគីរី មានជីវភាពនិងការរស់នៅ ប្រែប្រួលផ្លាស់ប្តូរច្រើន ។ ប្រពៃណី ទំនៀមទម្លាប់របស់ដូនតាមួយចំនួនមិនត្រូវបានគេអនុវត្តបន្តទៅទៀតទេ ។ បងប្អូនជនជាតិទាំងអស់ មិនថាតែជនជាតិទំពួនឡើយ មិនសូវធ្វើកសិកម្មបែបពនេរចរទៀតទេ ព្រោះពួកគាត់យល់ថា ធ្វើឱ្យពួកគាត់ខាតពេលវេលា ពិបាកក្នុងការរៀបចំកសាងផ្ទះសម្បែងសារជាថ្មី ។ ម្យ៉ាងវិញទៀត បច្ចុប្បន្ននេះ កាលណាបងប្អូនជនជាតិទាំងនោះធ្វើការផ្លាស់ប្តូដីធ្វើស្រែចម្ការវិលជុំ ទម្រាំវិញមកដល់កន្លែងដើមវិញ ដីរបស់គាត់អាចត្រូវបាត់បង់ដោយមានម្ចាស់ថ្មីមកកាន់កាប់ជំនួស ។

**ផ្នែក អក្សរសាស្ត្រ អក្សរសិល្ប៍**

**ក្រុមអ្នកស្រាវជ្រាវ**

| | |
|---|---|
| ១-បណ្ឌិត អ៊ីវ ច័ន | ប្រធានបេសកកម្ម |
| ២-លោក ណុន សុខា | អនុប្រធាន |
| ៣-លោកស្រី ភាជ ណាង | សមាជិក |
| ៤-កញ្ញា សុង ឧស្សាហ៍ | - |
| ៥-លោក ប៊ី សុខគង់ | - |
| ៦-លោកស្រីគីម កែវកល្យាណ | - |
| ៧-លោក ជួន ជីវិន | - |

# ទំនៀមទម្លាប់ធ្វើចម្ការរបស់ជនជាតិទំពួន
# នៅខេត្តរតនគិរី

ជនជាតិទំពួនរស់នៅស្ទើរគ្រប់ស្រុកទាំងអស់ក្នុងខេត្តរតនគិរី។ បងប្អូនជនជាតិទំពួនក៏ដូចបងប្អូនជនជាតិមួយចំនួនទៀតនៅក្នុងខេត្តរតនគិរីដែរ ពួកគេប្រកបរបរធ្វើចម្ការតាមលក្ខណៈជាពនេចរ។ ការធ្វើចម្ការនេះ មានដំណាំស្រូវជាចំបង ក្រៅពីស្រូវមានដាំបន្លែផ្សេងៗដូចជា: ត្រសក់ ល្ពៅ ល្ហុង ម៉ាត្រីវ ជាដំណាំរួមផ្សំផងដែរ។ ជាទូទៅ ចាប់ពីខែមីនា គឺជារដូវចាប់ផ្ដើមកាប់ព្រៃធ្វើចម្ការរបស់បងប្អូនជនជាតិទំពួន។ ពួកគាត់នាំគ្នាចេញពីភូមិទៅស្នាក់នៅឯចម្ការ ដើម្បីប្រកបរបរដាំដុះនារដូវវស្សា រហូតដល់ខែវិច្ឆិកា ឬ ខែធ្នូ ទើបត្រឡប់ចូលភូមិវិញ។ ពេលទំនេរពីការងារបុរសៗទៅប្រកបរបរផ្សេងៗ ដូចជាបរបាញ់សត្វ បំពុលត្រី ... ចំណែកនារីវិញ ពួកគេត្បាញសំពត់ប៉ុង ភួយ ក្រមា ចង់ស្ពាយ ដែលធ្វើអំពីកប្បាសបានមកពីការដាំនៅឯចម្ការ។

### របៀបធ្វើចម្ការរបស់ជនជាតិទំពួន

ទម្លាប់របស់ជនជាតិទំពួន ដល់ពេលរដូវធ្វើចម្ការ គេត្រូវដើរមើលដីជាមុន បើគេពេញចិត្តកន្លែងណាមួយហើយ គេកាប់ឆ្ការព្រៃកន្លែងនោះបន្តិច រួចគេត្រឡប់មកផ្ទះវិញដោយរង់ចាំមើលការយល់សប្តិរបស់គេនៅពេលយប់។ ប្រសិនបើគេយល់សប្តិឃើញផ្លែសាវម៉ាវ ផ្លែ ពង្រ ផ្លែរោល ផ្លែតង្កៀបក្ដាម មានន័យថា ដីគេពេញចិត្តនោះ អាចដាំស្រូវនិងដំណាំផ្សេងៗបានផ្លែផលល្អ ហើយថែមទាំងមានអារក្សអ្នកតាជួយតាមថែរក្សាគេមិនឱ្យមានជំងឺឈឺស្កាត់ឬគ្រោះថ្នាក់អ្វីកើតមានចំពោះគេឡើយ។ តែប្រសិនបើគេយល់សប្តិឃើញទឹកភ្លៀង ស្រូវ ចម្រៀងស្ងួត កាប់ឈ្លូស វាយមាន់ ពួកគេមិនកាប់ចម្ការនោះទេ ដោយគេមានជំនឿថា ពេលគេដាំដំណាំលើដីនោះ វាមិនមានលទ្ធផលល្អដល់គេឡើយ (ទឹកភ្លៀងសំដៅលើទឹកភ្នែកយំ, ស្រូវ មានន័យថា មានមនុស្សឈឺ នៅពេលធ្វើចម្ការ ស្រូវមិនល្អ ដូចនេះ គេត្រូវរកកន្លែងថ្មីផ្សេងទៀត)។

ក្នុងករណីគេកាប់ព្រៃធ្វើចម្ការមិនបានផ្សងតាមការយល់សប្តិមើលដីថាល្អឬអាក្រក់នោះ បើពេលគេកាប់ព្រៃបានជួបនឹងសត្វផ្សេងៗដូចជា ឈ្លូស មាន់ កំប្រុក ដង្កែន ងាប់នៅក្នុងចម្ការដែលគេកំពុងកាប់នោះ គេត្រូវឈប់កាប់ព្រៃនេះភ្លាម។ ទោះបីគេកាប់បានដីច្រើនក៏ដោយ ក៏ត្រូវទៅរកកន្លែងផ្សេងទៀតដែរ ព្រោះគេមានជំនឿថា គេជួបប្រផ្នូលមិនល្អ។ បើគេធ្វើចម្ការលើដីនេះ រូបគេនិងក្រុមគ្រួសារត្រូវមានគ្រោះថ្នាក់ឬស្លាប់ដូចសត្វនោះដែរ។

ករណីមួយទៀត គេទៅកាប់កន្លែងដែលគេពេញចិត្តបួនប្រាំព្រឹកសិន រួចគេយកមាន់និងស្រាមួយពាងទៅសែនលើដីចម្ការនោះ។ បន្ទាប់មក គេធ្វើការបួងសួងសុំអារក្សអ្នកតានៅទីនេះថា "ខ្ញុំកាប់ចម្ការនិងចង់រស់នៅទីនេះ តើអារក្សអ្នកតាឱ្យយើងកាប់និងរស់នៅដែរឬអត់?" ពេលគេសែនស៊ីផឹករួចរាល់ គេ

យកដើមចេកមួយដើមដាំលើដីចម្ការនិងយកអង្កាមចេញពីស្រាពាងនោះដាក់ជុំវិញគល់ចេក គេបន់ស្រន់បួងសួងដល់អារក្សអ្នកតានោះ ថាប្រសិនបើអារក្សអ្នកតាមិនអនុញ្ញាតឱ្យគេធ្វើចម្ការនិងរស់នៅទីនេះទេ សូមឱ្យដើមចេកនេះបាត់ពីទីនេះភ្លាម ឬ មានសត្វអ្វីមកឆ្កឹះឆ្កៀលគល់ចេកនេះ បើកន្លែងនេះល្អព្រមអនុញ្ញាតឱ្យគេកាប់ចម្ការនិងរស់នៅទីនេះ សូមឱ្យចេកនៅកន្លែងដដែលព្រមទាំងមានស្រមោចមករោមអង្កាមនៅគល់ចេកដែលយកចេញពីស្រាពាងនោះ។ ព្រឹកស្អែក ពេលគេទៅមើលបើឃើញស្រមោចរោមអង្កាមមានន័យថា ពេលដាំដំណាំនឹងទទួលបានផលល្អទាំងស្រូវទាំងដំណាំផ្សេងៗ ហើយគេក៏រៀបចំសែនតាមប្រពៃណី។

**ក្នុងពិធីសែនមានដូចតទៅ :**

• *សែនលើកទី១* ពេលគេកាប់ព្រៃតូចៗអស់

ទម្លាប់នៃការកាប់ចម្ការរបស់ជនជាតិទំពួនគេត្រូវកាប់ព្រៃតូចៗជាមុន រួចទើបគេកាប់ដើមធំជាក្រោយ។ ពេលកាប់ព្រៃតូចអស់ គេធ្វើពិធីសែនសុំឱ្យអារក្សអ្នកតាជួយថែរក្សាពួកគេកុំឱ្យមានគ្រោះថ្នាក់ដោយសារកាំបិត ពូថៅ ដឹង ឬ ដោយប្រការអ្វីផ្សេងទៀតនៅពេលកាប់ដើមធំៗ។

**គ្រឿងរណ្ដាប់ :** មានមាន់មួយ ស្រាមួយពាង

• *សែនលើកទី២* ដើម្បីឱ្យព្រៃឆេះល្អ

ពេលកាប់រួចរាល់ គេទុកព្រៃហាលថ្ងៃប្រហែល១៥ថ្ងៃទើបគេដុត។ មុននឹងដុត គេធ្វើពិធីសែនដើម្បីឱ្យព្រៃឆេះល្អ រួចគេយកបំណែកសល់ពីឆេះទៅដាក់លើមាត់ពាងទឹក តំណាងឱ្យភាពត្រជាក់ត្រជុំមិនមានជំងឺ គឺត្រជាក់ដូចទឹក។

**គ្រឿងរណ្ដាប់ :** មានមាន់មួយ ស្រាមួយពាង

• *សែនលើកទី៣* រើព្រៃក្រោយពីដុតរួច គេត្រូវសែនមុននឹងរើព្រៃដែលដុតឆេះចេញពីចម្ការ

**គ្រឿងរណ្ដាប់ :** មានមាន់មួយ ស្រាមួយពាង ដាំដើមចេក១ដើម យកអង្កាមចេញពីស្រាពាងដាក់ជុំវិញគល់ចេកនោះ។ ពេលគេទៅចម្ការព្រឹកឡើងបានឃើញដានជើងមនុស្សនៅលើអង្កាមនោះ មានន័យថា ចម្ការនេះនឹងមានមនុស្សស្លាប់,ឃើញដានជើងឈ្លូសមានន័យថា មានគោស្លាប់, ឃើញដានជើងគោ មានន័យថា មានក្របីស្លាប់។

• *សែនលើកទី៤* ចាប់ផ្ដើមដាំស្រូវ

មុននឹងចាប់ផ្ដើមដាំស្រូវគេត្រូវសែន ដោយកាប់បំពង់ឫស្សីប្រវែងមួយហត្ថ ច្រកពូជស្រូវចូលក្នុងបំពង់ រួចយកទៅដាំឱ្យបានប្រហែលមួយម៉ែត្របួនជ្រុង ដើម្បីគេធ្វើពិធីសែនបួងសួងសុំឱ្យស្រូវល្អ បើមិនសែនព្រះរបស់ស្រូវនឹងកាច់ពួកគេឱ្យស្លាប់ភ្លាម។

**គ្រឿងរណ្ដាប់ :** មានមាន់មួយ ស្រាមួយពាង

# BRAO DIALECTS: LEXICAL AND PHONOLOGICAL VARIATIONS

Charles Keller
Jacqueline Jordi
Kenneth Gregerson
Ian G. Baird[1]

## 0. Introduction: the Brao

Brao is a Mon-Khmer language belonging to the West Bahnaric subgroup and has been classified within the schema[2] below:

| | |
|---|---|
| | Northwest Bahnaric |
| | North Bahnaric |
| Proto-Bahnaric | West Bahnaric → BRAO, et al. |
| | Central Bahnaric |
| | South Bahnaric |

FIGURE 1. THE CLASSIFICATION OF BRAO WITHIN BAHNARIC

In this paper we use the term *Brao* to refer generically to the set of West Bahnaric speech varieties that includes the *Ombaa*, *Ka-nying*, *Hamong*, *Kavet*, [3] and *Jrii* subgroups, who live north of the Sesan river in Ratanakiri and Stung Treng Provinces, northeastern Cambodia and extending north across the mountain range into Attapeu and Champasak Provinces in southern Laos, where the Brao are also referred to as *Lave(h)*. Brao also includes the *Lowland Brao* (*Brao Tanaap*) and the *Krung* speech communities, who live south of the Sesan river extending to the south of Ban Lung towards Lom Phat. Finally, there are also communities known as *Lun*, which are more problematic as to classification, involving riverine Brao settlements that, on the face of it, sometimes appear linguistically akin to speech communities south of the Sesan and sometimes to those north of the Sesan. Research in the past few years (especially by J. Jordi and I. Baird) now offers the possibility of beginning to clarify who the Lun are linguistically and making preliminary observations about how they may fit into the Brao dialects picture. Map 1 below shows the main geographic areas for each of the eight Brao varieties identified in this paper. Refer also to the chart of Brao Dialects (Fig. 2) which offers a broad classification along with a partial listing of representative locations for each dialect.




Map 1

Brao dialects in Cambodia and Laos

| **Varieties:** Northern Brao | | | | | Southern Brao | | |
|---|---|---|---|---|---|---|---|
| **Regions:** Western Highlands | | | Eastern Highlands | | North of Ban Lung | Along SeSan, SeKong, etc. | South of Ban Lung |
| **Jrii** | **Kavet** | **Hamong** | **Ombaa** | **Ka-nying** | **Krung** | **Lun** | **LL Brao** |
| Viang Xay (Jeur Wiang) (L) | Kavet Stream* (L) | Vongsam-phan (L) | Kampha (Ombaa) River (C) | I-toum ('Ntoom) (L) | O Chum (C) | Rundiem, Rumbat (C) | Padung Stream (C) |
| Cheung Hiang (Jeu Hiang) (L) | Ndraak Stream (L) | Ta-oum (Tra-oum) (L) | Sesan River (C) KengMak Kheua(L) | | La Ok (C) | Vang (C) | Kantrieng (C) |
| Vong Xay (L) | Lelai (Heulay) (C) | Mak Kiang (L) | Tabok (Trabok) Stream(C) | Boung Vay (L) | Taveng (C) | Din Daeng (C) | Kancain (C) |
| Vonglakhone (L) | Sekong River (DakDanai TangOng) (C) | Vang Nyang (L) | Hamok (C) | Houay Le (L) | Kalai (Klai) (C) | Ban Na (Tambaing), HouayKeua (Kamba) and Taong (Gaboh) (L) | Tangkap (C) |
| Oudomxay (Treo) (L) | Phou Xay (L) | Kang (L) | Bang Geut (C) | Houay Keo (DakRoo) (L) | Kroala (C) | Phon Sa-at (Pa) (L) | Sroksek (C) |
| Hat Phila (L) | Phou Hom (L) | Na Seuak (L) | Ke Kuang (C) | Nam Souan (Dak Joor) (L) | Khuon (C) | Phnom Kok Brao (C) | Ramblain (C) |
| Hat Sai Soung (L) | Vong Vilai Neua (Ta Bak Reung) (L) | Houay Kout (L) | Yom (Bong)(C) | Hat Xan (L) | Chuay (Njuy) (C) | Pleu (Pareu) | Tuh (C) |
| Houay Ko (L) | Lamong (L) | | Phao (C) | Palai (C) | Mas (Chan) (C) | Tanaic | Teun (C) |
| | | | Tampuan Reung(C) | | | | Cha Ung (C) |
| | | | Koh Pong (Blawng Stream) (C) | | | | Taong (C) |

* Brao dialect place names are often derived from rivers or streams along which they live (e.g. Ombaa, Kavet, Hamong), while other names are purely village designations (e.g., Viang Xay). Country locations above are indicated as Cambodia (C) and Laos (L).

FIGURE 2. BRAO DIALECT LOCATIONS

The speech of Northern Brao communities, who all live north of the Sesan river, varies in both lexical and phonological ways from those of Southern Brao villages, who live south of the Sesan river in (Ratanakiri Province) Cambodia. In the Northern grouping the Jrii are situated in the west near the Sekong River, with the Kavet, Hamong, Ombaa and Ka-nying distributed to the east. Each of these groups identifies itself as being culturally and linguistically distinct from the others, with, for example, the Jrii dialect tending to be closest to the adjacent Kavet, and farthest from the Ka-nying to the far east, and the Ombaa dialect being the most similar to the Kanying and Hamong dialects, since these groups are adjacent to them. Thus, the Kavet dialect is, in some ways, similar to the Jrii to its west, and to the Hamong to its east.[4] South of the Sesan the Krung and Lowland Brao share a number of features that distinguish them from their brethren north of the Sesan, but there are also some regular (though not dramatic) speech variations between Krung and Lowland Brao. Social relations, however, between the Southern Brao groups do not reflect the kind of conventional antipathy reported between some of the Northern Brao communities, such as between the Kavet and the Ombaa. As to relations across the Sesan, a Kavet source told us that they had traditionally formed alliances with and gotten along well with the Krung. Some of the villages representing Brao varieties discussed in detail are located individually in Map 2a and Map 2b.

